ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- បារ៉ាក់ អូបាម៉ា នៅក្រោមសម្រស់ដ៏ត្រចះត្រចង់ដែលមិនចេះសាបសូន្យ
- ការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សនៅតំបន់អាស៊ីអាគ្នេយ៍

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥៦ ខែធ្នូ ឆ្នាំ២០១២

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៥៦ ខែធ្នូ ឆ្នាំ២០១២

## មាតិកា

◆បារ៉ាក់ អូបាម៉ា នៅក្រោមសម្រស់ ..........១

◆សិទ្ធិមនុស្ស ដែលជាសិទ្ធិរស់រានមានជីវិត ..........៤

◆ដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្រលើកទីមួយ ..........៧

**ផ្នែកឯកសារ**

◆ចម្លើយសារភាពរបស់ ព្រំ សុធា ..........១០

◆បញ្ជីឈ្មោះ និងរូបថតអ្នកទោសមន្ទីរស-២១ ..........១៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆តាំង គីម ជីវិតកម្មពៀរ និងការចង់បាន ..........២៤

◆មាស វឿន អតីតអនុប្រធានកងពលទី១ ..........២៧

**ផ្នែកច្បាប់**

◆អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ..........៣១

**វេទិកាពិភាក្សាសាធារណៈ**

◆ការចងក្រងឯកសារក្រោយពីអំពើឃោរឃៅ ..........៣៥

◆ការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សនៅតំបន់ ..........៤០

◆ពិភពមួយដែលគ្មានសង្គ្រាម ..........៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ដំណើរឆ្លងកាត់របបខ្មែរក្រហម ..........៥៦




បូជនីយដ្ឋានអ្នកសារព័ត៌មាន




ខួបលើទី៦៤ នៃទិវាសិទ្ធិមនុស្ស “ធុរកិច្ច និងសិទ្ធិមនុស្ស”

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ *អេង កុកថាយ, អាន ហាញឌុល, ចន ឆរឆើអារី, ស៊ីវ ធួន* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា* ***អ្នកបកប្រែ*** ៖ *នង ច័ន្ទមល្លិកា, ភួង ច័ន្ទប្រណិត* ***និពន្ធនាយក*** ៖ *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក*** ៖ *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** ៖ *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *ឆេង វេង* Email: dccam@online.com.kh, Homepage: www.dccam.org

# បារ៉ាក់ អូបាម៉ា នៅក្រោមសម្រស់ដ៏ត្រចះត្រចង់ ដែលមិនចេះសាបសូន្យនៃប្រាសាទអង្គរវត្ត

កិច្ចការនយោបាយកំពូល ការដឹកនាំរដ្ឋ និងយុទ្ធសាស្រ្តនយោបាយធំៗកកើតចេញពីបញ្ហាតូចៗ និងយុទ្ធសាស្រ្តសាមញ្ញបូកបញ្ចូលគ្នា ។ ជាមួយគ្នានេះ ដំណើរការប្រជុំកំពូល ទំនាក់ទំនងការទូត និងអង្គប្រជុំផ្សេងៗដែលត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាចម្បងរវាងប្រទេសធំៗទាំងឡាយ ក៏កើតចេញមកពីការស្វែងរកដំណោះស្រាយបញ្ហាតូចៗដែរ ។ នៅពេលដែលបញ្ហាតូចៗទាំងនេះត្រូវបានដោះស្រាយ ហើយកិច្ចព្រមព្រៀងត្រូវបានបង្កើតឡើង ចំណុចទាស់ទែងគ្នាត្រូវបានកំណត់ច្បាស់លាស់ ហើយអ្វីដែលត្រូវធ្វើបន្ទាប់ទៀតនោះ គឺបូកបញ្ចូលរឿងរ៉ាវតូចៗឲ្យទៅជាមេរៀនដែលមានប្រយោជន៍ ។ បញ្ហានៅក្នុងកិច្ចការនយោបាយថ្នាក់កំពូលទាំងអស់ ទាមទារឲ្យមានការបង្ហាញតាមរយៈការប្រើប្រាស់រូបភាពសម្លេង ឬនិមិត្តរូបផ្សេងទៀត ដើម្បីឆ្លុះបញ្ចាំងនូវរឿងរ៉ាវពិតប្រាកដឲ្យបានច្បាស់លាស់ និងធ្វើឲ្យមានលក្ខណៈកន្ត្រាក់អារម្មណ៍ ។ កិច្ចប្រជុំថ្នាក់កំពូលនិងការធ្វើសុន្ទរកថានៅចំពោះមុខថ្នាក់ដឹកនាំធំៗ នៅក្នុងសន្និសីទដែលមានការលម្អរចនាយ៉ាងត្រចះត្រចង់ និងដ៏មានតម្លៃក្នុងការជំរុញឲ្យមានការសម្រេចបាននូវសន្តិភាព សន្តិសុខ សហប្រតិបត្តិការ និងសិទ្ធិមនុស្ស ។ ប៉ុន្តែសុន្ទរកថាសំខាន់ៗក៏ទាមទារឲ្យមានការរចនាតុបតែងឆាកដ៏អធិកអធម ។ ដំណោះស្រាយដ៏ប៉ិនប្រសប់ ក៏ទាមទារឲ្យមានបរិយាកាសល្អដែរ ។ ទស្សនកិច្ចធំៗរបស់ថ្នាក់ដឹកនាំអន្តរជាតិ ទាមទារឲ្យមានកាយវិការជានិមិត្តរូបណាមួយដែលប្រែក្លាយរឿងរ៉ាវនយោបាយនិងសិល្បៈដឹកនាំរដ្ឋទៅជាអ្វីមួយដែលសាធារណជនអាចចងចាំជាប្រវត្តិសាស្រ្ត ។

ដូចគ្នានេះដែរ ដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា បង្ហាញឲ្យឃើញនូវលក្ខណៈប្រវត្តិសាស្រ្តយ៉ាងពិតប្រាកដមួយ ។ លោកគឺជាប្រធានាធិបតីកំពុងកាន់ដំណែងដំបូងបង្អស់របស់សហរដ្ឋអាមេរិកដែលបានមក



លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា ចូលរួមពិសារភោជនីអាហារពេលល្ងាចជាមួយបណ្តាមេដឹកនាំប្រទេសអាស៊ាន និងប្រទេសដែលជាដៃគូអាស៊ាន នៅមជ្ឈមណ្ឌលកោះពេជ្រ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២



សម្តេច ហ៊ុន សែន ស្វាគមន៍លោក បារ៉ាក់ អូបាម៉ា មុនពេលពិធីពិសារអាហារពេលល្ងាចនៅមជ្ឈមណ្ឌលកោះពេជ្រកាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២

ធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយប្រជាជនកម្ពុជារង់ចាំការមកដល់របស់លោកដោយក្តីអន្ទះសាជាយូរមកហើយ ។ ក៏ប៉ុន្តែនៅមានចំណុចជាច្រើនដែលលោកខកខានមិនបានបំពេញនៅក្នុងឱកាសនៃដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្រនេះ ។

នៅប្រទេសថៃ លោក បារ៉ាក់ អូបាម៉ា បានចូលជួបសម្តែងការគួរសមជាមួយព្រះមហាក្សត្រថៃ ហើយត្រូវបានស្វាគមន៍ដោយថ្នាក់ដឹកនាំព្រះពុទ្ធសាសនាជាច្រើនអង្គនៅវត្តភូ ។ លោកបានជួបជាមួយនាយករដ្ឋមន្ត្រីថៃ យីងឡាក់ ស៊ីណាវ៉ាត្រា ដែលបានរៀបចំអាហារពេលល្ងាចជាផ្លូវការដ៏រំភើបមួយជូនលោកប្រធានាធិបតី ។ លោក បារ៉ាក់ អូបាម៉ា និងលោកស្រី យីងឡាក់ ស៊ីណាវ៉ាត្រា បានធ្វើសន្និសីទសារព័ត៌មានរួមគ្នាមួយ និងចូលរួមក្បួនត្រួតពលកិត្តិយសដ៏ខត្តុង្គខត្តម ។

នៅប្រទេសភូមា លោក បារ៉ាក់ អូបាម៉ា ត្រូវបានទទួលស្វាគមន៍ដោយប្រជាពលរដ្ឋភូមារាប់ម៉ឺននាក់នៅតាមដងផ្លូវ ។ លោកបានជួបជាមួយមេដឹកនាំសិទ្ធិមនុស្សដ៏មានប្រជាប្រិយភាពមួយរូបគឺលោកស្រី អ៊ុងសាន ស៊ូជី នៅគេហដ្ឋានរបស់លោកស្រីក្បែរមាត់បឹង ។ លោក បារ៉ាក់ អូបាម៉ា និងលោកស្រី អ៊ុងសាន ស៊ូជី បានធ្វើសេចក្តីថ្លែងការណ៍ប្រកបដោយភាពជំរុញទឹកចិត្ត និងក្តីសង្ឃឹម ។ លោក បារ៉ាក់ អូបាម៉ា បានឡើងធ្វើសុន្ទរកថានៅសកលវិទ្យាល័យយ៉ាំងហ្គោនដល់សិស្សានុសិស្សដែលជានិមិត្តរូបមួយជំរុញឲ្យមានរបត់លទ្ធិប្រជាធិបតេយ្យនៅប្រទេសភូមា ។

ក៏ប៉ុន្តែ នៅប្រទេសកម្ពុជាស្ថានភាពមិនសូវមានលក្ខណៈអធិកអធមដូចនៅប្រទេសថៃ និងភូមាទេ ។ នៅពេលមកដល់ប្រទេសកម្ពុជា ក្បួនអមដំណើររថយន្តរបស់លោក បារ៉ាក់ អូបាម៉ា បានបើកតាមផ្លូវដែលគ្មានមនុស្សម្នាឈរអបអរសាទរម្នាក់សោះ ។ កម្ពុជាមិនបានរៀបចំក្បួនត្រួតពលកិត្តិយស ហើយក៏មិនមានស្ត្រីដែលបង្ហាញពីប្រពៃណី និងភាពអង់អាចទទួលស្វាគមន៍លោកប្រធានាធិបតីដែរ ។ ដំណើរទស្សនកិច្ចរបស់លោក បារ៉ាក់ អូបាម៉ា ត្រូវបានចាត់ទុកថាជារឿងសាមញ្ញ ដោយមិនមានការរៀបចំអធិកអធម និងអស្ចារ្យ ។ ខ្ញុំមានការសោកស្តាយដែលលោក បារ៉ាក់ អូបាម៉ា មិនបានទស្សនាប្រាសាទអង្គរវត្ត ។

ទង្វើបែបនេះអាចជាសញ្ញាណមួយថា ដំណើរទស្សនកិច្ចរបស់លោក បារ៉ាក់ អូបាម៉ា ដែលប្រជាជនកម្ពុជារំពឹងទុកយ៉ាងខ្លាំងនោះ មិនសូវមានសារៈសំខាន់ទេ ហើយក៏មិនបានបង្ហាញនូវកាយវិការណាមួយដែលជំរុញគំនិតឲ្យមានការប្រសើរឡើងនូវចំណងមិត្តភាពដ៏យូរអង្វែងដែរ ។ ដំណើរទស្សនកិច្ចរបស់លោក បារ៉ាក់ អូបាម៉ា គឺដើម្បីចូលរួមប្រជុំអាស៊ានតែប៉ុណ្ណោះ មិនមែនដើម្បីមកកាន់ប្រទេសកម្ពុជាទេ ។ សម្រាប់ប្រទេសកម្ពុជា ដំណើរទស្សនកិច្ចរបស់លោក បារ៉ាក់ អូបាម៉ា មិនបានធ្វើឡើងក្នុងបំណងបង្កើតវេទិកាជាប្រវត្តិសាស្ត្រ ជំរុញឲ្យមានការប្រសើរឡើងនូវមិត្តភាព និងផ្តល់នូវភាពវិសេសវិសាលនោះទេ ។ កិច្ចប្រជុំបានប្រព្រឹត្តឡើងប្រកបដោយបរិយាកាសល្អ ហើយពិភាក្សាពីបញ្ហាសំខាន់ៗជាច្រើនតែភាពខ្វះខាតនូវការបង្កើតវេទិកាជាប្រវត្តិសាស្ត្រ ខ្លឹមសារសំខាន់ៗ និងកាយវិការដែលជានិមិត្តរូបចំពោះដំណើរទស្សនកិច្ចនេះបានបង្ហាញថា កម្ពុជាត្រូវធ្វើដំណើរដ៏វែងឆ្ងាយទៅមុខទៀត ។

ខ្ញុំមានការសោកស្តាយត្រង់ថា ដំណើរទស្សនកិច្ចរបស់លោក បារ៉ាក់ អូបាម៉ា មិនបានសម្លឹងមើលកម្ពុជាឲ្យបានច្រើនជាងនេះ ដើម្បីគយគន់មើលវប្បធម៌ដ៏ស្រស់ផូរផង់របស់ប្រទេសកម្ពុជានិងប្រជាជនរាប់លានដែលប្រឹងរស់ពីរបបខ្មែរក្រហមដោយក្តីសង្ឃឹម

ចំពោះអនាគត ប្រសិនបើទុកបញ្ហានយោបាយមួយអន្ទើសិន ។ ថ្នាក់ដឹកនាំរបស់រដ្ឋាភិបាលនានាត្រូវគោរពតាមរបៀបវារៈដែលបានគ្រោងទុក និងត្រូវដោះស្រាយបញ្ហាដែលកំពុងតែកើតមានឡើងដែលជាកិច្ចការចាំបាច់ដែលត្រូវធ្វើ ។ កម្ពុជាគឺជាទឹកដីមួយប្រកបដោយភាពស្រស់បវរ ហើយខ្ញុំសង្ឃឹមថា លោក បារ៉ាក់ អូបាម៉ា ក៏ទទួលអារម្មណ៍នូវសម្រស់ដ៏គ្រប់គ្រងនេះដែរ ។ ខ្ញុំក៏រំពឹងដែរថា ថ្ងៃណាមួយ លោកនឹងនាំក្រុមគ្រួសារមកទស្សនាប្រាសាទអង្គរវត្តដ៏អស្ចារ្យនេះ ។ មានហេតុផលជាច្រើនដែលជំរុញឲ្យលោក បារ៉ាក់ អូបាម៉ា (ឬមេដឹកនាំពិភពលោកផ្សេងទៀត) គួរមកទស្សនាប្រាសាទអង្គរវត្ត ។

ប្រាសាទអង្គរវត្តឋិតក្នុងចំណោមអច្ឆរិយវត្ថុទាំងប្រាំពីររបស់ពិភពលោកនិងជាសម្បត្តិមនុស្សជាតិ ហើយប្រាសាទនេះផ្តល់នូវអត្ថន័យយ៉ាងជ្រាលជ្រៅសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប និងជានិមិត្តរូបនៃអរិយធម៌របស់កម្ពុជានាពេលបច្ចុប្បន្ននេះ ។ ប្រាសាទអង្គរវត្តគឺជានិមិត្តរូបនៃអរិយធម៌ដែលអាចធ្វើឲ្យលុបបាត់នូវអតីតកាលប្រកបទៅដោយភាពចម្រូងចម្រាសរបស់ប្រទេសកម្ពុជា ។ ប្រាសាទអង្គរវត្តគឺជាវត្ថុបុរាណដ៏ស័ក្តិសិទ្ធិនៃអរិយធម៌ខ្មែរដែលបានជម្នះឧបសគ្គធំៗរាប់មិនអស់ ។ កម្ពុជាបានឆ្លងផុតដំណាក់កាលរបបអាណានិគម ការកាប់សម្លាប់ សង្គ្រាម អំពើប្រល័យពូជសាសន៍ គ្រោះទុរ្ភិក្ស និងអំពើឈ្លានពានពីសំណាក់បរទេស ។ ស្រដៀងគ្នានេះដែរ ប្រាសាទអង្គរវត្តបានឈរបង្អួតខ្លួនរាប់ពាន់ឆ្នាំមកហើយក្រោមដំណក់ទឹកភ្លៀង កម្តៅថ្ងៃដ៏ក្តៅហែង និងខ្យល់ព្យុះបក់បោកគ្មានត្រាប្រណី ។ ប្រៀបបានដូចជាវប្បធម៌ខ្មែរដូច្នោះដែរ ប្រាសាទអង្គរវត្តនៅតែទាក់ចិត្តទាក់អារម្មណ៍អ្នកទស្សនា និងមនុស្សគ្រប់រូបដែលកោតសរសើរមិនដាច់ពីមាត់នូវវប្បធម៌ដ៏គ្រប់គ្រងនេះ ។

ដូចគ្នាទៅនឹងប្រទេសថៃ និងភូមាដែរ កម្ពុជាគឺជាប្រទេសដែលមានវប្បធម៌គ្រប់គ្រងនិងប្រកបដោយភាពទន់ភ្លន់ ។ ខ្ញុំសង្ឃឹមថា លោក បារ៉ាក់ អូបាម៉ា បានឃើញភាពទន់ភ្លន់នេះតាមរយៈគំនូរមួយផ្ទាំងដ៏ធំនៅពីមុខលោក នៅពេលដែលលោកឈរពីមុខជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ការទទួលបាននូវសម្រស់ដ៏ទន់ភ្លន់បែបនេះនៅប្រាសាទអង្គរវត្តគឺជាការរំលឹកថា ភាពរុងរឿងរបស់ប្រទេសកម្ពុជានឹងមានសម្រស់មិនចេះសាបសូន្យ ទោះបីជាទស្សនវិស័យសម្រាប់អនាគតនៅកំពុងលូតលាស់យ៉ាងណាក៏ដោយ ។

**ឆាំង យុ**



លោក បារ៉ាក់ អូបាម៉ា នៅវិមានសន្តិភាពដែលមានរូបប្រាសាទអង្គរវត្តនៅពីក្រោយ ។ រូបថត ៖ សេតវិមាន

# សិទ្ធិមនុស្ស ដែលជាសិទ្ធិរស់រានមានជីវិត សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍

ដោយសារកម្ពុជាជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ និងអំពើយង់ឃ្នង កម្ពុជាប្រកាន់ជំហរយ៉ាងអង់អាចក្នុងការក្រើនរំឭកសហគមន៍អន្តរជាតិ អំពីសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សសម័យទំនើប ដំបូងរបស់ខ្លួនដែលជាអនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទោសទណ្ឌឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍គឺជាសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សសម័យទំនើបដំបូង ដែលទទួលបានការទទួលស្គាល់ ជាពិសេសដោយហេតុថាអនុសញ្ញានេះបង្ហាញលក្ខណៈនៃចលនាសិទ្ធិមនុស្សក្នុងសម័យក្រោយឆ្នាំ១៩៤៥ ។ ជាងនេះទៅទៀតដូចជាក្នុងករណីប្រទេសកម្ពុជា អនុសញ្ញានេះ មានទម្ងន់ខាងសីលធម៌ ដែលកើតចេញពីប្រវត្តិសាស្ត្ររបស់កម្ពុជា និងការបន្តជជែកពីកាតព្វកិច្ចរបស់មនុស្សជាតិនាពេលបច្ចុប្បន្ន ។

ចលនាសិទ្ធិមនុស្ស ដែលត្រូវបានរំលឹកនៅថ្ងៃទី១០ ខែធ្នូ បានទាញលក្ខណៈសំខាន់ពីលិខិតុបករណ៍ផ្លូវច្បាប់ និងទស្សនៈដែលលើកឡើងបន្ទាប់ពីសង្គ្រាមលោកលើកទី២ ។ គួរឲ្យកត់សម្គាល់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិបានបង្កើតឲ្យមានការបន្តការប្តេជ្ញាចំពោះសិទ្ធិមនុស្សជាមូលដ្ឋាន ។ មាត្រា១ បានចែងថាមួយក្នុងចំណោមគោលបំណងរបស់អង្គការសហប្រជាជាតិ គឺដើម្បីសម្រេចឲ្យបានកិច្ចសហការរបស់អន្តរជាតិក្នុងការលើកស្ទួយ និងការជំរុញឲ្យមានការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសំរាប់មនុស្សជាតិទាំងអស់គ្នាដោយគ្មានការបែងចែកពូជសាសន៍ ភេទ ភាសា ឬសាសនា ។ ទោះបីជាយ៉ាងនេះក៏ដោយ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ មិនបានពិពណ៌នាអំពីសិទ្ធិមនុស្ស ឬបង្កើតអាណត្តិជាក់លាក់ណាមួយ ឬយន្តការក្នុងការធានាឲ្យមានការអនុវត្តសិទ្ធិមនុស្សក្នុងបណ្តារដ្ឋសមាជិកឡើយ ។ ជាងនេះទៅទៀត ភាសាដែលប្រើសម្រាប់គាំទ្រសិទ្ធិមនុស្សក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ មិនហួសពីពាក្យ “ការលើកស្ទួយ” និង “ការជំរុញ” ។

ម្យ៉ាងវិញទៀត អនុសញ្ញាដែលបានអនុម័តក្រោយធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងមុនសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានកំណត់ឲ្យប្រទេសជាច្រើនប្រើចំណាត់ការកាត់ទោស និងការទប់ស្កាត់ក្នុងការគាំទ្រសិទ្ធិមនុស្សជាមូលដ្ឋានដែលជាសិទ្ធិរស់រានមានជីវិត ។ អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍



ការដង្ហែរក្បួនពីពហុកីឡដ្ឋានជាតិអូឡាំពិកឆ្ពោះទៅកាន់ទីលានសេរីភាពក្នុងឱកាសប្រារព្ធ

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ កើតចេញពីការស្អប់ខ្ពើមយ៉ាងខ្លាំងចំពោះគោលនយោបាយកំណាចរបស់ជនណាហ្ស៊ីអាល្លឺម៉ង់អំឡុងសង្គ្រាមលោកលើកទី២ ដែលក្នុងនោះ ជនជាតិជ្វីហ្វ ប្រជាជនស្លាវ អ្នកស្រលាញ់ភេទដូចគ្នា ជនពិការ និងអ្នកផ្សេងទៀត ត្រូវបានសម្លាប់នៅតាមជំរុំប្រមូលផ្តុំ និងយុទ្ធនាការសម្លាប់ជាច្រើន ។ អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ បានបង្កើតអាណត្តិផ្លូវច្បាប់សម្រាប់សមាជិកជាប់ពាក់ព័ន្ធដើម្បីទប់ស្កាត់ និងដាក់ទោសទណ្ឌ

បទប្រល័យពូជសាសន៍ ។ អាណត្តិនេះ មានសារសំខាន់ក្នុងន័យពង្រីកពាក្យពេចន៍ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិក្នុងការជំរុញដាស់តឿន និងការគាំទ្រសិទ្ធិមនុស្ស ហើយអណត្តិនេះបង្ហាញលក្ខណៈរបស់កិច្ចព្រមព្រៀងដែលមានលក្ខណៈជំរុញលើកទឹកចិត្ត និងគ្មានការបង្ខំដែលជា *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* ដែលត្រូវបានអនុម័តនៅថ្ងៃបន្ទាប់ (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨) ។ អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍គឺជាអនុសញ្ញាដំបូងដែលបង្វែរចលនាសិទ្ធិមនុស្សចេញពីការអំពាវនាវយ៉ាងមុតមាំចំពោះការគោរពសិទ្ធិមនុស្សយ៉ាងប្រសើរទៅរកច្បាប់ដែលចាំបាច់



ខួបលើកទី៦៤នៃទិវាសិទ្ធិមនុស្សអន្តរជាតិ នៅព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១២ ។

ត្រូវអនុវត្តដែលមានការកាត់ទោស ។ សារសំខាន់នៃការផ្លាស់ប្តូរនេះមិនគួរត្រូវបំបាត់ចោលក្នុងការរំលឹកដល់សិទ្ធិមនុស្សឡើយ ។

ប៉ុន្តែពេលដែលថ្ងៃប្រារព្ធសិទ្ធិមនុស្សជាសកល គឺជាថ្ងៃដ៏សំខាន់ដើម្បីរំលឹកពីសមិទ្ធផលរបស់មនុស្សជាតិ ក្នុងការលើកស្ទួយសិទ្ធិមនុស្សជាសាកល ថ្ងៃនោះក៏ជាឱកាសដ៏សំខាន់សម្រាប់ការឆ្លុះបញ្ចាំងពីកង្វះខាតខាងចលនាសិទ្ធិមនុស្ស ។ បទប្រល័យពូជសាសន៍ បានបន្តញាំញីសហគមន៍អន្តរជាតិ ចាប់តាំងពីមានអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍នេះ ។ ប្រវត្តិសាស្ត្រដ៏ញាំញីរបស់អនុសញ្ញានេះ ជាការក្រើនរំលឹកដែលសូម្បីតែមូលដ្ឋានសិទ្ធិមនុស្សទាំងអស់ ដូចជាសិទ្ធិរស់រានមានជីវិត អាចជាច្បាប់សកល ប៉ុន្តែវាមិនមែនជាបទដ្ឋានសកលឡើយ ។ ប្រវត្តិសាស្ត្រដែលហ៊ុមព័ទ្ធរបបកម្ពុជាប្រជាធិបតេយ្យ បង្ហាញពីអំពើយង់ឃ្នងដែលបានកើតឡើងដោយមានការទប់ស្កាត់តិចតួច និងការកាត់ទោសពីភាគីនៃអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ រហូតដល់ច្រើនទសវត្សរ៍ចុងក្រោយ ។ ខណៈដែលស្ថានភាពនេះបង្ហាញភ័ស្តុតាងនៃគម្លាតរវាងច្បាប់ និងការពិតអស់រយៈពេលជាច្រើនទសវត្សរ៍ ចាប់ពីទសវត្សរ៍៨០ ត្រូវបានហ៊ុមពទ្ធ័ដោយគំរូនៃការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ប៉ុន្តែការកាត់ទោសមិនបានសំរេចឡើងនោះទេ ។ ប្រទេសរ៉្វាន់ដា អតីតប្រទេសយូហ្គូស្លាវី ដាហ៊្វ័រ និងតំបន់ដទៃជាច្រើនក្នុងសកលលោក បង្ហាញពីគម្លាតយ៉ាងធំរវាងច្បាប់អន្តរជាតិ និងការពិតនៃនយោបាយ ។

នៅខែមករា ឆ្នាំ២០១២ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន បានប្រកាសថា ឆ្នាំ២០១២ នឹងជាឆ្នាំនៃការទប់ស្កាត់ ។ លោកបានប្រកាសថា ការជ្រើសរើសនេះដើម្បីព្រមព្រៀងឲ្យមានការយកចិត្តទុកដាក់ជាពិសេស ចំពោះការទប់ស្កាត់ដែលជាមាគ៌ាដំបូងក្នុងការការពារប្រឆាំងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ការបោសសម្អាតពូជសាសន៍ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ប៉ុន្តែថ្មីៗនេះនៅខែកញ្ញា ឆ្នាំ២០១២ អគ្គលេខាធិការអង្គការសហប្រជាជាតិបានថ្លែងថា លោកត្រូវបានញាំញីដោយការភ័យខ្លាចដែលសហគមន៍អន្តរជាតិមិនបានគោរពតាមការសន្យាដែលថា«មិនឲ្យកើតឡើងសាជាថ្មី» ។

ទោះបីជាយ៉ាងនេះក៏ដោយ ក្នុងការក្រើនរំឭកសិទ្ធិមនុស្ស វាមានសារៈសំខាន់ដើម្បីគូសបញ្ជាក់ថា ការពិតនៃនយោបាយ គឺមិនមែនជាការដោះសារចំពោះសិទ្ធិជាមូលដ្ឋានក្នុងការរស់រានមានជីវិត ។ អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ គឺជាគោលដ៏សំខាន់សម្រាប់សិទ្ធិនេះ ពីព្រោះអនុសញ្ញានេះបានភ្ជាប់កាតព្វកិច្ចទៅនឹងការទប់ស្កាត់ និងការដាក់ទោសទណ្ឌលើការរំលោភសិទ្ធិធ្ងន់ធ្ងរ ។ ប៉ុន្តែប្រហែលជាហាសិបឆ្នាំក្រោយមក ការរំលោភសិទ្ធិធ្ងន់ធ្ងរនៅតែបន្ត ហើយកម្ពុជាមានកាតព្វកិច្ចយ៉ាងសំខាន់ក្នុង

ការក្រើនរំឭកសកលលោកអំពីកង្វះខាតនេះ ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបង្កើតទិដ្ឋភាពថ្មីមួយសម្រាប់អរិយធម៌មនុស្សជាតិ ហើយជាសសរស្តម្ភរបស់ចលនាសិទ្ធិមនុស្ស ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនេះ សមតែជាចំណុចស្នូលនៃថ្ងៃប្រារព្ធសិទ្ធិមនុស្សជាសកល ។

ទោះបីជាយ៉ាងនេះក្តី ថ្ងៃនោះគឺជាថ្ងៃដ៏សមស្របសម្រាប់កម្ពុជាក្នុងការក្រើនរំលឹកសកលលោកឲ្យត្រឡប់មើលអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ ដែលជាការក្រើនរំលឹកដល់សិទ្ធិជាមូលដ្ឋានក្នុងការរស់រានមានជីវិត ដែលបញ្ជាក់ពីស្មារតីនៃចលនាសិទ្ធិមនុស្សដែលជាស្មារតីមួយបន្តពុះពារការពារសកលលោកនាពេលបច្ចុប្បន្ន ។

**ឆាំង យុ**

◆ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ។ សេចក្តីប្រកាសនេះ ត្រូវបានអនុម័តដោយមហាសន្និបាតដោយសំឡេងឆ្នោតគាំទ្រ៤៨សំឡេង សូន្យសំឡេង ប្រឆាំង និង៨សំឡេងអនុប្បវាទ ។ សេចក្តីប្រកាសនេះគឺជាសេចក្តីប្រកាសមួយដែលគ្មានការបង្ខំឲ្យសម្រេចតាមរយៈការបង្រៀន ការអប់រំ និងវិធានការជឿនលឿន ដើម្បីលើកស្ទួយការគោរព និងការការពារសិទ្ធិ និងសេរីភាព ។

◆ សេចក្តីប្រកាសជាសកល បញ្ចូលគោលការណ៍គន្លឹះមួយចំនួនដែលបានបង្កើតជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ជាគោលការណ៍ ដែលត្រូវបានដាក់បញ្ចូលក្នុងសន្ធិសញ្ញាជាបន្តបន្ទាប់) ។

◆ មាត្រា៣ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា “មនុស្សគ្រប់រូបមានសិទ្ធិក្នុងការរស់រានមានជីវិត សិទ្ធិមានសេរីភាព និងសិទ្ធិមានសន្តិសុខបុគ្គល” ។

◆ អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ ត្រូវបានពិពណ៌នាថាជា “សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សសម័យទំនើបដំបូង” ដោយអ្នកសិក្សាស្រាវជ្រាវផ្នែកពីបទប្រល័យពូជសាសន៍ម្នាក់ នៅពេលដែលអនុសញ្ញានោះត្រូវបានអនុម័តមួយថ្ងៃមុនសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨) ។ អនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍នេះ បានចូលជាធរមាននៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១ បន្ទាប់ពីទទួលបានការផ្តល់សច្ចាប័នចំនួនម្ភៃ (តាមការតម្រូវរបស់មាត្រា១៣) ។

◆ ប្រទេសសមាជិកនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ដូចខាងក្រោម ៖ ប្រទេសបារាំង(១៩៥០), សហភាពសូវៀត(១៩៥៤), ចក្រភពអង់គ្លេស(១៩៧០), ចិន(១៩៨៣) និងសហរដ្ឋអាមេរិក(១៩៨៨) ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០ ។

◆ តុលាការយុត្តិធម៌អន្តរជាតិបានថ្លែងថា រដ្ឋមានកាតព្វកិច្ចក្នុងការអនុវត្តឲ្យបានខ្ជាប់ខ្ជួនចំពោះការទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងទឹកដីរបស់ខ្លួន ។ តុលាការនោះបានចែងផងដែរថា “កាតព្វកិច្ចរបស់រដ្ឋដើម្បីទប់ស្កាត់ធ្វើឡើងភ្លាមៗ ពេលដែលរដ្ឋនោះដឹង ឬគួរតែបានដឹងអំពីការកើតឡើងនៃហានិភ័យដែលអំពើប្រល័យពូជសាសន៍ និងត្រូវបានប្រព្រឹត្ត” ។

◆ ខែមករា ឆ្នាំ២០១២ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន បានជ្រើសរើសឆ្នាំ២០១២ ជាឆ្នាំនៃការទប់ស្កាត់ដោយយោងតាមការយកចិត្តទុកដាក់ ជាពិសេសក្នុងការទប់ស្កាត់ដែលជាមាគ៌ាដំបូងដើម្បីការពារប្រឆាំងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ការបោសសម្អាតពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ លោកបានថ្លែងថា “ការទប់ស្កាត់គឺជាចំណុចស្នូលនៃការទទួលខុសត្រូវក្នុងការការពារ” ។ ក្នុងសេចក្តីថ្លែងការណ៍ចុងក្រោយ នៅខែកញ្ញា ឆ្នាំ២០១២ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានថ្លែងថា លោកត្រូវបានញាំញីដោយការភ័យខ្លាចដែលសហគមន៍អន្តរជាតិមិនបានធ្វើតាមការសន្យាដែលថា “មិនឲ្យកើតឡើងសាជាថ្មី” ។

# ដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្ររបស់ប្រធានាធិបតីសហរដ្ឋអាមេរិក

ដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា មកកាន់ប្រទេសកម្ពុជានៅខែវិច្ឆិកានេះ គឺជាទស្សនកិច្ចដំបូងបង្អស់របស់ថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៃសហរដ្ឋអាមេរិក ។ លោកអនុប្រធានាធិបតី រីឆាត និកសុន បានធ្វើដំណើរមកប្រទេសកម្ពុជាក្នុងឆ្នាំ១៩៥៣ ។ អតីតស្ត្រីទីមួយនៃសហរដ្ឋអាមេរិក ហ្សាក់គីលីន កេណ្ណឌី បានមកប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៦៧ និងត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសម្តេចព្រះនរោត្តម សីហនុ ។ អតីតប្រធានាធិបតី ប៊ីល គ្លីនតុន បានមកប្រទេសកម្ពុជាក្នុងឆ្នាំ២០០៦ និងថ្មីៗកន្លងទៅនេះ លោកស្រីរដ្ឋមន្ត្រីក្រសួងការបរទេស ហ៊ីលឡារី គ្លីនតុន ក៏បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០១០និងក្រោយមកក្នុងឆ្នាំ២០១២ ។

ដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា មិនមែនគ្រាន់តែជាលើកដំបូងប៉ុណ្ណោះទេ ប៉ុន្តែគឺជាដំណើរទស្សនកិច្ចដ៏ពិសេសមួយដោយសារតែលោកធ្លាប់បានផ្សារភ្ជាប់ជីវិតរបស់ខ្លួនដ៏សាមញ្ញកាលពីកុមារភាពនៅក្នុងប្រទេសឥណ្ឌូណេស៊ី ដែលជាប្រទេសមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ទោះបីជាលោកមិនធ្លាប់រស់នៅក្នុងប្រទេសកម្ពុជាក៏ដោយ តើនរណាម្នាក់អាចនឹងដឹងទៅថា លោកប្រធានាធិបតីម្នាក់នេះធ្លាប់មានជីវិតផ្ទាល់ខ្លួនភ្ជាប់ទៅនឹងតំបន់អាស៊ីអាគ្នេយ៍នេះ?

ខ្ញុំចាំបាន នៅពេលដែលខ្ញុំកំពុងតែសិក្សានៅសកលវិទ្យាល័យរ៉ាត់ហ្គើស សហរដ្ឋអាមេរិក ក្រោមអាហារូបករណ៍ហ្វុលប្រាយ ដែលពេលនោះ លោក បារ៉ាក់ អូបាម៉ា កំពុងតែមមាញឹកចូលរួមការប្រកួតប្រជែងដើម្បីដណ្តើមតួនាទីជាបេក្ខភាពប្រធានាធិបតីមកពីគណបក្សប្រជាធិបតេយ្យ ។ ក្រោយមក លោកក៏បានឈ្នះជា



លោក បារ៉ាក់ អូបាម៉ា ត្រូវបានទទួលស្វាគមន៍ដោយឯកឧត្តម អ៊ឹម សិទ្ធី នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញក្រោយពីយន្តហោះ Air Force One ចុះចតកាលពីល្ងាចថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ ។ រូបថតៈ AP

បេក្ខភាពប្រធានាធិបតីដើម្បីមកប្រកួតប្រជែងជាមួយគូបដិបក្ខមកពីគណបក្សសាធារណរដ្ឋគឺលោកព្រឹទ្ធសមាជិក ចន ម៉ាខេន ដែលនឹងត្រូវចូលរួមក្នុងការប្រកួតប្រជែងការបោះឆ្នោតក្នុងឆ្នាំ២០០៨ ។ បរិយាកាសជុំវិញការឡើងកាន់អំណាចជាប្រធានាធិបតីរបស់លោក បារ៉ាក់ អូបាម៉ា និងសេចក្តីសង្ឃឹមសម្រាប់ការផ្លាស់ប្តូរស្ថានភាពនយោបាយ នៅក្នុងសហរដ្ឋអាមេរិកមានលក្ខណៈពិសេសខ្លាំងក្លានិងហួសពីការស្មានទាពេលនោះ ។

គូប្រជែងរបស់លោក បារ៉ាក់ អូបាម៉ា មានឱកាសតិចតួចណាស់ក្នុងការយកឈ្នះមកលើរូបលោក ។ លទ្ធភាពដែលលោក បារ៉ាក់ អូបាម៉ា អាចឈ្នះឆ្នោតគឺសឹងតែមួយរយភាគរយទៅហើយ ។ ប៉ុន្តែលទ្ធផលនៃការបោះឆ្នោតលើកទីពីរនេះ លទ្ធភាពនៃការឈ្នះរបស់លោក បារ៉ាក់ អូបាម៉ា មិនសូវច្រើនដូចមុនទេ ទោះបីជាលោកបានឈ្នះឆ្នោតក្នុងអាណត្តិទីពីរនេះទៀតក៏ដោយ ។ ពលរដ្ឋសហរដ្ឋអាមេរិកខ្លះត្អូញត្អែរថា ក្នុងអាណត្តិទីមួយ ប្រធានាធិបតី បារ៉ាក់ អូបាម៉ា មិនបានប្រើគោលនយោបាយបង្រួបបង្រួមដើម្បីផ្សះផ្សានយោបាយក្នុងនាមជាប្រធានាធិបតីទេ ។ លោកហាក់បីដូចជា ធ្វើឲ្យមានការបែកបាក់គ្នាជាងមុនពេលដែលលោកចូលកាន់ដំណែងជាប្រធានាធិបតីក្នុងឆ្នាំ២០០៨ទៅទៀត ។ ក្នុងអាណត្តិនេះលោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា ប្រហែលជាបានរៀនសូត្រនូវកំហុសរបស់ខ្លួនយ៉ាងច្បាស់លាស់ ហើយនៅពេលដែលដឹងថាអាណត្តិនេះគឺជាអាណត្តិចុងក្រោយ បារ៉ាក់ អូបាម៉ា និងបង្ហាញឲ្យឃើញយ៉ាងពិតប្រាកដនូវសក្តានុពលរបស់ខ្លួនជាថ្នាក់ដឹកនាំដ៏ល្អប្រសើរសម្រាប់ប្រជាជនភាគច្រើនដែលកំពុងតែត្រូវការឲ្យលោកជួយមិនមែនត្រឹមតែនៅក្នុងសហរដ្ឋអាមេរិកទេ ថែមទាំងនៅក្នុងប្រទេសផ្សេងទៀត ក៏ដូចជាប្រទេសកម្ពុជាដែរ ។

ឪពុករបស់លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា មានស្រុកកំណើតនៅប្រទេសកេនយ៉ា ។ ម្តាយរបស់លោកគឺជាជនជាតិអាមេរិកកាំងស្បែកសមកពីរដ្ឋកាន់សាស់ ។ ចំណែកឯឪពុកចុងរបស់លោកគឺជាជនជាតិឥណ្ឌូណេស៊ី ហើយលោក បារ៉ាក់ អូបាម៉ាត្រូវបានចិញ្ចឹមបីបាច់នៅក្នុងគ្រួសារស្បែកស ។ លោក បារ៉ាក់ អូបាម៉ាមានចំណុចជាច្រើនដែលប្រជាជនទូទៅចូលចិត្ត និងគិតថាស្រដៀងនិងមនុស្សទូទៅ ។ នៅពេលដែលធ្វើជាប្រធានាធិបតីដំបូងក្នុងឆ្នាំ ២០០៨ លោក បារ៉ាក់ អូបាម៉ា មានអាយុ៤៧ឆ្នាំ ដែលជាប្រធានាធិបតីវ័យក្មេងមួយរូបក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក ។

ការឡើងកាន់អំណាចជាប្រធានាធិបតីរបស់លោក បារ៉ាក់ អូបាម៉ា បានចាប់ផ្តើមពីឋានៈសង្គមតូចទាប ។ ដូចលោកបានសរសេរនៅក្នុងសៀវភៅប្រវត្តិរូបផ្ទាល់ខ្លួនទីមួយរបស់លោកដែលមានចំណងជើងថា "សុបិនរបស់ឪពុកខ្ញុំ" ម្តាយរបស់លោក បារ៉ាក់ អូបាម៉ា ឈ្មោះ អានដាន់ហេន និងឪពុកឈ្មោះ បារ៉ាក់ អូបាម៉ា មិនគួរនឹងបានជួបគ្នាទាល់តែសោះដោយសារតែស្ថានភាពប្រកាន់ពូជសាសន៍ធ្ងន់ធ្ងរនៅក្នុងសហរដ្ឋអាមេរិកនៅពេលនោះ ។ ជាភ័ព្វសំណាងល្អ រដ្ឋហាវ៉ៃគឺជាកន្លែងមួយរបស់សហរដ្ឋអាមេរិកដែលមានលក្ខណៈបើកទូលាយពាក់ព័ន្ធនឹងការរស់នៅចម្រុះពូជសាសន៍ ។ លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា បាននិយាយថា លោកនៅតែពុំយល់អំពីសេចក្តីសម្រេចចិត្តរបស់ជីដូននិងជីតាខាងម្តាយដែលអនុញ្ញាតឲ្យកូនស្រីអាយុ១៨ឆ្នាំរបស់ខ្លួនទៅរៀបការជាមួយនឹងបុរសស្បែកខ្មៅអាយុ២៣ឆ្នាំមកពីប្រទេសកេនយ៉ា ។ នៅពេលនោះ សហរដ្ឋអាមេរិកពុំគាំទ្រការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិស្បែកខ្មៅនិងជនជាតិស្បែកសទេ ។ បើប្រៀបធៀបទៅនឹងប្រទេសកម្ពុជា វាមានលក្ខណៈស្រដៀងគ្នាទៅការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិចិននិងជនជាតិចាម ប៉ុន្តែករណីនេះនៅតែមានលក្ខណៈស្រាលជាងការរៀបការរបស់ឪពុកម្តាយលោក បារ៉ាក់ អូបាម៉ា ។ ឪពុកម្តាយរបស់លោកនៅតែតស៊ូរៀបការនិងរស់នៅជាមួយគ្នារហូតបានកូនប្រុសម្នាក់ដែលដាក់ឈ្មោះថា បារ៉ាក់ អូបាម៉ា ។ អ្នកទាំងពីរប្រហែលជាមិនបានដឹងថា កូនប្រុសម្នាក់នេះ នៅពេលដែលបានដឹងក្តីនឹងក្លាយជាប្រធានាធិបតីសហរដ្ឋអាមេរិកនោះឡើយ ។ ប្រហែលជាដោយសារតែសម្ពាធផ្នែកពូជសាសន៍បានជាឪពុកម្តាយរបស់លោកលែងលះគ្នា ។ ក្រោយមកម្តាយរបស់លោកបានបន្តការសិក្សានៅសកលវិទ្យាល័យវ៉ាស៊ីនតោន ចំណែកឯឪពុករបស់លោកទទួលបានអាហារូបករណ៍ទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅសកលវិទ្យាល័យហាវើដក្នុងឆ្នាំ១៩៦៣ ហើយក្រោយមកបានវិលត្រឡប់ទៅប្រទេសកេនយ៉ាក្នុងឆ្នាំ ១៩៦៤ ។ ឪពុករបស់លោក បារ៉ាក់ អូបាម៉ា បានមកលេងរូបលោកតែម្តងគត់ក្នុងឆ្នាំ១៩៧១ ហើយប្រាំបួនឆ្នាំក្រោយមក ឪពុក

របស់លោកក៏បានស្លាប់ដោយគ្រោះថ្នាក់រថយន្ត ។ ម្តាយរបស់លោកបានស្លាប់ក្នុងឆ្នាំ១៩៩៥ ដោយជំងឺមហារីក ។

លោក បារ៉ាក់ អូបាម៉ា មិនដែលដឹងពីចរិត ឬកពាពិតប្រាកដរបស់ឪពុករបស់ខ្លួនទេ ។ អ្វីដែលលោកអាចចងចាំបានពីឪពុករបស់លោកគឺការធ្វើដំណើរដ៏វែងឆ្ងាយពីប្រទេសកេនយ៉ាមកកាន់សហរដ្ឋអាមេរិក ការដែលឪពុកម្តាយរបស់លោកសាងទំនាក់ទំនងស្នេហាជាមួយគ្នា និងការគិតរបស់អ្នកផ្សេងមកលើឪពុកម្តាយរបស់លោក ។ ឪពុករបស់លោកហាក់បីដូចជាមនុស្សដែលគ្មាននរណាដឹងពីចរិតលក្ខណៈសោះ ។ ក្រោយមក លោក បារ៉ាក់ អូបាម៉ា បានតាមរកដំណើរជីវិតឪពុករបស់លោក ហើយបានទៅកាន់ភូមិតូចមួយក្នុងប្រទេសកេនយ៉ាជាកន្លែងដែលឪពុករបស់លោកចាប់កំណើតឡើង ។ ដំណើរជីវិតរបស់លោក បារ៉ាក់ អូបាម៉ា ជារឿងដែលសឹងតែមិនអាចជឿបាន ។ លោកគឺជាឥស្សរជនមួយរូបដែលគួរកោតសរសើរនិងពឹងពាក់បាន ដោយសារតែអ្វីដែលលោកបានធ្វើនិងសម្រេចបានក្នុងរយៈពេលជាងដប់ឆ្នាំចុងក្រោយនិងដោយសារចរិតលក្ខណៈរបស់លោកដែលជាមនុស្សមិនចេះអួតអាង និងជាមនុស្សដែលយល់ពីសេចក្តីត្រូវការរបស់មនុស្សក្រីក្រ និងអ្នកដែលមានឋានៈសង្គមទាប ។

ដូច្នេះ តើដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា មានអត្ថន័យយ៉ាងណាចំពោះប្រជាជនកម្ពុជា? តើប្រជាជនកម្ពុជារំពឹងអ្វីខ្លះពីលោក? ការធ្វើប្រជាមតិបានបង្ហាញថា ប្រជាជនកម្ពុជាជាច្រើនមានទំនោរពេញចិត្តទៅខាងសហរដ្ឋអាមេរិក ហើយភាគច្រើនចង់ទៅរស់នៅសហរដ្ឋអាមេរិក ។ ខ្ញុំជឿថា ប្រជាជនកម្ពុជាយល់ថា សហរដ្ឋអាមេរិកគឺជាទឹកដីដែលផ្តល់នូវឱកាសសេរីភាពនិងការរីកចម្រើនដូចអ្វីដែលប្រជាជនកម្ពុជាបានឃើញជនជាតិខ្មែរ-អាមេរិកាំង ដែលភាគច្រើនបានទៅរស់នៅក្នុងអំឡុងនិងក្រោយរបបខ្មែរក្រហមបានបង្ហាញពេលដែលអ្នកទាំងនោះមកលេងប្រទេសកម្ពុជាម្តងៗ ។

ប្រជាជនកម្ពុជាដឹងថា សហរដ្ឋអាមេរិកគឺជាប្រទេសមួយដែលមានសេដ្ឋកិច្ចរីកចម្រើន និងមានអំណាចយោធាយ៉ាងអស្ចារ្យ ។ ប្រជាជនកម្ពុជាបានឃើញតាមកញ្ចក់ទូរទស្សន៍ជាលើកដំបូងតាមរយៈសង្គ្រាមឈូងសមុទ្រពែរ្សក្នុងឆ្នាំ១៩៩១ ដែលយោធាសហរដ្ឋអាមេរិកបានកម្ទេចទាហានអ៊ីរ៉ាក់បានដោយងាយ ។ ប្រជាជនកម្ពុជាបានមើលឃើញម្តងទៀតនៅពេលដែលសហរដ្ឋអាមេរិកបានវាយប្រហារក្រុមតាលីបង់ក្នុងប្រទេសអាហ្គានីស្ថានក្នុងឆ្នាំ២០០១ ដែលជាការសងសឹកដល់ប្រទេសនេះ ដែលបានគាំទ្រកំពូលភេរវករ អូសាម៉ា ប៊ីនឡាដេន ហើយបន្តមកទៀត ក្នុងអំឡុងពេលប្រតិបត្តិការយោធាក្នុងប្រទេសអ៊ីរ៉ាក់ក្នុងឆ្នាំ២០០៣ ។

ការទម្លាក់គ្រាប់បែកកាលពីទសវត្សរ៍៦០និង៧០ បានធ្វើឲ្យប្រជាជនកម្ពុជាភ័យខ្លាច ។ ស្ថាប័នមនុស្សធម៌របស់សហរដ្ឋអាមេរិកជាច្រើន ជាពិសេស ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិកបានធ្វើការយ៉ាងច្រើនដើម្បីជួយប្រជាជនកម្ពុជាលើកកម្ពស់ជីវភាពរស់នៅតាមរយៈបណ្តាញសង្គមស៊ីវិលជាច្រើន ហើយកិច្ចខិតខំប្រឹងប្រែងនេះបានជួយប្រជាជនកម្ពុជាជាច្រើន ។ ប៉ុន្តែប្រជាជនកម្ពុជាត្រូវការជំនួយជាច្រើនទៀត ។ ប្រជាជនកម្ពុជាមិនអាចនៅដាច់ឆ្ងាយពីគេឯងទៀតទេ ដោយសារតែពេលនេះ ពិភពលោកកំពុងតែឈានទៅរកសហគមន៍សកលហើយ ។ សហរដ្ឋអាមេរិក បានអនុវត្តនូវគោលនយោបាយមួយដែលមិនផ្តល់ជំនួយដោយផ្ទាល់ទៅកាន់ស្ថាប័នរដ្ឋាភិបាលកម្ពុជា ដោយសារតែសហរដ្ឋអាមេរិកគិតថាប្រទេសកម្ពុជាមានបញ្ហាជាច្រើនទាក់ទងទៅនឹងការគោរពសិទ្ធិមនុស្ស សិទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។ ឥឡូវនេះ ប្រទេសទាំងពីរបានបង្កើតនូវចំណងការទូតដល់កម្រិតថ្មីមួយ ។ ដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា បង្ហាញឲ្យឃើញនូវចំណងការទូតនិងទំនាក់ទំនងថ្មីមួយនិងប្រសើរជាងមុន ។ ខ្ញុំសង្ឃឹមថាដំណើរទស្សនកិច្ចនេះនឹងជំរុញឲ្យមានគំនិតថ្មីៗពីរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋអាមេរិកដើម្បីឲ្យមានការរីកចម្រើនខាងការគោរពសិទ្ធិមនុស្ស ការជំរុញឲ្យមានប្រជាធិបតេយ្យកាន់តែទូលំទូលាយ និងនីតិរដ្ឋប្រសើរជាងមុន ។ ក៏ប៉ុន្តែរាល់ការអភិវឌ្ឍន៍សង្គមកម្ពុជាទាំងអស់គឺពឹងផ្អែកទាំងស្រុងទៅលើប្រជាជនកម្ពុជាខ្លួនឯង ។ **អេង កុកថាយ**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ចម្លើយសារភាពរបស់ ព្រាំ សុធា ប្រពន្ធរបស់ ស៊ាត ឆែ ហៅ ទុំ លេខាតំបន់២២

**ដកស្រង់ចេញពីឯកសារ J00៨៩៤**

ព្រាំ សុធា អាយុ៤១ឆ្នាំ កើតនៅភូមិព្រែកផ្ដៅ សង្កាត់កោះរះ ស្រុកល្វាឯម តំបន់២២ ភូមិភាគបូព៌ា ។ សុធា មាននាទីជាប្រធានសិប្បកម្មតម្បាញរបស់ស្រុក១៥៤ (ស្រុកកណ្ដាលស្ទឹង) តំបន់២៥ និងជាប្រពន្ធរបស់ ស៊ាត ឆែ ហៅ ទុំ នាទីលេខាតំបន់២២ ។ នៅក្នុងឯកសារចម្លើយសារភាពដែលបានចម្លងជាអង្គុលីលេខឡើងវិញមានកម្រាស់សែសិបពីរទំព័រ បានបញ្ជាក់ឲ្យដឹងថា ព្រាំ សុធា បានចូលធ្វើកិញសេ.អ៊ី.អា នៅឆ្នាំ១៩៥៧ ដោយមានសកម្មភាពតាមដានអ្នកកាសែត និងបានសម្លាប់អ្នកកាសែតអស់ម្ពនាក់ បំផុសប្រជាជនសិស្សនៅសាលាកម្ពុជបុត្រឲ្យស្អប់ខ្មែរក្រហម ។ នៅឆ្នាំ១៩៧០ សុធា មានទំនាក់ទំនងជាមួយខៀវ ហ៊ូយន់ និង ទីវ អុល ដោយបំផុសប្រជាជនឲ្យជួយឧបត្ថម្ភវៀតណាម ឃោសនាប្រជាជនកុំឲ្យចូលធ្វើបដិវត្តន៍ឲ្យចូលធ្វើទ័ពវៀតណាមនៅក្នុងតំបន់២២ ។ ឆ្នាំ១៩៧៥ សុធា បានទៅតំបន់២៥ ដោយមានសកម្មភាពបំផ្លាញផលដំណាំសម្ភាររហូតដល់អង្គការចាប់ខ្លួននៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។

ចម្លើយសារភាពរបស់ សុធា ធ្វើនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៨ ដែលមានឈ្មោះ អុន ជាអ្នកសួរចម្លើយ ហើយត្រូវបានចម្លងជាអង្គុលីលេខឡើងវិញនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៨ ដោយសមមិត្ត ហួយ ។ ខាងក្រោមនេះគឺជាអត្ថបទដកស្រង់ចេញពីឯកសារចម្លើយសារភាពរបស់ ព្រាំ សុធា ។

## សកម្មភាពក្បត់បក្សមុនថ្ងៃរំដោះ

ខ្ញុំនៅជាមួយឪពុកម្ដាយរហូតដល់ឆ្នាំ១៩៥៤ ក្រោយមកខ្ញុំបានមកនៅរៀនកាត់ដេរនៅភ្នំពេញ ជាមួយបងជីដូនមួយឈ្មោះ លី នៅកាត់ដេរ ។ នៅជាមួយបងខ្ញុំរហូត និងមានការទាក់ទងជាមួយ ងួន នៅកន្លែងកាត់ដេរនោះដែរ ខ្ញុំបានខូចសីលធម៌ជាមួយគ្នាជាញឹកញាប់ ។ ក្រោយមកបងខ្ញុំបានដេញ ងួន ចោល ។ បន្ទាប់មកទៀត ខ្ញុំមានការទាក់ទងជាមួយឈ្មោះ គុច និង ហេង នៅស៊ីឈ្នួលលក់ក្រណាត់ឲ្យចិន ព្រមទាំងបានខូចសីលធម៌ជាមួយគ្នាពីរបីដងដែរ ។

ឆ្នាំ១៩៥៥ ខ្ញុំមានការទាក់ទងជាមួយឈ្មោះ ទុំ ហើយខ្ញុំក៏យកគ្នាជាប្ដីប្រពន្ធរហូតមក ។ ឆ្នាំ១៩៥៦ ខ្ញុំបានស្គាល់ ម៉ែន សាន ព្រោះឈ្មោះនេះមកទាក់ទងជាមួយប្ដីខ្ញុំ និងបានអប់រំខ្ញុំពីវៀតណាមមានគុណបំណាច់លើយើង ហើយលើកពីបក្សវៀតណាមល្អ មិនដូចបក្សខ្មែរទេ ។ ក្រោយមក ប្ដីខ្ញុំទៅវៀតណាមខាងជើង តែអត់ទៅដល់ទេដល់ត្រឹមកំពង់ផែ ត្រូវ ម៉ែន សាន ហៅមកវិញ ។

ឆ្នាំ១៩៥៦ ខ្ញុំបានស្គាល់ឈ្មោះ កែវ មាស ដែលមកស្នាក់នៅផ្ទះរបស់ខ្ញុំ ហើយអប់រំខ្ញុំ លើកពីបញ្ហាយួនមានគុណបំណាច់លើយើងច្រើនណាស់ និងបានណែនាំខ្ញុំឲ្យអប់រំយុវជន យុវនារីឲ្យយល់ជ្រួតជ្រាបអំពីបញ្ហាវៀតណាម ដើម្បីពង្រឹងកម្លាំងនៅក្នុងប្រទេសរបស់យើង ។

ឆ្នាំ១៩៥៧ ខ្ញុំមានការទាក់ទងជាមួយឈ្មោះ សារិន ជាចាងហ្វាងកាសែតមិត្តភាព និងឈ្មោះ ហេង ជាគ្រូបង្រៀនសាលាចំរើនវិជ្ជា ដែលចេញចូលទាក់ទងញឹកញាប់ជាមួយប្ដីខ្ញុំ ។ អ្នកទាំងពីរនិយាយប្រាប់ខ្ញុំពីរឿងដែលគាត់ទាក់ទងជាមួយកិញនៅក្រសួងកិញឲ្យចាប់អ្នកកាសែតប្រជាជន ពេលនោះចាប់អ្នកកាសែតបានប្រហែល២០នាក់ ។

នៅឆ្នាំ១៩៥៧ដដែល ខ្ញុំមានភារកិច្ចតាមដានសិស្សបាចត្រាក់ ហើយរាយការណ៍ឲ្យឈ្មោះ សារិន និង ហេង ។ បន្ទាប់មកអ្នកទាំងពីរបានឲ្យខ្ញុំទៅទាក់ទងជាមួយកិញម្នាក់នៅចំការមនឈ្មោះ ស៊ុម ។ ខ្ញុំបានរាយការណ៍ប្រាប់ ស៊ុម ពីសកម្មភាពកូនសិស្សបាចត្រាក់ ហើយក្រោយពីរាយការណ៍មក ខ្ញុំឃើញទាហានចាប់សិស្សបានពីរនាក់មានឈ្មោះ ធន់ និង ណាំ ហុង ។

ឆ្នាំ១៩៥៨ សារិន និង ហេង បានឲ្យខ្ញុំទៅហៅគ្រូ សំបុក

បង្រៀននៅសាលាកម្ពុជបុត្រមកជួប ។ ពេលនោះខ្ញុំគ្រាន់តែដឹងថា អ្នកទាំងពីរបានអប់រំគ្រូ សំបុក ឲ្យបំផុសកសាងកម្លាំងសិស្សនៅក្នុងសាលាកម្ពុជបុត្រឲ្យប្រឆាំងនឹងបដិវត្តន៍ ។

ក្រោយមកទៀត សារិន និង ហេង បានអប់រំខ្ញុំឲ្យបំផុសយុទ្ធជន យុទ្ធនារី ឲ្យជ្រួលច្របល់ពីបញ្ហាស្រី ស្រា ហើយបំផ្លាញកម្មាភិបាលបដិវត្តន៍ គឺរកយុទ្ធវិធីធ្វើឲ្យបែកការណ៍ ដូចជា បង១ នៅសាលាចំរើនវិជ្ជា និងសាលាកម្ពុជបុត្រជាដើម ។

ឆ្នាំ១៩៥៩ ខ្ញុំឃើញកម្លាំងដែលមកធ្វើការនៅផ្ទះរបស់ខ្ញុំមានឈ្មោះ កែវ មាស, ម៉ែន សាន, ទីវ អុល, ហ៊ូ យន់, សារិន និង ហេង នៅពេលនោះខ្ញុំពុំដឹងប្រជុំរឿងអីទេ ព្រោះប្ដីខ្ញុំឲ្យខ្ញុំយាម និង ដាំបាយឲ្យអ្នកទាំងអស់នេះហូប ។

ឆ្នាំ១៩៦១ កែវ មាស និង ម៉ែន សាន អប់រំខ្ញុំថា យើងធ្វើបដិវត្តន៍តែរូបភាពគឺយើងប្រឆាំងចក្រពត្តិ តែថ្ងៃក្រោយយើងទាក់ទងជាមួយចក្រពត្តិអាមេរិក និងវៀតណាម យើងគ្រាន់តែលាក់ការណ៍ កុំឲ្យបែកការណ៍ ហើយយើងត្រូវបង្កប់ខ្លួនស៊ីរូងផ្ទៃក្នុង ។ ក្រោយមក កែវ មាស និង ម៉ែន សាន បានអប់រំបញ្ចូលខ្ញុំជា សេ.អ៊ី.អា ។ អ្នកខ្ទេសនាម ម៉ែន សាន, អ្នកទទួលស្គាល់ កែវ មាស សមាជិកចូលរួមមាន សារិន, ហេង និងគ្រួសារខ្ញុំ ។

ពេលនោះគ្មានពិធីអ្វីទេ កែវ មាស ណែនាំខ្ញុំពីភារកិច្ច សេ.អ៊ី.អា តែម្ដងគឺ ៖

១) អប់រំអូសទាញកម្លាំង យុទ្ធជន យុទ្ធនារី ឲ្យវក់វីពីបញ្ហាស្រី ស្រា កុំឲ្យមើលឃើញពីការតស៊ូ និងអូសទាញកម្មាភិបាលកុំឲ្យគិតពីប្រទេសជាតិ ។

២) ណែនាំឲ្យបង្កប់ខ្លួនស៊ីរូងផ្ទៃក្នុងបដិវត្តន៍ ដើម្បីកសាងកម្លាំង និងបំផ្លាញបដិវត្តន៍យូរអង្វែង ។

៣) ណែនាំខ្ញុំឲ្យប្ដេជ្ញាចិត្តបម្រើនូវភារកិច្ច សេ.អ៊ី.អា នេះឲ្យបាន និងរក្សាការសម្ងាត់ឲ្យបានដាច់ខាត ។

នៅក្នុងឆ្នាំដដែល កែវ មាស និង សារិន មកស្នាក់នៅផ្ទះខ្ញុំ ហើយបានខូចសីលធម៌ជាមួយគ្នាជាញឹកញាប់ ពេលដែលគ្រួសារខ្ញុំគាត់ទៅធ្វើការ ។

នៅឆ្នាំ១៩៦២ គ្រួសារខ្ញុំបានប្រាប់ខ្ញុំពីកម្លាំង សេ.អ៊ី.អា ដែលទាក់ទងជាមួយគាត់មាន ហ៊ូ យន់ និង ទីវ អុល ។ អ្នកទាំងពីរបានអប់រំខ្ញុំឲ្យធ្វើសកម្មភាពបំផុសកសាងកម្លាំងយុទ្ធជន យុទ្ធនារីធ្វើជាកម្លាំង សេ.អ៊ី.អា សម្រាប់បង្កប់ ហើយប្រឆាំងជាមួយបដិវត្តន៍បានយូរអង្វែង ។ បន្ទាប់មក កែវ មាស បាត់ដំណឹងមិនដែលឃើញមកផ្ទះខ្ញុំតាំងពីឆ្នាំ១៩៦២ រហូតមក ។

ឆ្នាំ១៩៦៣ ម៉ែន សាន លែងឃើញឡើងចុះផ្ទះខ្ញុំរហូតមក ។ ខ្ញុំ, សារិន និង ហេង បានទាក់ទងជាមួយ អាង និង សារឿន ។ សារិន បានអប់រំ អាង និង សារឿន ឲ្យធ្វើសកម្មភាពនៅក្នុងសាលាបន្តទៀត ដោយឲ្យអូសទាញយុទ្ធជន យុទ្ធនារី នៅក្នុងសាលាដើម្បីកសាងធ្វើជាកម្លាំងសេ.អ៊ី.អា ។ សកម្មភាពរបស់ អាង កសាងកម្លាំងបានម្នាក់ ឈ្មោះនារី ផល្លា កូនសិស្សសាលាចំរើនវិជ្ជា ។

ឈ្មោះទាំងអស់នេះ ខ្ញុំបានទាក់ទងធ្វើសកម្មភាពជាមួយរហូតមក ។ នៅឆ្នាំដដែល គ្រួសារខ្ញុំណែនាំខ្ញុំនៅតែផ្ទះទេ គឺឲ្យខ្ញុំនៅយាមផ្ទះ ។ សារិន និង ហេង ចេញទៅជនបទ គឺគ្រួសារខ្ញុំផ្ទាល់ណែនាំឲ្យខ្ញុំនៅរក្សាការសម្ងាត់ពីការដែលគាត់ដើរធ្វើការទាក់ទងកន្លែងផ្សេងៗក្ដី ហើយគាត់អប់រំខ្ញុំឲ្យធ្វើការឃោសនា យុទ្ធជន យុទ្ធនារី ពីការសប្បាយ ពាលា ស្រី ស្រា មិនឲ្យគិតគូរពីការធ្វើបដិវត្តន៍ ។

ចុងឆ្នាំ១៩៦៣ ខ្ញុំបានទាក់ទងជាមួយ អាង និង សារឿន ព្រមទាំងអប់រំពីរនាក់នេះឲ្យធ្វើសកម្មភាពកសាងកម្លាំងសិស្សនៅក្នុងសាលាចំរើនវិជ្ជា ។

ឆ្នាំ១៩៦៤ សភាពការណ៍ពេលនោះតឹងតែងតាមដាន ហើយនៅក្នុងខែសីហា គ្រួសារខ្ញុំត្រូវចេញទៅព្រៃ និងបានណែនាំខ្ញុំបន្តទៀតថា ត្រូវបង្កប់ខ្លួនឲ្យជ្រៅនៅក្នុងជួរបដិវត្តន៍ ពេលនោះគាត់ឲ្យខ្ញុំនៅចាំទាក់ទងជាមួយ ព្រំ គឹមវ៉ាន ដែលជាប្អូនរបស់ខ្ញុំគឺជា សេ.អ៊ី.អា ដែរ ដែលបានអប់រំកាលពីដើរធ្វើការជាមួយគាត់ ។

នៅចុងឆ្នាំ១៩៦៤ ខ្ញុំបានទាក់ទងជាមួយ ព្រំ គឹមវ៉ាន ហើយ គឹមវ៉ាន បានប្រាប់ពីកម្លាំង សេ.អ៊ី.អា ដែលទាក់ទងជាមួយគាត់ និងគ្រួសារខ្ញុំមាន ៖

- តឹក គឹមអុន គ្រូបង្រៀនសាលាចំរើនវិជ្ជា
- ធុច នៅខាងបុងតុងសាលាចំរើនវិជ្ជា

បន្ទាប់មកប្អូនខ្ញុំបានគេចខ្លួនបាត់ ។ ក្រោយមកខ្ញុំបានជួបជាមួយ ធុច និង តឹក គឹមអុន នៅឯភ្នំពេញ ។ មុនពេលដែលខ្ញុំចេញមកចម្ការ ធុច និង តឹក គឹមអុន បានអប់រំខ្ញុំថា ពេលទៅនៅចម្ការត្រូវ

ខ្ញុំអប់រំកសាងកម្លាំងបន្តខ្សែរយៈ ។ ពេលនោះខ្ញុំបានរាយការណ៍ប្រាប់ តឹក គឹមអុន និង ធុច ថាខ្ញុំអប់រំកសាង កម្លាំងបានពីរនាក់គឺ ឈ្មោះ ខេង និង មឿន នៅធ្វើទឹកត្រីលក់ នៅក្នុងឃុំកោះរះ ស្រុកល្វាឯម ។

ឆ្នាំ១៩៦៥ ខ្ញុំមកនៅជាមួយម្តាយខ្ញុំនៅឯភូមិព្រែកផ្តៅ សង្កាត់កោះរះ ពេលនោះខ្ញុំបានទាក់ទងជាមួយ ខេង និងមឿន និង អប់រំឲ្យធ្វើសកម្មភាពរហូត ។ នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំ ជាមួយនឹង ខេង និង មឿន នេះ បានខូចសីលធម៌ជាមួយគ្នាជាញឹកញាប់ ព្រោះពេលនោះម្តាយខ្ញុំជំពាក់លុយពីរនាក់នេះ ។ អ្នកទាំងពីរនាក់នេះជាគិញរបស់មេឃុំកោះរះ ឈ្មោះ ចំរើន ។ នៅឆ្នាំ១៩៦៧ ខេង និង មឿន បានសម្លាប់តាម្នាក់នៅក្នុងភូមិព្រែកជ្រូក ឈ្មោះ តាមួង ពេលដែលគាត់ដើរបំផុសយុវជន យុវនារីឲ្យក្រោកឡើងតស៊ូប្រឆាំងនឹងពួកចក្រពត្តិ ។ ឈ្មោះទាំងពីរនេះ នៅឆ្នាំ១៩៧០ បានចូលធ្វើកងទ័ពនៅក្នុងអគ្គភាពវៀតណាមហើយក៏បាត់ដំណឹងរហូត ។

ឆ្នាំ១៩៦៧ ខ្ញុំបានជួបជាមួយយុទ្ធជននីរសារបស់បងដាំផេង ដែលមកហៅខ្ញុំឲ្យទៅជួបជាមួយ ព្រាំ គឹមវ៉ាន នៅឯភ្នំពេញ ។ បងដាំផេង ជាប្តីរបស់ ព្រាំគឹមវ៉ាន ។ ក្រោយពីបងដាំផេង ចេញទៅធ្វើការបាត់ ខ្ញុំក៏បានជួបនិយាយជាមួយ គឹមវ៉ាន ពីខ្សែទាក់ទងជាមួយ ធុច និង តឹក គឹមអុន ។ ខ្ញុំសួរថា បានទាក់ទងឬទេ? ហើយប្រាប់ គឹមវ៉ាន ថាកម្លាំងទាក់ទងជាមួយ ខេង និង មឿន នេះ ប្អូនឯងយកទៅរាយការណ៍ឲ្យ ធុច និងតឹក គឹមអុន ផង ។ ព្រាំ គឹមវ៉ាន បានបញ្ជាក់ប្រាប់ខ្ញុំថា អ្នកទាំងនោះចេញទៅជនបទអស់ហើយ ។

ពេលដែលខ្ញុំត្រឡប់មកន្លែងវិញ ខ្ញុំបានទាក់ទងជាមួយ មេឃុំកោះរះ ឈ្មោះ ចំរើន ហើយគាត់បានអប់រំខ្ញុំឲ្យធ្វើគិញ និង ទាក់ទងជាមួយឈ្មោះ ខេង និង មឿន ឲ្យជាប់ ។ ក្រោយពីជួបគ្រួសារខ្ញុំមក ខ្ញុំបង្កប់ខ្លួននៅក្នុងជួរប្រជាជន ហើយមានការទាក់ទងជាមួយ មេឃុំកោះរះ ជាមួយនឹងខ្សែទាក់ទងមួយចំនួនទៀតមានៈ

- ◆ ណាន គ្រូបង្រៀននៅកោះរះ
- ◆ រុម ពេទ្យដើរតាមភូមិ
- ◆ ណាំ ពេទ្យដើរតាមភូមិ
- ◆ យុង ជំទប់ទី១
- ◆ ខេង អ្នកធ្វើទឹកត្រីដើរលក់
- ◆ មឿន អ្នកធ្វើទឹកត្រីលក់

ឈ្មោះទាំងនេះ មេឃុំប្រាប់ខ្ញុំឲ្យដឹងពីខ្សែគិញនៅក្នុងឃុំកោះរះនេះ ។ មេឃុំណែនាំឲ្យខ្ញុំធ្វើសកម្មភាពនៅក្នុងភូមិតាមដានប្រជាជនដែលបំផុសពីបញ្ហាខ្មែរក្រហមឲ្យរាយការណ៍ជូនមេឃុំភ្លាម ។ មេឃុំណែនាំទៀតថា ត្រូវតាមដានឲ្យជាប់ កុំឲ្យខ្មែរក្រហមដើរធ្វើការបាន ។ ក្រោយពីមេឃុំណែនាំ ខ្ញុំមកទាក់ទងជាមួយ ខេង និងមឿន នេះជាប់ សកម្មភាពរបស់ខ្ញុំតាមដានប្រជាជនក្នុងភូមិ ហើយដើរបំផុសប្រជាជនឲ្យយាមតាមភូមិដើម្បីកុំឲ្យខ្មែរក្រហមចូលធ្វើការនៅក្នុងភូមិបាន ។

ឆ្នាំ១៩៦៩ ខ្ញុំបានជួបជាមួយម្តាយ ខេង និង មឿន ហើយបានអប់រំអ្នកទាំងពីរឲ្យបង្កប់ខ្លួននៅក្នុងចំណោមប្រជាជននៅក្នុងឃុំកោះរះ ឲ្យជ្រៅ ហើយឲ្យ ខេង និងមឿន នេះទាក់ទងជាមួយមេឃុំ ចំរើន នេះជាប់ដើម្បីទាក់ទងពីការរកស៊ីលក់ទឹកត្រីផង និងដើរយកការណ៍ពីខ្មែរក្រហមនៅតាមភូមិ ឃុំ មករាយការណ៍ឲ្យមេឃុំ ចំរើន ផង គឺដើរពិនិត្យប្រជាជននៅតាមភូមិដែលបំផុសចលនាពីខ្មែរក្រហម ។ អ្នកទាំងពីរនៅធ្វើការជាមួយមេឃុំ ចំរើន នេះជាប់រហូតមក ហើយកម្លាំងដែលទាក់ទងមានៈ ណាន, ណាំ, យុង និង រុម ។

នៅឆ្នាំដដែល សកម្មភាពរបស់ខ្ញុំទាក់ទងជាមួយជំទប់ យុង រាយការណ៍ឲ្យមេឃុំចាប់ប្រជាជន នៅភូមិកោះរះ មានឈ្មោះ ប៊ិច ហៅ ឃឹម និង អ៊ិក ដោយចោទថា ខ្មែរក្រហម ។

ឆ្នាំ១៩៧០ ខ្ញុំណែនាំឈ្មោះ ខេង និង មឿន ឲ្យធ្វើសកម្មភាពបំផុសប្រជាជនឲ្យឃើញថា កម្លាំងខ្លាំងខ្លាំង ដើម្បីបំបាក់កម្លាំងស្នេហាជាតិ ឲ្យមើលឃើញថា បដិវត្តន៍នេះរេចរិលទៅៗគ្មានកម្លាំងតស៊ូ ។

ខែកក្កដា ឆ្នាំ១៩៧០ ខ្ញុំចេញទៅជនបទតាមរយៈគ្រួសារខ្ញុំ និងមាន មីងឡូត ជូនមកដល់ បារុង ស្មោកការ ហើយឃើញឈ្មោះ ញិល មកយកខ្ញុំទៅឲ្យឈ្មោះ ងិន នៅឃុំកំពង់ព្នៅ ។ ងិន បាននាំខ្ញុំមកភូមិស្កាស្រុក នៅឃុំព្នៅទី២ ។ ពេលខ្ញុំចេញមក ខ្ញុំបានជួបជាមួយ រុម និង ណាំ នៅក្នុងភូមិសាឡុង ពេលនោះខ្ញុំទើបដឹងថាឈ្មោះពីរនាក់នេះមកបង្កប់ខ្លួននៅក្នុងភូមិសាឡុង ព្រោះ រុម និង ណាំ នេះជាមនុស្សរបស់មេឃុំកោះរះ ឈ្មោះ ចំរើន ។ ពីរនាក់នេះធ្វើពេទ្យនៅភូមិសាឡុង ។

ឆ្នាំ១៩៧១ ខ្ញុំទទួលការណែនាំពីឈ្មោះ ងិន និង តាលន់ ឲ្យទៅបង្កប់ខ្លួននៅក្នុងជួរប្រជាជន ហើយធ្វើសកម្មភាពបំផុស

ទំនាស់ប្រជាជនក្នុងភូមិ និងដើរឃោសនាប្រជាជនឲ្យជួយខបក្តម្ភកងទ័ពវៀតណាម ឲ្យប្រជាជនមើលឃើញថា កងទ័ពវៀតណាមល្អ គឺឃោសនាលើកឥទ្ធិពលវៀតណាមដែលមានគុណបំណាច់លើកម្ពុជា និងឃោសនាប្រជាជនមិនឲ្យកូនចូលកងទ័ពខ្មែរឲ្យចូលធ្វើកងទ័ពវៀតណាម ព្រោះលើកថាវៀតណាមល្អ ខ្មែរមិនល្អទេ វាយខ្មាំងក៏មិនខ្លាំងដែរ ។ សកម្មភាពខ្ញុំធ្វើជាហូរហែបន្តបន្ទាប់មករហូតនៅឆ្នាំ ១៩៧១ ខ្ញុំទាក់ទងជាមួយ តាលន់ ហើយ តាលន់ កសាងកម្លាំងបានម្នាក់ឈ្មោះ ណុន ដែលត្រូវជាបងប្អូននឹងគ្នា ។ ណុន ជាប្រធានភូមិស្គាស្រុក ។ ខ្ញុំ និង ណុន បានធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ដោយមិនដោះស្រាយជីវភាពប្រជាជនគឺគិតតែពីបំផុសទំនាស់នៅក្នុងជួរប្រជាជន ធ្វើឲ្យមានភាពច្របូកច្របល់ ។

ឆ្នាំ១៩៧២ ខ្ញុំបានទាក់ទងជាមួយឈ្មោះ ៈ

- គង់ ហៅ ងិន គណៈស្រុកពារាំង
- តាលន់ នៅមន្ទីរ តំបន់២២
- ដុន នៅមន្ទីរ តំបន់២២
- អៃ នៅមន្ទីរ តំបន់២២
- ពៅ នៅមន្ទីរ តំបន់២២
- តាកែ្មក នៅមន្ទីរ តំបន់២២

កម្លាំងទាំងអស់នេះចុះមកធ្វើការនៅក្នុងភូមិ និងមានការទាក់ទងជាមួយខ្ញុំ, ណុន និង មួង ។ នៅក្នុងភូមិស្គាស្រុក គឺដើរឃោសនាប្រជាជនមិនឲ្យកូនចូលទៅសមរភូមិមុខ ។ ពេលនោះខ្ញុំ, ណុន និងមួង ធ្វើសកម្មភាពបំផុសថា នៅសមរភូមិមុខខ្មាំងខ្លាំងណាស់ ពេលចូលសមរភូមិមុខម្តងៗស្លាប់ច្រើនណាស់ ពេលណាក៏ខ្មាំងខ្លាំងដែរ ។ ខ្ញុំធ្វើសកម្មភាពបំផុសយុទ្ធជន នៅតាមភូមិដោយលើកថា បើមិត្តឯងទៅសមរភូមិមុខប្រយ័ត្នមិនបានជួបមុខម៉ែ

ពាក់កណ្តាលឆ្នាំ១៩៧២ គ្រួសារខ្ញុំមកលេងនៅភូមិស្គាស្រុក ពេលនោះគ្រួសារខ្ញុំអប់រំថា បញ្ហាអ្វី គឺត្រូវទទួលការណែនាំពីសមមិត្ត ងិន ចុះ ។ ក្រោយពីនេះ គ្រួសារខ្ញុំបានហៅកម្លាំង សេ.អ៊ី.អា មកប្រជុំនៅនឹងផ្ទះខ្ញុំនៅជាមួយ តាលន់ នៅភូមិស្គាស្រុក អ្នកចូលរួមប្រជុំមាន ខ្ញុំ, គង់ ងិន, សាយ ប្រធានពេទ្យតំបន់២២ និង តាលន់ ។ ខ្លឹមសារគឺៈ គ្រួសារខ្ញុំណែនាំឲ្យរៀបចំកសាងកម្លាំងក្បត់ កៀងគរកម្លាំងប្រជុំឲ្យបានច្រើន ហើយឲ្យធ្វើសកម្មភាពបំផុសប្រជាជនឲ្យមានទំនាស់ ហើយពេលចាត់តាំងសហករណ៍ត្រូវធ្វើសកម្មភាពបំផុសទំនាស់ និងបំផ្លាញរបស់សមូហភាព ។ ក្រោយពីប្រជុំរួច គ្រួសារខ្ញុំក៏ត្រឡប់ទៅតំបន់វិញ ។ ក្រោយពីគ្រួសារខ្ញុំត្រឡប់ទៅវិញបាត់ ឈ្មោះ ងិន ហៅកម្លាំងក្បត់មកប្រជុំមាន គង់ ងិន, ណុន និងខ្ញុំ ។ ខ្លឹមសារគឺៈ ឲ្យប្រជាជនយល់ថា អង្គការបដិវត្តន៍បំផុសប្រជាជនឲ្យកូនចូលធ្វើកងទ័ព ដោយអង្គការយកទៅឲ្យវាយខ្មាំង គឺចំណេញតែស្លាប់ទេ ។

ឆ្នាំ១៩៧៣ អង្គការបានចាត់តាំងខ្ញុំមកនៅសហករណ៍ផលិតកម្មកម្រិតទាប ។ សកម្មភាពរបស់ខ្ញុំនៅពេលនោះ គឺបំផុសប្រជាជនមិនឲ្យចូលសហករណ៍ ។ ពេលនោះអង្គការណែនាំថា ឲ្យយករបស់របរដាក់រួមត្រឹមតែគោ ក្របី ស្រែទេ ហើយសម្ភារបន្តិចបន្តួចទុកមិនទាន់ដាក់រួមទេ ។ តែខ្ញុំបានបំផុសប្រជាជនថារបស់របរទាំងអស់នេះត្រូវដាក់រួម គ្រាន់តែរបស់របរកំប៉ិកកំប៉ុកក៏យកទៅដាក់រួមទាំងអស់ បើអ្នកណាមិនដាក់រួមអ្នកនោះក្បត់បក្ស ដើម្បីឲ្យប្រជាជនមើលឃើញថា អង្គការបដិវត្តន៍តឹងតែងគាបសង្កត់ប្រជាជន ។

ឆ្នាំ១៩៧៣ដដែល តាលន់ ត្រូវចេញមកនៅតំបន់ ពេលនោះគាត់ណែនាំខ្ញុំថា ត្រូវទាក់ទងកម្លាំងរបស់យើងឲ្យជាប់មាន ដុន, អៃ, តាកែ្មក និង ពៅ ។ តាលន់ ឲ្យខ្ញុំទាក់ទងធ្វើសកម្មភាពនៅសហករណ៍ភូមិស្គាស្រុក ហើយខ្ញុំកសាងកម្លាំងបានម្នាក់ឈ្មោះ សេង ។ សេង មានចំណុចខ្សោយក្នុងការមិនជឿលើបដិវត្តន៍ គឺធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ តាំងពីឆ្នាំ១៩៧០ មកម្ល៉េះ ។

ឆ្នាំ១៩៧៣នេះដែរ ដុន និង អៃ បានឲ្យខ្ញុំធ្វើការទាក់ទងជាមួយ យ៉យ ប្រធានភូមិស្គាស្រុក ។ ឈ្មោះ យ៉យ នេះ តាលន់ កសាងយូរមកហើយ ។

នៅឆ្នាំដដែលនេះ អង្គការលើកថា កសិករមានអនុធនលើ គឺចាត់តាំងសហករណ៍ផលិតកម្មកម្រិតទាប ។ តែសកម្មភាពរបស់ខ្ញុំ និង យ៉យ ធ្វើសកម្មភាពចាត់តាំងសហករណ៍យកកសិករកណ្តាលលើមកចាត់តាំងកម្រិតខ្ពស់ យកកសិករក្រ និងកណ្តាលថ្នាក់ក្រោមចាត់តាំងសហករណ៍កម្រិតទាប ដើម្បីបំផ្លើសមាគ៌ារបស់បក្ស ។

ឆ្នាំ១៩៧៤ ខ្ញុំបានទាក់ទងជាមួយឈ្មោះ យ៉យ, សេង, អៃ, ពៅ និង ដុន ក្នុងការធ្វើសកម្មភាពបំផ្លាញសម្ភារនៅក្នុងសហករណ៍ ពេលនោះឈ្មោះ យ៉យ កសាងកម្លាំងបានម្នាក់ឈ្មោះ លឹម ។ លឹម

នេះមានចំណុចខ្សោយមិនក្តាប់សហករណ៍ ។ ខ្ញុំ និង លឹម បានធ្វើសកម្មភាពបំផុសទំនាស់នៅក្នុងសហករណ៍ធ្វើឲ្យច្របូកច្របល់ ធ្វើឲ្យប្រជាជនអស់ជំនឿលើបដិវត្តន៍ ។

ខែកក្កដា ឆ្នាំ១៩៧៤ យ៉យ ចុះមកភូមិស្គាស្រុក ពេលនោះ យ៉យ ឲ្យខ្ញុំទៅហៅកម្លាំងមកជួបគាត់ដែលមាន លឹម, សំ, ណុន, សេង និងខ្ញុំ ។ យ៉យ លើកឡើងថា បញ្ហាយើងនៅបង្កប់ក្នុងសហករណ៍នេះ យើងត្រូវយកចិត្តទុកដាក់កសាងកម្លាំងឲ្យបានច្រើន ដើម្បីបង្កប់នៅក្នុងបដិវត្តន៍ឲ្យបានជ្រៅនៅតាមភូមិឃុំ ។ ចំពោះបញ្ហាធ្វើសកម្មភាពគឺត្រូវធ្វើឲ្យបានជាប់ ដោយបំផុសនៅក្នុងសហករណ៍ឲ្យច្របូកច្របល់ ធ្វើឲ្យប្រជាជនអស់ជំនឿលើអង្គការ បំផ្លាញរបស់របរ ហើយគោក្របីត្រូវកាប់ស៊ីឲ្យជាប់ ធ្វើយ៉ាងណាបំផ្លាញបដិវត្តន៍ ។ យ៉យ បានលើកទៀតថា សមមិត្ត សំ ត្រូវទាក់ទងជាមួយសមមិត្ត លាង ប្រធានសង្កាត់ញ្ញើទី២ និងសមមិត្ត កុយ អនុប្រធានសង្កាត់ញ្ញើទី២ ឲ្យជាប់ ហើយកម្លាំងដែលនៅតាមភូមិត្រូវទាក់ទងជាមួយសមមិត្ត សំ ឲ្យជាប់ដែរ ។

ខែមករា ឆ្នាំ១៩៧៥ សកម្មភាពរបស់ខ្ញុំបំផុសប្រជាជនឲ្យច្របូកច្របល់នៅក្នុងប្រជាជន ពេលនោះគ្រួសារខ្ញុំ និង យ៉យ ទៅផ្ទះខ្ញុំ ។ គ្រួសារខ្ញុំលើកថា កម្លាំងនៅក្នុងសហករណ៍ដែលធ្លាប់ទាក់ទងគ្នាត្រូវធ្វើសកម្មភាពឲ្យខ្លាំងខាងអុកឡុកអង្គការ ត្រូវបំផុសប្រជាជនទាមទារឲ្យកូនមកផ្ទះ ព្រោះនៅសមរភូមិមុខងាប់ច្រើនណាស់ ហើយអ្នកដែលពលី អង្គការមិនឲ្យដឹងដល់ឪពុកម្តាយទេ គឺធ្វើឲ្យប្រជាជនជ្រួលច្របល់ ធ្វើឲ្យអង្គការពិបាកដោះស្រាយ ។

## អំពីសកម្មភាពរបស់ខ្ញុំក្រោយរំដោះទូទាំងប្រទេស

ក្រោយរំដោះ អង្គការលើកទិសជួយឧបត្ថម្ភដល់ប្រជាជនជម្លៀស តែសកម្មភាពរបស់ខ្ញុំទទួលការណែនាំពីឈ្មោះ លឹម ឲ្យធ្វើសកម្មភាពបំផុសទំនាស់រវាងប្រជាជន និងប្រជាជនមូលដ្ឋាន ធ្វើឲ្យច្របូកច្របល់ បំផុសទំនាស់ពីគ្រួសារមួយទៅគ្រួសារមួយ ធ្វើឲ្យក្នុងសហករណ៍ភូមិស្គាស្រុកនេះ ច្របូកច្របល់រវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ។

ខែមិថុនា ឆ្នាំ១៩៧៥ យ៉យ កម្មាភិបាលស្រុកចុះមកលេងផ្ទះខ្ញុំ និងគ្រួសារខ្ញុំផង ក៏ដូចជាចុះមកក្តាប់ការងាររបស់សហករណ៍ ។ ពេលនោះ យ៉យ លើកថាកម្លាំងក្បត់ដែលនៅក្នុងសហករណ៍ត្រូវបន្តកសាងកម្លាំង សេ.អ៊ី.អា ឲ្យបានច្រើន ហើយធ្វើសកម្មភាពបំផ្លាញបដិវត្តន៍នៅក្នុងសហករណ៍ និងបង្កទំនាស់ឲ្យជាប់ ។

បន្ទាប់មក ខ្ញុំ លឹម, ណុន និង សេង បានពិភាក្សាធ្វើសកម្មភាពបន្តទៀត ។ អង្គការបានបើករបស់របរមកឲ្យចែកតាមសហករណ៍ ពេលនោះ ចែកមានលើសខ្វះ និងបាននាំគ្នាដើរបំផុសថា អង្គការអួតថាល្អៗ ល្អណានឹងកើត បើពេលចែកសម្ភារមិនចែកឲ្យប្រជាជនផងនោះ ។

ខែសីហា ឆ្នាំ១៩៧៥ ខ្ញុំទទួលការណែនាំពី សំ និង លឹម ឲ្យធ្វើសកម្មភាពបំផ្លាញសំណាប ពេលត្រាំសំណាបធ្វើឲ្យរលួយចោល ។

ខែតុលា ឆ្នាំ១៩៧៥ ពេលនោះគ្រួសារខ្ញុំយកខ្ញុំពីសហករណ៍ស្គាស្រុក ឃុំញ្ញើទី២ ស្រុកស៊ីធរកណ្តាល តំបន់២២ មកឲ្យនៅតំបន់២៥វិញ ។ ពេលនោះគាត់យកខ្ញុំមកឲ្យនៅក្នុងមន្ទីរតំបន់ ជាមួយបង ជា លេខាតំបន់២៥ ។ គាត់ប្រាប់ខ្ញុំថា ត្រូវចាំស្តាប់មិត្ត ជា សិនចុះ គាត់ឲ្យធ្វើការអ្វីធ្វើហ្នឹងទៅ ។ ពេលនោះគ្រួសារខ្ញុំបានប្រាប់ថា យកខ្ញុំឲ្យនៅតំបន់២៥នេះ គឺដើម្បីតខ្សែពីបង ជា លេខាតំបន់២៥ ទៅគាត់ ហើយពីគាត់ទៅបង ជា វិញ ។ បង ជា យកខ្ញុំទៅនៅជាមួយក្នុងមន្ទីរតំបន់នៅតាខ្មៅជាមួយប្រពន្ធគាត់ឈ្មោះ សែម នៅក្តាប់កងនារីរបស់តំបន់២៥ ។ នៅទីនោះខ្ញុំធ្វើបាយ ធ្វើទឹកឲ្យបង ជា ។ គាត់បានអប់រំខ្ញុំនិងប្រពន្ធគាត់ថា ត្រូវកសាងកម្លាំងក្បត់នៅក្នុងកងនារីឲ្យបានច្រើន ដើម្បីធ្វើសកម្មភាពប្រឆាំងជាមួយបដិវត្តន៍ ហើយគាត់បានប្រាប់កម្លាំងឲ្យខ្ញុំដឹងនៅក្នុងតំបន់ជាមួយប្រពន្ធគាត់មានៈ

- តាហុង ប្រធានមន្ទីរ១១ របស់តំបន់២៥
- តាអ៊ូច ប្រធានដឹកជញ្ជូនរបស់តំបន់២៥
- តាសួង ប្រធានសិប្បកម្មរបស់តំបន់២៥
- ដេង ប្រធានខាងក្រឡឹងរបស់តំបន់២៥
- ជួន ខាងជួសជុលឡាន
- ជា ទៅនៅធ្វើប្រធានមន្ទីររបស់ស្រុក១៥៤ ។

កម្លាំងទាំងអស់នេះ គាត់បានប្រាប់ខ្ញុំឲ្យដឹង ហើយណែនាំថាធ្វើការទាក់ទងជាមួយគ្នាចុះពីបញ្ហាធ្វើសកម្មភាព ។

ឆ្នាំ១៩៧៦ ក្រោយពីទទួលការណែនាំពីបង ជា ហើយ ខ្ញុំ និងបង សែម បានធ្វើសកម្មភាពកសាងកម្លាំងបានម្នាក់ឈ្មោះនារី សាមិត ប្រធានក្រុមមានចំណុចខ្សោយ លេងសើច ហើយមុខមាត់ អួតអាង

ធ្វើការខ្ជិលខ្ជា ខ្ញុំឃើញដូច្នេះ ក៏បានអប់រំឲ្យធ្វើសកម្មភាពប្រឆាំងជាមួយបដិវត្តន៍ ។ ខ្ញុំណែនាំនារី សាមិត ធ្វើសកម្មភាពនៅក្នុងកងនារីដោយបំផុសពីបញ្ហាសីលធម៌នៅក្នុងកង បំផុសពីបញ្ហាទាមទារអន្តការរកប្ដី ហើយបាតុភាពនេះមានជាបន្តបន្ទាប់ ។

ខែមីនា ឆ្នាំ១៩៧៦ គ្រួសារខ្ញុំទៅលេងនៅតាខ្មៅ ។ ពេលនោះ គាត់អប់រំខ្ញុំថាត្រូវធ្វើសកម្មភាព ហើយសមមិត្ត ជា នេះក៏ជាខ្សែ សេ.អ៊ី.អា ដែរ និងជាអ្នកដឹកនាំនៅក្នុងតំបន់២៥ ទាំងមូល ហើយគាត់លើកថា យើងនៅកន្លែងណាត្រូវបង្កប់ធ្វើសកម្មភាពឲ្យបានជ្រៅ ។ ពេលនោះ ខ្ញុំរាយការណ៍ឲ្យគាត់ដឹងថា បង ជា បានឲ្យខ្ញុំធ្វើការជាមួយប្រពន្ធគាត់ និងធ្វើសកម្មភាពនៅក្នុងកងនារី ។

ក្រោយមក ខ្ញុំបានទៅធ្វើស្រែនៅព្រែកសំរោង និងបានទាក់ទងជាមួយ សារុម ប្រធានក្រុម និងសាមិត ។ នារី សារុម នេះ សាមិត កសាងបានពេលធ្វើស្រែ ដោយមានសកម្មភាពបំផ្លាញស្រូវឡើងទឹក ។ ខ្ញុំ និងបង សែម, សារុម និង សាមិត ទទួលការណែនាំពីឈ្មោះ ហុង ឲ្យធ្វើសកម្មភាពបំផ្លាញសម្ភាររបស់របរធ្វើស្រែ គឺពេលប្រូតស្រូវត្រូវជាន់ពន្លិចចោលក្នុងទឹកធ្វើឲ្យជ្រុះចោល ។

ឆ្នាំ១៩៧៦ បង ជា ហៅខ្ញុំ និងប្រពន្ធគាត់មកជួបនៅមន្ទីរតំបន់មាន បង ហុង និងបង ដេង ។ ពេលនោះគាត់លើកណែនាំពីបញ្ហាធ្វើសកម្មភាពកសាងកម្លាំង ធ្វើសកម្មភាព និងទាក់ទងកម្លាំងឲ្យបានជាប់ ត្រូវពង្រីងកម្លាំងពង្រីកកម្លាំង ហើយណែនាំខ្ញុំ និងប្រពន្ធគាត់ឲ្យទាក់ទងជាមួយឈ្មោះ ហុង នេះឲ្យជាប់ក្នុងការធ្វើសកម្មភាព ។

បន្ទាប់មកគាត់លើកបញ្ហាធ្វើសកម្មភាពបំភ្លៃមាគ៌ាបក្សពីបញ្ហាសីលធម៌ បំផុសនារីឲ្យទាក់ទងជាមួយកងពិការរបស់ភូមិភាគធ្វើឲ្យប្របូកប្របល់នៅក្នុងកង ធ្វើឲ្យបក្សពិបាកដោះស្រាយ ។ សកម្មភាពកសាងកម្លាំង ខ្ញុំកសាងបានម្នាក់ឈ្មោះ លន អ៊ី ប្រធានក្រុមចំណុចខ្សោយពេលធ្វើការងារ មានអំនួត មុខមាត់ មិនស្ដាប់ការណែនាំរបស់ថ្នាក់លើ ។ ខ្ញុំឃើញដូច្នេះហើយ បានកសាងនារី លន អ៊ី នេះឲ្យធ្វើសកម្មភាពបន្តទៀត ។ ខ្ញុំណែនាំឲ្យធ្វើសកម្មភាពបំផុសពីបញ្ហាអន្តការតឹងតែង ធ្វើការគ្មានពេលសម្រាកទេ ហើយឲ្យបង្កទំនាស់នៅក្នុងកងនារី ធ្វើឲ្យប្របូកប្របល់ សកម្មភាពនេះធ្វើជាមួយនារី សារុម និងនារី សាមិត នៅក្នុងកងនារីនេះ ។

ខែសីហា ឆ្នាំ១៩៧៦ គ្រួសារខ្ញុំមកលេងនៅតាខ្មៅ ពេលនោះគាត់ជួបជាមួយបង ជា ខ្ញុំក៏នៅជិតគាត់ដែរ គឺគាត់បានជួបពិភាក្សាជាមួយបង ជា ។ ខ្ញុំឮបង ជា និយាយរាយការណ៍ឲ្យគ្រួសារខ្ញុំ តែមុននឹងបង ជា រាយការណ៍ គ្រួសារខ្ញុំណែនាំបង ជា ពីបញ្ហាពង្រីងកម្លាំងនៅក្នុងមូលដ្ឋាន ហើយកសាងកម្លាំងក្បត់ឲ្យបានច្រើន និងរៀបចំបង្កប់នៅក្នុងមូលដ្ឋាន សហករណ៍ក្ដីដែលត្រូវការស្រួលធ្វើសកម្មភាព ។ ខ្ញុំក្ដាប់បានគ្រួសារខ្ញុំនិយាយណែនាំបង ជា ពីបញ្ហាត្រៀមរៀបចំកម្លាំងទុកវាយបក្សនៅពេលខាងមុខនេះ ហើយកម្លាំងក្បត់ដែលយើងកសាងបានត្រូវក្ដាប់ឲ្យជាប់ដល់ពេលមានការយើងយកប្រើតែម្ដង ។

បង ជា បានរាយការណ៍ពីកម្លាំងក្បត់នៅក្នុងមន្ទីររបស់តំបន់២៥មាន ហុង, ដេង, តាអ៊ុច, តាសួង និងជួន ហើយគាត់បាននិយាយពីសភាពការណ៍នៅក្នុងតំបន់២៥ និងបានលើកពីការអប់រំកម្លាំងពង្រឹងពង្រីកកម្លាំងបាន ហើយកំពុងបន្តសកម្មភាព ។ បង ជា លើកពីបញ្ហាកម្លាំងនៅមូលដ្ឋាន គឺពង្រឹងពង្រីកកម្លាំងបានហើយ ហើយក៏បានកសាងបង្កប់នៅតាមស្រុកដែរ ។

ក្រោយមកទៀតបង ជា ហៅប្រពន្ធគាត់ និងខ្ញុំទៅជួបគាត់ ហើយណែនាំថា ត្រូវពង្រីកកម្លាំងនៅក្នុងកងនារី និងភារកិច្ចរបស់យើងនៅតាខ្មៅនេះត្រូវធ្វើសកម្មភាពបំផុសពីបញ្ហាឲ្យកម្លាំងរត់ទៅស្រុកយួន ។

នៅឆ្នាំ១៩៧៦នេះដែរ សកម្មភាពរបស់ខ្ញុំជាមួយបង សែម ដើរបំផុសនារីឲ្យមើលឃើញពីការលំបាកនៅធ្វើការងារ ព្រោះធ្វើគ្មានពេលម៉ោងសម្រាក ។ បំផុសឲ្យឃើញថា ក្នុងដំណាក់កាលធ្វើបដិវត្តន៍សង្គមនិយមមានការលំបាក ឲ្យឃើញបដិវត្តន៍លំបាក តឹងតែង បដិវត្តន៍សង្គមនិយមគ្រាន់តែរកប្ដីក៏ពិបាកដែរ ព្រមទាំងបំផុសនារីឲ្យរកប្ដីរត់ទៅយួន ។

បន្ទាប់មកទៀត ខ្ញុំបានជួបជាមួយបង ហុង ប្រធានមន្ទីរ១១ និងបង ដេង ប្រធានសិប្បកម្ម តំបន់២៥ ។ ពេលនោះខ្ញុំ និងបង សែម រាយការណ៍ឲ្យអ្នកទាំងពីរពីការធ្វើសកម្មភាពនៅក្នុងកងនារី និងពីការកសាងកម្លាំងបានទាំងអស់បីនាក់ គឺសាមិត, សារុម និង លន អ៊ី ក្រោយពីខ្ញុំរាយការណ៍ហើយ បង ហុង បានណែនាំខ្ញុំឲ្យខំក្ដាប់កម្លាំង និងធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ឲ្យខ្លាំងក្លា ដោយឲ្យខ្ញុំ និងបង សែម ទាក់ទងជាមួយនារី ថុង ។

ក្រោយពីបង ហុង ណែនាំហើយ ខ្ញុំ និងបង សែម ធ្វើការទាក់

ទងជាមួយ ថុង និងណែនាំ នារី ថុង, សាមិត, សារុម និងលន អី ឲ្យធ្វើសកម្មភាពបំផ្លាញស្រូវ មិនបញ្ចូលទឹកក្នុងស្រែ លួចបង្ហូរទឹកក្នុងស្រែចោល ។ សកម្មភាពបន្តទៀតគឺ បង្កទំនាស់ជាមួយពួកពិការភាគដែលមន្ទីរនៅព្រែកហូរ ដោយបង្កអុកឡុកមានធ្វើឲ្យទំនាស់ប្រចប្រុកប្រចល់រហូតដល់ពួកពិការឃើញនារីដើរម្នាក់ឯងលបចាប់ ហើយទំនាស់នេះមានជាប់រហូតមក ធ្វើឲ្យអង្គការដោះស្រាយមិនចេញ ។

ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហុង បានហៅកម្លាំងក្បត់មកប្រជុំនៅផ្ទះបង សែម ដែលមាន អ្នកចូលរួមគឺ ហុង, ផេង, សែម, នារី សាមិត, នារី សារុម, នារី លនអី, នារី ថុង និងខ្ញុំ ដោយមានខ្លឹមសារគឺៈ

ហុង លើកថា យើងប្រមូលកម្លាំងបានហើយ យើងត្រូវពង្រីកឲ្យធ្វើសកម្មភាពឲ្យខ្លាំងថែមទៀត គឺបំផ្លាញដល់ការកសាងប្រទេសរបស់បក្ស គឺយើងបំផ្លាញស្រូវ ។ គាត់លើកពីរបៀបធ្វើ យើងត្រូវក្តាប់ចំណុចខ្សោយឲ្យជាប់ ហើយបំផុសកសាងកម្លាំងឲ្យបានច្រើននៅក្នុងកងនារី ត្រូវដឹកនាំធ្វើសកម្មភាពកសាងកម្លាំងឲ្យបានច្រើនមកធ្វើកម្លាំងក្បត់ ហើយគាត់លើកពីសកម្មភាពដែលត្រូវធ្វើមានៈ

- យើងបំផ្លាញស្រូវ ពេលច្រូតស្រូវ ។
- ត្រូវបំផ្លាញកណ្តៀវ ចប ហើយស្រូវយើងទុកឲ្យទុំញោសចាំច្រូត គឺធ្វើឲ្យដាច់កស្រូវ ។
- យើងត្រូវបំផុសយុវនារី នៅក្នុងកងកុំឲ្យខំធ្វើការ គឺយើងបំផុសតែពីការធ្វើបដិវត្តន៍លំបាក ។

ក្រោយពីប្រជុំមក សកម្មភាពរបស់ខ្ញុំនៅពេលច្រូតស្រូវ គឺបំផ្លាញស្រូវ ពេលច្រូតគឺច្រូតបោះៗ ធ្វើឲ្យជ្រុះពាសពេញ ។ ពេលនោះខ្ញុំទាក់ទងជាមួយនារី សាមិត, នារី សារុម, នារី លន អី និង នារី ថុង ។ បងសែម បានណែនាំឲ្យបំផ្លាញស្រូវ ពេលយកពូជទៅទុកធ្វើឲ្យកំពប់ ហើយលាយគ្នាយកពូជស្រូវក្រមួនសទៅលាយជាមួយពូជស្រូវចុងបន្ទា ធ្វើឲ្យប្រឡូកគ្នា និងទុកឲ្យផ្តុស ។ ពេលបោកស្រូវ កុំឲ្យបោកជ្រុះអស់ពេក ពេលដែលចោលកណ្តាប់ទៅស្រូវនៅសល់ច្រើន ហើយបញ្ហាបំផ្លាញដំណាំដូចជា កាប់ចេកចោល ពេលឆ្ការព្រៃ ដោយយកលេសថាជាព្រៃ ។

ខែមករា ឆ្នាំ១៩៧៧ បង ជា ឲ្យខ្ញុំទៅនៅស្រុកកណ្តាលស្ទឹង ពេលនោះចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានសិប្បកម្មត្បាញរវៃរបស់ស្រុក១៥៤ មុនពេលខ្ញុំទៅនៅស្រុកកណ្តាលស្ទឹង បង ជា បានអប់រំ ខ្ញុំថា ពេលទៅនៅក្នុងស្រុក គឺទាក់ទងជាមួយសមមិត្ត ជា មន្ទីរស្រុក១៥៤ ។ ពេលនោះគាត់លើកថា បញ្ហាធ្វើសកម្មភាព កសាងកម្លាំងជាសំខាន់ ហើយក៏ប្រយ័ត្នបែកការណ៍ដែរ ហើយបង ជា បានប្រាប់ខ្ញុំថាកម្លាំងដែលត្រូវទាក់ទងធ្វើសកម្មភាពមានឈ្មោះ ជា ប្រធានមន្ទីរស្រុក១៥៤ និងគ្រុយ លេខាស្រុក១៥៤ ។ ឈ្មោះទាំងពីរនាក់នេះ បង ជា ឲ្យខ្ញុំទទួលការណែនាំធ្វើសកម្មភាពជាមួយ ហើយគាត់បានប្រាប់ខ្ញុំថា សមមិត្ត ជា និងគ្រុយ គឺដឹងអស់ហើយ ។

ពេលខ្ញុំមកនៅក្នុងស្រុក១៥៤ ពេលនោះបង ស៊ុម នារី ប្រកាសចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានសិប្បកម្មរបស់ស្រុក១៥៤ នៅកំពង់កន្ទួត ។

ពេលនោះខ្ញុំទៅក្តាប់ ស្មារតី យុវជន យុវនារី នៅឡើយ គឺរហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំបានការទាក់ទងជាមួយឈ្មោះ គ្រុយ និងឈ្មោះ ជា នៅកំពង់កន្ទួត ។ ពេលនោះ អ្នកទាំងពីរហៅខ្ញុំមកណែនាំដោយលើកពីបញ្ហាដែលមកនៅក្នុងស្រុក១៥៤ និងពីទិសធ្វើសកម្មភាពនៅក្នុងឆ្នាំ១៩៧៧ នេះគឺៈ

១) យើងត្រូវធ្វើសកម្មភាពកសាងកម្លាំងក្នុងអង្គភាពខ្លួន ។

២) យើងត្រូវបំផ្លាញសម្ភារនៅក្នុងមន្ទីរតម្បាញ ហើយបង គ្រុយ បានលើកពីខ្សែរយៈឲ្យធ្វើសកម្មភាពមានឈ្មោះៈ

- ផ្នែកសិប្បកម្មតម្បាញមាននារី ភី ជាសមាជិកសិប្បកម្មតម្បាញ និងនារី អឿន ប្រធានក្រុមសិប្បកម្មតម្បាញ ។
- ផ្នែកដេរមាននារី យឹម ចេញពីមន្ទីរអប់រំ, នារី ណាង នារីក្រោយ១៧មេសា និងច្រឹក កម្មករពាង ក្បឿង ។
- ផ្នែកពាង ក្បឿង មានឈ្មោះ តំ ជាប្រធានសិប្បកម្មពាងក្បឿង, កុល ជាអនុប្រធាន សិប្បកម្មពាង ក្បឿង និង ឡូត ប្រធានក្រុមផ្នែកខាងត្បូង ។

ឈ្មោះទាំងអស់នេះ ជាខ្សែទាក់ទងធ្វើសកម្មភាពក្បត់ជាមួយគ្នា ។ ក្រោយមកទៀត អង្គការចាត់តាំងឲ្យទៅច្រូតស្រូវនៅកំពង់កន្ទួត ពេលនោះអង្គការណែនាំថា ស្រូវត្រូវច្រូតពេលព្រឹកចំពោះស្រូវណាទុំខ្លាំង ហើយស្រូវស្លាបសេកត្រូវច្រូតពេលថ្ងៃ ។ ពេលនោះ ខ្ញុំបានជួបពិភាក្សាជាមួយ តំ និង ឡូត ហើយ តំ លើកឡើងថា ស្រូវទុំស្រួយ យើងទុកសិន យើងច្រូតអាណាពុំទាន់ទុំញោស ។ ជាគោល

បំណាងធ្វើឲ្យស្រូវខូចអស់ច្រើន ដោយស្រូវទុំច្រូតពុំកើត ហើយខូចចោល ។ តំ បានចាត់តាំង ឡូត ឲ្យទទួលខាងបោក ហើយខ្ញុំ និង តំ ទទួលខាងដឹកនាំច្រូត និងជា រៀបផែនការបំផ្លាញស្រូវ ។

ចុងខែកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំបានជួបគ្រួសារខ្ញុំ ពេលដែលគាត់ទៅរកខ្ញុំនៅកំពង់កន្ទួត តែខ្ញុំមកតាខ្មៅ ។ កាលនោះ គ្រួសារខ្ញុំគ្រាន់តែប្រាប់ខ្ញុំថា នៅកន្លែងនេះ ត្រូវបង្កប់ខ្លួនប្រយ័ត្នបែកការណ៍ ហើយសកម្មភាពក៏ត្រូវបំផ្លាញឲ្យជាប់ ។

ខែមីនា ឆ្នាំ១៩៧៧ អង្គការចាប់ គ្រុយ ពេលនោះនៅក្នុងមន្ទីរសិប្បកម្មឈ្មោះមួយចំនួនដែលបង ស៊ីម ក្តាប់បានត្រូវដកឲ្យទៅនៅសហករណ៍អស់ ។ ដូច្នេះកម្លាំងនៅកន្លែងនោះ ខ្ញុំត្រូវទាក់ទងជាមួយបង ជា ប្រធានមន្ទីរស្រុក១៥៨នេះ ហើយគាត់ណែនាំឲ្យខ្ញុំធ្វើសកម្មភាពនៅក្នុងមន្ទីរសិប្បកម្មនេះ ។ គាត់លើកពីបញ្ហារៀបចំការទាក់ទងជាមួយខាងមន្ទីរពាង ក្បឿង ។ បន្ទាប់មក បង ជា បានហៅ តំ មកជួបនៅកំពង់កន្ទួត ពេលនោះគាត់លើកថា បញ្ហាកសាងកម្លាំងត្រូវកសាងនៅក្នុងអង្គភាពរបស់ខ្លួន គឺកសាងឲ្យបានច្រើន ហើយត្រូវទាក់ទងគ្នាឲ្យបានជាប់ ។

ក្រោយពីបង ជា លើកឡើងហើយក៏បែកគ្នា ហើយខ្ញុំមកនៅធ្វើសកម្មភាពនៅក្នុងមន្ទីរសិប្បកម្មតម្បាញនេះ បានកសាងម្នាក់គឺ នារី លី មានចំណុចខ្សោយមិនធ្វើការងារ ពេលខ្ញុំកសាងបានហើយ ខ្ញុំឲ្យធ្វើសកម្មភាពបំផ្លាញម៉ាស៊ីនដេរធ្វើឲ្យខូច និងបំផុសពីបញ្ហាដើរលួចប្របូកប្របល់នៅក្នុងអង្គភាព ។

នៅចុងខែមីនា ឆ្នាំ១៩៧៧ បងស៊ីម ដកនារី លី ឲ្យទៅនៅក្នុងកងចល័ត ពេលនោះខ្ញុំបានហៅមកអប់រំឲ្យធ្វើសកម្មភាពត្រូវកសាងកម្លាំង ហើយបំផុសពីបញ្ហាសីលធម៌ឲ្យប្របូកប្របល់កងចល័ត ។

ខែមេសា ឆ្នាំ១៩៧៧ គ្រួសារខ្ញុំទៅលេងខ្ញុំនៅកំពង់កន្ទួត ពេលនោះទៅជាមួយបង ជា គឺជិះឡានតូចទៅ និងមាននីរសារគ្រួសារខ្ញុំម្នាក់ទៅជាមួយផង ។ ពេលគាត់ទៅដល់ភ្លាម បង ជា បានប្រើខ្ញុំឲ្យទៅហៅកម្លាំងមកជួបគាត់មានឈ្មោះ តំ, កុល, ឡូត និង ជា ។ ឈ្មោះទាំងអស់នេះបានហៅមកជួបគាត់ និងចាប់ផ្តើមបើកការប្រជុំមួយ ។

ពេលនោះគ្រួសារខ្ញុំលើកបញ្ហាប្រជុំ ហើយឲ្យឈ្មោះ ជា ប្រធានមន្ទីរស្រុក១៥៨នេះ រាយការណ៍រួមនៅក្នុងស្រុកពីការកសាងកម្លាំង និងរៀបចំខ្សែទាក់ទងកម្លាំងបង្កប់ ។

បន្ទាប់មកបានគ្រួសារខ្ញុំលើកឡើងអប់រំ គាត់លើកថា ឥឡូវនេះសភាពការណ៍កាន់តែលំបាកណាស់ ព្រោះនៅគ្រប់អង្គភាពនៅគ្រប់កងទាំងអស់ អង្គការកំពុងតាមដានខ្លាំងណាស់ ហើយកម្លាំងដែលយើងកសាងបានត្រូវពង្រឹងឲ្យខ្លាំង និងទាក់ទងឲ្យជាប់ ។ បើសភាពការណ៍មិនស្រួល ត្រូវរត់ទៅស្រុកយួន ហើយវាយបកបដិវត្តន៍វិញ ។

បន្តមកទៀតបង ជា គាត់លើកថា កម្លាំងរបស់យើងនៅក្នុងមូលដ្ឋានទាំងអស់នេះ ត្រូវបង្កប់នៅតាមស្រុកឲ្យបានជ្រៅ និងប្រយ័ត្នកុំឲ្យបែកការណ៍ តែបែកការណ៍ខ្សែរបស់យើង អ្នកដឹកនាំរបស់យើងនឹងត្រូវអន្តរាយអស់មិនខាន តែបើយើងធ្វើការបានល្អ យើងរក្សាការសម្ងាត់បានល្អយើងបង្កប់នៅក្នុងបដិវត្តន៍បានយូរអង្វែងតទៅទៀត ។

ពេលប្រជុំចប់ ហើយគ្រួសារខ្ញុំនិងបង ជា ជិះឡានដើរមើលតាមស្រុក ហើយគាត់ត្រឡប់ទៅកន្លែងវិញ ។ ចាប់តាំងពីពេលនោះមក ខ្ញុំលែងបានជួបគ្រួសារខ្ញុំរហូត ។

ក្រោយពីប្រជុំមក ខ្ញុំបានធ្វើសកម្មភាពនៅក្នុងមន្ទីរតម្បាញ គឺធ្វើឲ្យខូចកីទុកអំបោះចោលពាសពេញ ធ្វើឲ្យខូចដាច់ ហើយខ្ញុំកសាងកម្លាំងបានពីរនាក់ឈ្មោះ ភ័ណ និង លឹម នារីពីរនាក់នេះរត់ពីរោងចក្រ "ត.១១" ភ្នំពេញ ហើយខ្ញុំបានចាប់អប់រំកសាងឈ្មោះពីរនាក់នេះឲ្យធ្វើសកម្មភាពបំផ្លាញសម្ភារនៅក្នុងមន្ទីរតម្បាញនេះ ។

នៅក្នុងសិប្បកម្មតម្បាញនេះ គឺខ្ញុំទាក់ទងជាមួយនារី ភី និងនារី អឿន ។ នារីទាំងពីរនេះ ដែលឈ្មោះ គ្រុយ ខ ទ្រើសនាមឲ្យទាក់ទងតាំងពីយូរណាស់មកហើយ ហើយកម្លាំងកសាងថ្មីមានឈ្មោះ ភ័ណ និង លឹម ក្នុងការធ្វើសកម្មភាពនៅក្នុងតម្បាញ គឺបង្កទំនាស់រវាងកម្មករ គឺធ្វើឲ្យអាប់អួរនៅក្នុងមន្ទីរ ហើយដើរបំផុសបំភ្លើសមាគ៌ារបស់បក្ស ដើរធ្វើសកម្មភាពបំផុសយុទ្ធជន យុទ្ធនារីឲ្យរត់ទៅផ្ទះ គឺដោយបំផុសថា ធ្វើបដិវត្តន៍យូរណាស់ កាន់តែលំបាកណាស់ ហើយខ្ញុំណែនាំឲ្យធ្វើសកម្មភាពបំផុសពីបញ្ហាទាមទារអង្គការរកប្តី ។

ខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំទាក់ទងជាមួយឈ្មោះ តំ, កុល, ឡូត និងបង ជា ប្រធានមន្ទីរស្រុក១៥៨ ។ ពេលនោះពិភាក្សាគ្នាពីការរៀបចំកម្លាំងនៅក្នុងមន្ទីរពាង ក្បឿង ដោយបានកសាងឈ្មោះ ហុង

និង អុល នៅមន្ទីរពាង ក្បៀង ។

ក្រោយពីពិភាក្សាគ្នាមក តំ ហើយនឹងខ្ញុំបានអប់រំយុទ្ធជនពីរនាក់នេះ ហើយរាយការណ៍ឲ្យគាត់ ។ បង ជា អប់រំឲ្យធ្វើសកម្មភាពប្រឆាំងជាមួយបដិវត្តន៍ ដោយណែនាំឲ្យបំផ្លាញក្បៀង និងកសាងកម្លាំង បំផុសទំនាស់នៅក្នុងរោងចក្រពាង ក្បៀងនេះ គឺផ្ដាច់ខ្សែភ្លើងក៏ដូចជាបញ្ហាបំផុសពីបញ្ហាលួចសម្ភារ ។

ក្រោយមកខ្ញុំបានទាក់ទងជាមួយឈ្មោះ វង់ ប្រធានដឹកជញ្ជូនរបស់ស្រុក១៥៤ និងបង ជា ។ វង់ នេះគឺបង ជា ណែនាំឲ្យខ្ញុំដឹង ។ ពេលនោះបង ជា លើកគោលការណ៍ថា បញ្ហាកសាងកម្លាំងយើងត្រូវក្ដាប់ចំណុចខ្សោយឲ្យបានជាប់ ។ ក្រោយពីគាត់ណែនាំ ខ្ញុំបានធ្វើសកម្មភាពនៅក្នុងមន្ទីរតម្បាញ គឺឃោសនាយុទ្ធនារីនៅក្នុងតម្បាញឲ្យឃើញថា បដិវត្តន៍តឹងតែងធ្វើការគ្មានពេលសម្រាក ហើយខ្ញុំអប់រំកម្លាំងដែលខ្ញុំកសាងបានមានឈ្មោះ ភី, អឿន, ភ័ណ និង លឹម នេះឲ្យធ្វើសកម្មភាពនៅតម្បាញកសាងបាននារីឈ្មោះ វ៉ាន់ ជានីរសាររបស់ អាយ ហើយនារី វ៉ាន់ នេះមានចំណុចខ្សោយមិនគោរពហើយអំនួត មុខមាត់ ដូច្នេះខ្ញុំកសាងបានឲ្យធ្វើការទាក់ទងជាមួយនារី ភី, នារី អឿន, នារី ភ័ណ និងនារីលឹម នេះក្នុងការធ្វើសកម្មភាពអុកឡុក បំផ្លាញសម្ភារជាបន្តបន្ទាប់រហូតមក ។

ក្រោយមកទៀតប្ដីនារី វ៉ាន់ នេះឈ្មោះ រឹម នៅខាងពាងក្បៀង ត្រូវបាន តំ និង កុល អប់រំបាន និងឲ្យធ្វើសកម្មភាពនៅកន្លែងនោះដែរ ។

ខែសីហា ឆ្នាំ១៩៧៧ ពេលនោះឈ្មោះ ជា មកពីមន្ទីរស្រុក១៥៤ មកមើលពាង ក្បៀង និងមកមើលអ្នកតម្បាញ ។ ជាបានហៅកម្លាំងមកប្រជុំ អ្នកចូលរួមប្រជុំមាន តំ, កុល, ឡូត, វង់, នារីភី, នារីអឿន និងខ្ញុំ ដោយមានខ្លឹមសារគឺ បញ្ហាកសាងកម្លាំងអប់រំកម្លាំងឲ្យធ្វើសកម្មភាពនៅក្នុងកង ហើយ ជា លើកទៀតថា ពេលយើងធ្វើស្រែ យើងត្រូវធ្វើគឺ ៈ

- យើងត្រូវបំផ្លាញសំណាប យើងសាបយកពូជលាយគ្នា
- យើងត្រូវធ្វើឲ្យសំណាបងាប់ ពេលដកដំណាបក៏ត្រូវបំផ្លាញ
- ពេលស្ទូង ត្រូវស្ទូងបត់ដើម ធ្វើឲ្យរលួយ ត្រូវលួចបង្ហូរទឹកចោល ហើយពេលបញ្ចូលទឹក គឺយើងកុំបង្ហូរធ្វើឲ្យរលួយ ។

នេះផែនការរបស់ ជា ណែនាំ ក្រោយពីណែនាំមក ខ្ញុំត្រូវចុះទៅធ្វើស្រែ ពេលសាប ខ្ញុំធ្វើសកម្មភាពធ្វើឲ្យរលួយខូចសំណាប ។ តំ គឺទទួលការណែនាំពី ជា ឲ្យធ្វើសកម្មភាពពេលដកសំណាប ខ្ញុំណែនាំនារី ភី, នារីអឿន, នារីភ័ណ, នារីលឹម និងនារីវ៉ាន់ ឲ្យធ្វើសកម្មភាពគឺបំផ្លាញសំណាប ។ នៅពេលដកស្ទូង ខ្ញុំកសាងកម្លាំងបានម្នាក់ឈ្មោះនារី វី ខ្ញុំពិនិត្យឃើញចំណុចខ្សោយសេរី មិនស្ដាប់គេឯង ខ្ញុំឃើញដូច្នេះបានអប់រំកសាងឲ្យចូលរួមធ្វើសកម្មភាពក្បត់ជាមួយគ្នា ។ ពេលស្ទូងស្រូវ ខ្ញុំបានណែនាំ ភ័ណ ឲ្យបំផុសយុទ្ធនារីពីបញ្ហាស្ទូងបត់ដើម ធ្វើឲ្យរលួយខូច ហើយពេលថែសន្ទូង ក៏ខ្ញុំបានទទួលការណែនាំពី តំ និង ជា ឲ្យធ្វើសកម្មភាពបំផ្លាញទឹកស្រែ បង្ហូរចោល ហើយពេលអត់ទឹក ធ្វើឲ្យសន្ទូងងាប់អស់ជាច្រើន ។

ខែតុលា ឆ្នាំ១៩៧៧ ជា និង តំ ត្រូវរត់ចេញពីភូមិព្រៃវង និងពីមន្ទីរ ពាង ក្បៀង ។ ក្រោយមក អង្គការចាប់បានឈ្មោះ តំ មកវិញ តែឈ្មោះ ជា បាត់ខ្លួនរហូត ពេលដែលរត់នោះគឺ ជិះម៉ូតូ ។

ក្រោយពីពីរនាក់នេះរត់បាត់ ខ្ញុំត្រូវមកមន្ទីរតាខ្មៅ ពេលនោះខ្ញុំអត់បានជួបជាមួយបង ជា ទេ ខ្ញុំបានជួបជាមួយបង ហ៊ុង ប្រធានមន្ទីរតំបន់២៥ ។ ខ្ញុំបានរាយការណ៍ឲ្យបង ហ៊ុង ដឹងពី តំ និងជា រត់ ហើយឲ្យគាត់ដឹងពីកម្លាំងដែលទាក់ទងធ្វើសកម្មភាពមាន កុល, ឡូត, វង់, នារីភី, នារីអឿន, នារីភ័ណ, នារីលឹម, នារីវ៉ាន់, នារីវី, អុល, រឹម, អ៊ុន និង ហ៊ុង ។

ក្រោយពីខ្ញុំរាយការណ៍មក បងហ៊ុង ណែនាំខ្ញុំថា ត្រូវធ្វើការទាក់ទងខ្សែឲ្យបានជាប់ ហើយធ្វើសកម្មភាពជាមួយកម្លាំងដែលនៅក្នុងស្រុកនោះ ។ ពេលមកជួបជាមួយខ្ញុំនៅក្នុងមន្ទីរតំបន់បង ហ៊ុង ណែនាំខ្ញុំថា ត្រូវប្រយ័ត្ន ព្រោះសភាពការណ៍អង្គការកំពុងតាមដានខ្លាំងណាស់ ហើយបញ្ហាធ្វើសកម្មភាពទាក់ទងត្រូវរៀបចំខ្សែឲ្យបានស្រួលបួលក្នុងការធ្វើសកម្មភាព ។ ក្រោយពីបងហ៊ុង ណែនាំរួចហើយខ្ញុំបានមកដល់កន្លែងវិញ ហើយខ្ញុំបន្តការអប់រំកម្លាំងដែលកសាងបានឲ្យរឹងក្នុងការបន្តធ្វើសកម្មភាពតទៅទៀតក្នុងការបំផ្លាញបដិវត្តន៍នៅពេលធ្វើស្រែ គឺខ្ញុំបំផ្លាញស្រូវជាបន្តបន្ទាប់រហូតមក ។

ថ្ងៃ១៦ ខែធ្នូ ឆ្នាំ១៩៧៧ អង្គការដកខ្ញុំឲ្យទៅនៅប្រូតស្រូវនៅស្វាម៉ាត់ក្នុងស្រុក២០ នៅក្នុងសន្តិបាល គឺនៅក្នុងការដ្ឋានរបស់សន្តិបាល ។ ខ្ញុំចេះតែភ័យ ហើយរហូតដល់ថ្ងៃ១ ខែកុម្ភៈ ឆ្នាំ១៩៧៨ អង្គការចាប់ខ្លួនខ្ញុំតែម្ដង ។ **ផាង សារៈមុនិន្ទ**

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

**អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុជាតិ និង ស៊ុំ សាវីណា**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ១២២ | យូ គុល | ប្រុស | ២៦ | ទាហានស័ក្តិបី |
| ១២៣ | សាត់ ហេហៀក | ប្រុស | ១១ | កម្មករកំពង់ផែភ្នំពេញ |
| ១២៤ | សូ សួន | ប្រុស | ១ | អនុក្រុម កងពល១៧០ ៣.៩.៧៦ |
| ១២៥ | មុក សារ៉ុង | ប្រុស | ? | នៅអគ្គការសហប្រជាជាតិ |
| ១២៦ | ជិន ប៉ោលាប | ប្រុស | ២៧ | ពាណិជ្ជកម្ម |
| ១២៧ | អ៊ឹង ដុយ | ប្រុស | ១ | ទាហានស័ក្តិបី |
| ១២៨ | វង់ សឿន | ស្រី | ២៥? | ប្រពន្ធគីម សាដូ ៨.១១.៧៦ |
| ១២៩ | ជា ត្រាន | ប្រុស | ? | ១៧០ |
| ១៣០ | ហ៊ីង សុខុម | ប្រុស | ៨ | គ្រូបង្រៀន |
| ១៣១ | កា សំអុន | ប្រុស | ២៥ | គ្រូបង្រៀន (អត់អាវ) |
| ១៣២ | គីម ភឿង | ប្រុស | ២៧ | ស័ក្តិបួន កាំភ្លើងធំ |
| ១៣៣ | ឌី ប៊ុនឡុង | ប្រុស | ? | ប្រេងកាត |
| ១៣៤ | គ្រួច ឃួន | ប្រុស | ២ | យុទ្ធជន កងពល ១៧០ |
| ១៣៥ | ម៉ុន ស៊ុនឃុន | ប្រុស | ៤ | ក១៥ |
| ១៣៦ | ជា ធន | ប្រុស | ១០ | ប្រធានពួក |
| ១៣៧ | សុក សារ៉ែន | ប្រុស | ៦ | ទាហានពលទោ |
| ១៣៨ | គីម ឈិត | ប្រុស | ៥ | ដ១ |
| ១៣៩ | អ៊ិន អ៊ឹម | ស្រី | ៧ | ប្រពន្ធ គ្រួសារកម្មករចាស់ |
| ១៤០ | លី យ៉េត | ស្រី | ៦ | ប្រពន្ធអា ម៉ាត់ |
| ១៤១ | ទូច សុត (ពេជ សុកហៀង) | ប្រុស | ២៣ | តំបន់២៥ |
| ១៤២ | គុយ ជា | ប្រុស | ៨ | និយាយវិទ្យុ |
| ១៤៣ | ប៉ាន់ ហួរ (ឈឹម) | ប្រុស | ? | ពោចិនតុង ប១ |
| ១៤៤ | អែម ចាន់ដារ៉ា | ស្រី | ២ | កូនកម្មករចាស់ |
| ១៤៥ | ដើម ដល្លី | ស្រី | ១ | ប,រ ចាន់ជាតិ (ជនជាតិ?) |
| ១៤៦ | ជា ឡុង | ស្រី | ១១ | ប្រពន្ធ ហោ ធួរេន ៩.១១.៧៦ |

| | | | | |
|---|---|---|---|---|
| ១៤៧ | ហែម ណែម (សរ) | ប្រុស | ? | ជនជាតិខ្មែរ |
| ១៤៨ | ហុង សឿន | ប្រុស | ២ | ទាហាន (ហុង សាភាព) |
| ១៤៩ | ថ្លុង ប៊ុនធឿន | ប្រុស | ៤ | ចោរព្រៃ |
| ១៥០ | ស៊ុំ ខន | ប្រុស | ៩ | ពាណិជ្ជកម្ម |
| ១៥១ | អ៊ឹម ជុន | ប្រុស | ១ | កងពល ១៧០ |
| ១៥២ | ទូន ភឿន | ប្រុស | ? | ស-២១យ ១១.៨.៧៦ |
| ១៥៣ | ខ្វីង ស៊ីហៀង | ប្រុស | ១៥ | ប្រពន្ធគូ ស៊ុម សូរ៉ុង ៣០.១១.៧៦ |
| ១៥៤ | ស៊ិន អៀង | ប្រុស | ១៩ | អាត់សាងដង់ (សំអាន) |
| ១៥៥ | ព្រាប រ៉េន | ស្រី | ១៤ | ប្រពន្ធអ៊ឹ លុន ៣០.១០.៧៦ |
| ១៥៦ | គីម ឡេង | ប្រុស | ៧ | កងពល៧០៣ បញ្ជាការ វ.ត |
| ១៥៧ | កែវ អេត | ស្រី | ? | កម្មករចាស់២.១១.៧៦? |
| ១៥៨ | ស៊ឹម សារ៉ុង | ប្រុស | ១ | រ.ច,៣ស២ (កែវ គុន) |
| ១៥៩ | គឹម លីងស្រ៊ុន | ប្រុស | ? | អនុកងហា ជាមពល ១១.៨.៧៦ |
| ១៦០ | កែវ បុល | ប្រុស | ៣ | អនុក្រុម ៨.១១.៧៦ (មានអក្សរនៅជញ្ជាំង) |
| ១៦១ | អ៊ឹម ស៊ុក | ស្រី | ៥៦ | ម្តាយ វង សឿន៨.១១.៧៦ |
| ១៦២ | វ៉ា ស្រេង | ប្រុស | ? | ពេទ្យ ស-២១យ |
| ១៦៣ | ស្រុន ហ៊ិន | ប្រុស | ១២ | រោងចក្រប្រេងកាត |
| ១៦៤ | សួន ពៅ | ស្រី | ? | ប្រ,ជផ្ទះ ១៣ |
| ១៦៥ | ថាស៊ី (ភា) | ប្រុស | ២០ | យុទ្ធជន៣១០ |
| ១៦៦ | កៅ យី | ប្រុស | ? | កង១១ (អាវផ្កា) |
| ១៦៧ | យូ ជនអេង | ប្រុស | ២៤ | យូ អេង |
| ១៦៨ | ម៉ាន ស៊ឹម ហៅ រៀម | ប្រុស | ៧ | មេក្រុម០១ |
| ១៦៩ | ជុំ កន | ប្រុស | ៩ | មេពួក២ |
| ១៧០ | នួន ខ្មោង | ប្រុស | ៣ | កៅស៊ូ |
| ១៧១ | ស៊ឹន អឿន | ប្រុស | ៤ | ជាងឈើ ១៣.១១.៧៦ |
| ១៧២ | យ៉ោក ព្រិល | ប្រុស | ៥ | ១៧០ |
| ១៧៣ | នាក់ ជួន | ប្រុស | ៧ | ឧស្សាហកម្ម |
| ១៧៤ | ញ៉ែម ណែន | ប្រុស | ១៨ | ប្រធានក្រឡឹង ១៨.១០.៧៦ |
| ១៧៥ | ស៊ុំ សាត | ប្រុស | ? | ពួកកង១៧០ |
| ១៧៦ | ភិន ភាព | ប្រុស | ១ | រោងប្រេងកាត |
| ១៧៧ | ហុង សុតសាក់ | ប្រុស | ១៧ | កម្មករចាស់ |
| ១៧៨ | ភួ យ៉ែម | ស្រី | ២៦ | ប្រពន្ធ វ៉ាល់ សប៊ុន ៨.១១.៧៦ |

| | | | | |
|---|---|---|---|---|
| ១៧៩ | រ៉ុង ឡេង | ប្រុស | ? | យុទ្ធជនកង១៣ថ្មី ៣.៨.៧៦ |
| ១៨០ | ឡៅ សាលី | ប្រុស | ? | ប្រ,ជ ផ្ទះ០៧ (ពុកមាត់) |
| ១៨១ | សុខ រស់ | ប្រុស | ១៣ | ទាហានស័ក្តិបី ៨.៩.៧៦ |
| ១៨២ | ឡុច ចំរើន | ប្រុស | ៣២ | កូនឡុច ឈុន ៣០.១០.៧៦ |
| ១៨៣ | អ៊ឹម សារ៉ែន | ប្រុស | ១៩ | យុទ្ធជន ៦.៩.៧៦ |
| ១៨៤ | ដេត គឹមណារី | ស្រី | ១៩ | ប្រពន្ធ អ៊ុច ម៉ឹងហេង ៨.១១.៧៦ |
| ១៨៥ | ឡុង ផាន សុវ៉ាន់ | ប្រុស | ១០ | នីរសារកងរយ ៥.៩.៧៦ |
| ១៨៦ | យ៉ុង សាវុធ | ប្រុស | ១៣ | អនុក្រុម |
| ១៨៧ | អ៊ុង សាវិន | ប្រុស | ? | រទេះភ្លើងគីឡូម៉ែត្រលេខ៦ |
| ១៨៨ | លិម ហួត | ប្រុស | ៧ | ប្រជាជនកម្មករនេសាទត្រី |
| ១៨៩ | អ៊ូ ឡាំឡាប | ប្រុស | ២ | ង. ០២.១ (?) |
| ១៩០ | ចាន់ យូរ៉ុន | ប្រុស | ៩ | គ្រូបង្រៀន ប្រហែលជាបងប្រុសរបស់ ចាន់ យូរ៉ាន់ |
| ១៩១ | អាំ វង់ | ប្រុស | ៨ | ទាហានស័ក្តិពីរ |
| ១៩២ | យ៉ឹម សារូន | ប្រុស | ៥ | យុទ្ធជន ៨.១១.៧៦ |
| ១៩៣ | លី ភាគរុន | ស្រី | ២២ | ប្រពន្ធ នៅ លីម អេង ២៨.១០.៧៦ |
| ១៩៤ | អឿង ហុយយូ | ប្រុស | ១ | ស័ក្តិមួយ ម៉ារីន |
| ១៩៥ | កែវ រុន | ប្រុស | ១២ | កម្មករថ្មី |
| ១៩៦ | សៅ រុន (ប្រឹក) | ប្រុស | ២ | បើកឡាន |
| ១៩៧ | ហេង ហ៊ួន | ប្រុស | ? | ទាហាន ព្រិនបាលឯក |
| ១៩៨ | ខៀវ វណ្ណថន | ប្រុស | ៥ | ទាហានស័ក្តិពីរ គាំផុន |
| ១៩៩ | ស៊ុម សាវុន | ប្រុស | ១០ | មេក្រុម១២ |
| ២០០ | នៅ គុយ | ប្រុស | ២ | សន្តិសុខជាតិ កំពង់សោម |
| ២០១ | ស៊ឹង សំអាន | ប្រុស | ៣ | វរសេនាតូច |
| ២០២ | ដួង ស្រេង | ប្រុស | ១ | ប១ ២៣.៧.៧៦ |
| ២០៣ | ឡើ ហ៊ួរ (ទិត) | ប្រុស | ? | ប្រជាជនតំបន់៣៥ |
| ២០៤ | ប៉ូល ហៀក | ប្រុស | ? | ពិសិត ស្នងការវរសេនាតូច |
| ២០៥ | ភោគ ម៉ុន | ប្រុស | ២ | កងពល ៣១០ |
| ២០៦ | ស្តើង គ្រឿន | ប្រុស | ៥ | អនុ វ,ត ១៧០ |
| ២០៧ | អ៊ូច ប៊ុនធឿន | ប្រុស | ៣ | យុទ្ធជន ១៣.១១.៧៦ |
| ២០៨ | ម៉ម មុត | ស្រី | ៧ | ប្រពន្ធឯម សេង ២៨.១០.៧៦ |
| ២០៩ | វ៉ាន់ សារ៉េន | ប្រុស | ២ | ស្នងការរយ |

**(នៅមានត)**



ថ្នាក់រៀននៅទួលស្លែងដែលបានធ្វើបទបង្ហាញដល់ភ្ញៀវទេសចររៀងរាល់ថ្ងៃ ច័ន្ទ ពុធ និងសុក្រ ។



លោកស្រី ម៉ាយូឡាំង ការ៉ុង ដែលជាកូនស្រីរបស់អ្ន
បាត់ខ្លួនកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧០ បានមកគោ



ក្រុមគម្រោង "ឃ្លាំមើលសាលាក្តីខ្មែរក្រហម" បានចុះទៅផ្សព្វផ្សាយដល់សាកលវិទ្យាល័យស្វាយរៀង កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ ។



ការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ខួបលើកទី៦៤ ថ្ងៃទី



គរុសិស្សមធ្យមសិក្សានៃសាលាគរុកោសល្យភូមិភាគខេត្តតាកែវ បានសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យអស់រយៈពេលប្រាំមួយថ្ងៃ ។



មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញអ្នកភូមិចំនួន៨
ដើងឯក និងសាលាក្តីខ្មែរក្រហមចាប់ពីថ្ងៃទី៨ ដល់ទី៦



ក្រុកថតរូបសារព័ត៌មានជនជាតិបារាំងមួយរូបដែលបាន
ារពវិញ្ញាណក្ខន្ធឪពុករបស់ខ្លួននៅកាលពីថ្ងៃទី១០ ខែធ្នូ ។



លោកស្រី ម៉ាយូឡាំង ការ៉ុង ឈរពីមុខរូបថតឪពុករបស់ខ្លួនឈ្មោះ ហ្ស៊ីល ការ៉ុង នៅបូជនីយដ្ឋានអ្នកសារព័ត៌មាន ទល់មុខសណ្ឋាគារ ឡឺ រ៉ូយ៉ាល់ កាលពីថ្ងៃទី១០ ខែធ្នូ២០១២ ។



ទី១០ ខែធ្នូ ឆ្នាំ២០១២ នៅសួនសេរីភាព ។



ក្រុមគម្រោង "ឃ្លាំមើលសាលាក្តីខ្មែរក្រហម" បានចុះទៅផ្សព្វផ្សាយដល់សាកលវិទ្យាល័យបៀលប្រាយ ក្នុងខេត្តរតនគិរីកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ ។



៩ នាក់ដើម្បីមកទស្សនាសារមន្ទីរទួលស្លែង វាលពិឃាត
ខែធ្នូ ឆ្នាំ២០១២ ។



មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកវេទិកាសាធារណៈមួយនៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើម្បីឲ្យមានការពិភាក្សាគ្នារវាងអ្នកធ្លាប់ឆ្លងកាត់របបខ្មែរក្រហម និងសិស្សានុសិស្សកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ ។

# តាំង គីម : ជីវិតកម្សត់ព្រៀវនិងការចង់បានយុត្តិធម៌ផ្ទាល់ខ្លួន

រស់នៅក្នុងផ្ទះដែលមិនទាន់សង់រួចរាល់មួយខ្នង ហ៊ុមព័ទ្ធជុំវិញដោយវាលស្រែ តាំង គីម កំពុងតែមានអារម្មណ៍រវើរវាយពីអតីតកាល ដោយបន្ទោសខ្លួនឯងទៅលើកម្មពៀរក្នុងជីវិតដែលគាត់គិតថានឹងត្រូវទទួលរងអស់មួយជីវិត ។ គីម មិនសូវមានសុខភាពមាំទាំប៉ុន្មានទេ ។ គាត់កំពុងតែរស់នៅក្នុងភាពខ្វះខាត និងភាពភ័យខ្លាច ហើយកំពុងតែតស៊ូដើម្បីរស់ ។ នៅក្នុងផ្ទះនោះ គាត់រស់នៅម្នាក់ឯងនៅពេលថ្ងៃ ហើយយប់ខ្លះ កូនប្រុសពៅរបស់គាត់ដែលបានរៀបការនិងរស់នៅក្បែរគាត់ បានមកស្នាក់នៅជាមួយគាត់យូរៗម្តង ។ ជីវិតរស់នៅរបស់ គីម មិនខុសអ្វីទៅនឹងរបបខ្មែរក្រហមប៉ុន្មានទេ ។

សព្វថ្ងៃមានអាយុ៥១ឆ្នាំ និងរស់នៅស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង គីម នៅតែចាំសម្តីរបស់ម្តាយគាត់ជារៀងរហូត នៅពេលមួយដែលគាត់កំពុងនៅលើភ្លៅម្តាយ ហើយម្តាយបាននិយាយដោយក្តីអាណិតអាសូរមកកាន់កូនថា "កូនម្តាយ កូនកើតមកមិនសូវមានសំណាងនឹងគេទេ ។ ម្តាយមិនដឹងថាកូននឹងអភ័ព្វប៉ុណ្ណាទេទៅថ្ងៃមុខ ។ ទោះបីជាជួបគ្រោះកម្មយ៉ាងណា កូនត្រូវតែទទួលយក ព្រោះនេះជាកម្មរបស់កូនពីជាតិមុន" ។

រាល់ថ្ងៃ អ្វីៗដែលនៅជុំវិញ គីម មិនសូវជាផ្តល់ភាពសុខសាន្តប៉ុន្មានទេ ។ រដូវភ្លៀងធ្វើឲ្យគាត់ព្រួយបារម្ភជាទីបំផុតព្រោះគាត់ខ្លាចសម្លេងផ្គរ ខ្លាចផ្លេកបន្ទោរ ខ្លាចសម្លេងរន្ទះនិងខ្លាចសម្លេងផ្ទុះដូចជាសម្លេងកាំជ្រួចជាដើម ។ គីម បិទប្រព័ន្ធទូរស័ព្ទរបស់គាត់ភ្លាម ពេលដែលមេឃចាប់ផ្តើមស្រទំរកកល់ចង់ភ្លៀង ។

គីម បាននិយាយថា "ខ្ញុំខ្លាចសម្លេងខ្លាំងៗ ។ ខ្ញុំមិនចង់ទៅបុណ្យណាដែលមានគេបាញ់កាំជ្រួចទេ ។ ពេលដែលគេបាញ់កាំជ្រួចម្តងៗ ខ្ញុំញ័រទ្រូងយ៉ាងខ្លាំង និងរត់ទៅពួនក្រោមតុ" ។

លើសពីនេះទៅទៀត គីម កំពុងតែរស់នៅជាមួយផលប៉ះទង្គិចផ្លូវចិត្តដែលគាត់បានជួបប្រទះកាលពីរបបខ្មែរក្រហមដែលគាត់ចាត់ទុកថាជារបបមួយព្រៃផ្សៃជាទីបំផុតក្នុងជីវិតរបស់



តាំង គីម នៅផ្ទះរបស់គាត់កាលពីខែតុលា ឆ្នាំ២០១២ កន្លងទៅ ។

គាត់ ។ ម៉្យាង គីម គិតថា បទពិសោធពីរបបខ្មែរក្រហមគឺជាកម្មពៀរវេរាដែលគាត់ត្រូវតែទទួលរង ដូចអ្វីដែលម្តាយរបស់គាត់និយាយប្រាប់គាត់ ។ ទោះបីជាហេតុការណ៍កាលនោះគឺជាបទពិសោធមួយដែលគាត់ឈឺចាប់យ៉ាងណាក្តី គីម បាននិយាយថា គាត់ត្រូវតែទទួលកម្មផលនេះ ។

ក្នុងឆ្នាំ១៩៧៤ ពេលដែលគាត់មានអាយុ១៨ឆ្នាំ គីម បានរៀបការជាមួយទាហាន លន់ នល់ ម្នាក់ ដែលកូនកម្លោះកំពុងតែជាប់ភារកិច្ចប្រាំងនៅឡើយពេលដែលពិធីមង្គលការហៀបនឹងចាប់ផ្តើម ។ ខណៈពេលដែល គីម កំពុងតែរង់ចាំវត្តមានរបស់អនាគតប្តីរបស់ខ្លួន ម្តាយរបស់ គីម បានប្រាប់គាត់ថា បើសិនជាប្តីរបស់ គីម មិនអាចមកបាន គីម និងត្រូវរៀបការជាមួយស្បែកជើងរបស់អនាគតប្តី ។ ជាភព្វសំណាង អនាគតប្តីរបស់គាត់បានមកដល់ផ្ទះការនៅពេលយប់មុនកម្មវិធីចាប់ផ្តើមបន្តិច ។ អនាគតប្តីរបស់គាត់បានមកដល់ទាំងកាយទទឹកជោគព្រោះគាត់បានរត់គេចពីសមរភូមិ និងហែលទឹកស្ទឹងដើម្បីមករៀបការ ។ ព្រឹកព្រហាមទៀបភ្លឺ ពិធីមង្គលការក៏ចាប់ផ្តើមឡើង ទាំង គីម មិនទាំងដឹងថា អ្វីជាស្នេហាផងនោះ តែគាត់ត្រូវតែរៀបការទៅតាមការផ្សំផ្គុំរបស់ឪពុកម្តាយ ។

ក្រោយពីរៀបការរួច គីម និងប្តីមិនដែលមានឱកាសរស់នៅជាមួយគ្នាពេញលេញជាប្តីប្រពន្ធទេ ។ ប្តីរបស់គាត់ត្រូវតែត្រឡប់ទៅកាន់សមរភូមិវិញក្រោយពីរៀបការរួចមួយថ្ងៃ ព្រោះពេលនោះ យោធាខ្មែរក្រហមកំពុងតែវាយសម្រុកខ្លាំងមកលើរដ្ឋាភិបាល លន់ នល់ ។ ក្រោយមកទៀត គីម ក៏មិនសូវមានឱកាសជួបប្តីច្រើនដែរ ដោយសារតែប្តីរបស់គាត់ជាប់ភារកិច្ចប្រយុទ្ធជាមួយខ្មែរក្រហម ។ គីម បានរៀបរាប់ថា «ខ្ញុំនិងប្តីខ្ញុំស្រលាញ់គ្នាដូចបងប្អូនអ៊ីចឹង យើងមិនដែលស្រលាញ់គ្នាជាប្តីប្រពន្ធទេ» ។

ជ័យជម្នះរបស់ខ្មែរក្រហមក្នុងខែមេសា ឆ្នាំ១៩៧៥ នាំមកនូវភាពទុក្ខសោកយ៉ាងខ្លាំងដល់ គីម ហើយទុក្ខសោកនោះនៅតែបៀមទុកក្នុងចិត្តគាត់ជានិច្ចនាពេលបច្ចុប្បន្ននេះ ។ គីម និងស្ត្រីប្រាំបីនាក់ ផ្សេងទៀតដែលសុទ្ធតែមានប្តីជាអតីតទាហាន លន់ នល់ ត្រូវបាននាំទៅសម្លាប់ ខណៈពេលដែលប្តីរបស់អ្នកទាំងនោះត្រូវបានសម្លាប់រួចហើយ រួមទាំងប្តីរបស់ គីម ផង ។ គីម ហើយនិងស្ត្រីទាំងប្រាំបីនាក់ត្រូវបានរំលោភមុននឹងសម្លាប់ចោល ។ ក្នុងចំណោមស្ត្រីទាំងនោះ គីម ជាមនុស្សតែម្នាក់គត់ដែលនៅរស់រានមានជីវិត ។ តែការដែលគាត់អាចរស់បាន គឺជារឿងដែលព្រឺព្រួចជាទីបំផុត ។ គីម បានរស់ជីវិតក្រោយពេលដែលយោធាខ្មែរក្រហមរំលោភគាត់រួចហើយ ។ ក្រោយមក នៅពេលដែលយោធាខ្មែរក្រហមកំពុងតែរំលោភស្ត្រីផ្សេងទៀត គីម ត្រូវបានយោធាខ្មែរក្រហមចិត្តធម៌ម្នាក់ជួយដោយលើកទឹកចិត្តឲ្យគាត់រត់គេចព្រោះបើរង់ចាំបន្តិចទៀត យោធាខ្មែរក្រហមនឹងមកសម្លាប់គាត់មិនខាន ។ គីម គេចខ្លួន និងរត់ចូលទៅពួនក្នុងបឹងព្រលិតមួយក្បែរកន្លែងសម្លាប់នោះ ។ ដោយភាពភ័យខ្លាច គីម បានពួននៅក្នុងទឹកអស់រយៈពេលបីថ្ងៃ ដោយមិនមានអាហារហូបចុកអ្វីទាំងអស់ ។ យោធាខ្មែរក្រហមដែលចង់សម្លាប់ គីម បានតាមរកគាត់គ្រប់ទីកន្លែង រួមទាំងរុករកនៅក្នុងបឹងដែលគាត់កំពុងតែពួនផង ។ គីម បានពួនដោយយកស្លឹកព្រលិតគ្របពីលើក្បាលនិងទប់ខ្លួនឲ្យនឹង ដើម្បីកុំឲ្យមានទឹករលក ក្រែងលោយោធាខ្មែរក្រហមទាំងនោះសង្ស័យ ។ ពេលមួយ យោធាខ្មែរក្រហមម្នាក់បានដើរចូលក្នុងបឹងព្រលិតនោះ ដែលសឹងតែជាន់ពីលើ គីម ទៅហើយ បើសិនជាឈានតែមួយជំហានទៀត ។

ក្រោយមក គីម ទៅរស់នៅក្នុងសហករណ៍ទាំងអារម្មណ៍ភ័យខ្លាចពេញមួយរបបខ្មែរក្រហមទាំងមូល ។

ភាពព្រឺព្រួចទាំងនេះធ្វើឲ្យជីវិតរបស់ គីម រស់នៅក្នុងភាពរវើរវាយ ភ័យខ្លាច និងឯកោពីអ្នកដទៃអស់រយៈពេលពីរទសវត្សរ៍ក្រោយមកទៀត ។ ដោយភាពអៀនខ្មាស គីម មិនដែលចែករំលែករឿងរ៉ាវជីវិតបែបនេះប្រាប់នរណាទេ រួមទាំងកូននិងប្តីក្រោយរបស់គាត់ផង ។ ទើបមកដល់ពាក់កណ្តាលទសវត្សរ៍៨០ ប្តីរបស់ គីម បានដឹងរឿងនេះហើយធ្វើឲ្យមានរង្គោះរង្គើនៅក្នុងគ្រួសាររហូតឈានទៅដល់ការលែងលះគ្នា ។ ចាប់តាំងពីពេលនោះមក គីម បន្តរស់នៅតស៊ូចិញ្ចឹមកូនបីនាក់តែម្នាក់ឯង ។ ភាពឈឺចាប់ផ្លូវចិត្តនិងការប៉ះទង្គិចអារម្មណ៍មិនទាន់បញ្ចប់ទេ ហើយ គីម ក៏មិនដឹងថាត្រូវដោះស្រាយដោយវិធីណាដែរ ។

ក្នុងឆ្នាំ២០០៣ គីម បានបួសជាដូនជីដើម្បីរំដោះខ្លួនពីកម្មពៀរដែលគាត់បានជួបប្រទះ ។ ការបួសជាដូនជីបានធ្វើឲ្យជីវិតគាត់ប្រសើរជាងមុនពេលដែលគាត់រស់នៅក្នុងវត្តអារាម ជាទីកន្លែងដែលគាត់ចាត់ទុកថា ជាទីស្ងប់ស្ងាត់បំផុត ។ ក្នុងឆ្នាំដដែល គីម ត្រូវ

បានផ្ញើសម្ភាសន៍និងថតនៅក្នុងខ្សែភាពយន្តមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា «វាលស្រែខ្មែរក្រហម ៖ រឿងរ៉ាវរបស់អ្នករួចរស់ជីវិតពីការរំលោភម្នាក់ឈ្មោះ តាំង គីម» ។ ក្នុងឆ្នាំ២០០៦ គីម បានលាចាកសិក្ខាបទពីដូនជី ។

នាពេលបច្ចុប្បន្ននេះ គីម ឋិតក្នុងសភាពស្គមស្គាំង និងខ្សោយ ។ ប៉ុន្តែ គាត់នៅតែចង់បានយុត្តិធម៌ពីអ្វីដែលគាត់បានបាត់បង់ ។ តុលាការខ្មែរក្រហមធ្វើឲ្យគាត់ពេញចិត្ត ទោះបីជាពេលខ្លះគាត់គិតថា តុលាការខ្មែរក្រហមមិនបានយកចិត្តទុកដាក់លើសុខភាពជនរងគ្រោះដូចការយកចិត្តទុកដាក់លើសុខភាពរបស់ជនជាប់ចោទក៏ដោយ ។ គីម បានចូលរួមស្តាប់សវនាការពីរបីដង តែសុខភាពរបស់គាត់មិនអំណោយផលទេ «ពេលដែលខ្ញុំត្រលប់មកផ្ទះវិញ ខ្ញុំឈឺបួនប្រាំថ្ងៃរាល់លើក ។ គ្មាននរណាថែទាំខ្ញុំទេ ។ តែខ្ញុំចង់ឃើញតែម្យ៉ាងគត់គឺភាពយុត្តិធម៌» ។

នៅពេលដែលមេដឹកនាំជាន់ខ្ពស់កំពុងតែត្រូវបានចោទប្រកាន់នៅក្នុងតុលាការខ្មែរក្រហម អ្នកបានរំលោភគីម កាលពីជិត៤០ឆ្នាំមុនកំពុងតែមានសេរីភាពដូចប្រជាជនកម្ពុជាឯទៀតដែរ ។ គីម បាននិយាយថា បើសិនជាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមយកអតីតកម្មាភិបាលខ្មែរក្រហមមកកាត់ទោស គាត់នឹងពេញចិត្តជាងនេះ ។

សព្វថ្ងៃ គីម បូជាកម្លាំងកាយចិត្តដើម្បីពុទ្ធសាសនា ។ គាត់បានចំណាយពេលពេញមួយព្រឹកនៅក្នុងវត្ត បោសសំអាតវត្ត បម្រើព្រះសង្ឃ ដើម្បីឲ្យគាត់អាចរួចពីការឈឺចាប់ផ្លូវចិត្តដែលគាត់កំពុងតែជួបប្រទះ ។ គីម កាន់សីលប្រាំបីយ៉ាងខ្ជាប់ខ្ជួន ។ ទោះបីជាគាត់ប្រកាន់ខ្ជាប់នូវគោលការណ៍នេះក៏ដោយ គីម សឹងតែមិនអាចរស់នៅដោយសុខសាន្តក្នុងចិត្តបាន ។ អ្នកដែលធ្វើបាបគាត់ពីអតីតកាលរស់នៅមិនឆ្ងាយពីផ្ទះរបស់គាត់ប៉ុន្មានទេ ។ សំឡេងវន្ទះ និងសំឡេងស្រែកខ្លាំងៗគឺជាសត្រូវរបស់គាត់ ដែលមិនអាចជៀសវាងបានទេនៅក្នុងជីវិតប្រចាំថ្ងៃរបស់គាត់ ។ **ញាណ សុជាតិ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**



# មាស វឿន អតីតអនុប្រធានកងពលទី១ ទទួលស្គាល់ការបោសសម្អាតនៅក្នុងរបបខ្មែរក្រហម

មាស វឿន ជាអតីតអនុប្រធានកងពលទី១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំបានជួប និងសម្ភាសន៍គាត់លើកដំបូងនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ ដោយពេលនោះគាត់ជាគ្រិស្តសាសនិកនៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ វឿន មានមាឌធំ រហ័សរហួន ទឹកមុខមាំ និងសម្ដីខ្លាំងៗ ដែលស័ក្ដិសមនឹងតួនាទីរបស់គាត់ជាអតីតមេបញ្ជានៃកងយោធាខ្មែរក្រហម ។ វឿន បានដឹងរឿងរ៉ាវជាច្រើនទាក់ទងទៅនឹងរចនាសម្ព័ន្ធការងារក្នុងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និងការបោសសម្អាតចុងក្រោយនៅតំបន់ព្រះវិហាររួមមាន ប្រជាជន មន្ត្រីរាជការ ទាហាន ដែលជម្លៀសទៅតំបន់នោះ ។

វឿន ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកោះអញ្ជើញឲ្យមកផ្ដល់សក្ខីកម្មនៅអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២ ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ស្របពេលមានការចោទប្រកាន់ពីឧក្រិដ្ឋកម្ម "ការកាប់សម្លាប់មន្ត្រីរាជការក្នុងរបបចាស់" ស្ថិតនៅទួលពោធិ៍ជ្រៃ ខេត្តព្រះវិហារ បន្ថែមក្នុងសំណុំរឿង លើអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។

មាស វឿន មានស្រុកកំណើតនៅភូមិស្រែខ្ទុង ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ វឿន បានរៀនដល់ថ្នាក់ទី៨ក្នុងសម័យសង្គមរាស្ត្រនិយម ហើយគាត់ក៏បានចូលបួសរយៈពេលប្រាំវស្សានៅវត្តព្រៃនាថ ។ ក្រោយពីលាចាកសិក្ខាបទនៅឆ្នាំ១៩៦៨ វឿន បានចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហម ក្នុងគោលបំណងរំដោះប្រទេសជាតិចេញពីរបបមូលធន ជិះជាន់ និងកេងប្រវ័ញ្ច ។ ដំបូងគាត់ចូលធ្វើការក្នុងកងយុវជនការពារ ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន និង នង សួន ដែលត្រូវបានរដ្ឋាភិបាលជំនាន់នោះចោទប្រកាន់



មាស វឿន ថតនៅខែតុលា ឆ្នាំ២០១០ នៅឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

ហើយបានរត់ចូលមកតស៊ូនៅក្នុងព្រៃ ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ វឿន បានចូលទៅនៅក្នុងភូមិវិញ ប៉ុន្តែត្រូវបានរដ្ឋាភិបាលសាធារណរដ្ឋខ្មែរចោទប្រកាន់គាត់ថា បានបម្រើការងារឲ្យខ្មែរក្រហម ព្រោះគាត់នៅមានទំនាក់ទំនងជាមួយ ហ៊ូ យន់ និង ខៀវ សំផន ។ នៅក្នុងហេតុការណ៍នោះ បងប្រុសរបស់ វឿន ឈ្មោះ អ៊ុន មានអាយុ៣០ឆ្នាំ ត្រូវទាហានរដ្ឋាភិបាលចាប់យកទៅសម្លាប់នៅឃុំអូរ ជាមួយប្អូនប្រុសម្នាក់ទៀតរបស់គាត់ ។ ដោយឡែក ឪពុកមារបស់គាត់ម្នាក់ក៏ត្រូវបានចាប់ខ្លួនដែរ ដោយរដ្ឋាភិបាលចោទថា “កាន់និន្នាការខ្មែរក្រហម” ។

ដោយបារម្ភពីសុវត្ថិភាព វឿន បានចេញទៅព្រៃម្តងទៀត ព្រោះគាត់ខ្លាចគិញសម្ងាត់របស់ លន់ នល់ ចាប់ខ្លួន ។ នៅពេលនោះ វឿន បានធ្វើជានីរសារ និងធ្វើជាកងការពារឲ្យកម្មាភិបាលខ្មែរក្រហមដែលដើរទាក់ទងគ្នាដើម្បីធ្វើការប្រជុំដែលមានទីតាំងនៅក្នុងខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។ ការងារនេះ វឿន ត្រូវធ្វើដោយសម្ងាត់បំផុត និងត្រូវដើរក្នុងព្រៃតែម្តង ។ វឿន បានទទួលការងារមួយទៀតគឺ ចាំទទួលកម្មាភិបាលតស៊ូខ្មែរក្រហមដែលនីរសារក្រុងភ្នំពេញរបស់ វន វេត (កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមឃោសនាសម្ងាត់នៅក្នុងក្រុង) នាំមកប្រគល់ឲ្យគាត់នៅតាមដងផ្លូវជាតិលេខ៤ ដើម្បីឲ្យគាត់ជូនដំណើរបន្តចូលទៅព្រៃ ។

ចំណែករដ្ឋាភិបាល លន់ នល់ ក៏ចាប់ផ្តើមកែលម្អភូមិមួយចំនួនធ្វើជាភូមិយុទ្ធសាស្ត្រក្នុងគោលបំណងទប់ស្កាត់មិនឲ្យខ្មែរក្រហមចូលមកឃោសនា ដោយដាក់ប៉ូលីស ទាហាន យាមការពារទាំងយប់ទាំងថ្ងៃ ។ ដូច្នេះកងទ័ពរំដោះខ្មែរក្រហមត្រូវរង់ចាំរហូតដល់ពេលដែលកងឈ្លបរបស់ខ្លួនមកប្រាប់ថា អាចចូលបានទើបហ៊ានលួនចូលទៅជួបទាក់ទងជាមួយប្រជាជននៅក្នុងភូមិ ។ ប៉ុន្តែ ការជួបនោះ មានរយៈពេលប្រហែលតែ១០ទៅ២០នាទីប៉ុណ្ណោះ ព្រោះខ្លាចកងទ័ពរបស់ លន់ នល់ ដឹង និងចាប់ខ្លួនបាន ។

នៅពាក់កណ្តាលឆ្នាំ១៩៧០ ខ្មែរក្រហមបង្កើតទ័ពបានពីរកងវរសេនាតូច និងមានកាំភ្លើងប្រមាណ១០ទៅ២០ដើមប៉ុណ្ណោះ គ្រប់គ្រងដោយ សឿង ។ តួនាទីរបស់យោធាទាំងនេះ គឺការពារកម្មាភិបាល សាស្ត្រាចារ្យ និងអ្នកស្នេហាជាតិ ដែលរត់ចូលមកតស៊ូក្នុងព្រៃ ។ ប៉ុន្តែស្របពេលនោះ រដ្ឋាភិបាល លន់ នល់ ក៏បានចាប់ផ្តើមធ្វើការរឹតបន្តឹងរាល់ការចេញចូល ការទាក់ទង និងបានបិទផ្លូវសេដ្ឋកិច្ចតាមភូមិឃុំ និងស្រុក ធ្វើឲ្យអ្នកតស៊ូនៅក្នុងក្រុង និងនៅក្នុងព្រៃមួយចំនួនបានដាច់ខ្សែរយៈទាក់ទង ។ ទោះបីមានការទប់ស្កាត់យ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមនៅតែកសាងបានកម្លាំងប្រដាប់អាវុធ និងពង្រីកមូលដ្ឋានរំដោះបានថែមទៀត ។ ចំណែក វឿន នៅពេលនោះ បានផ្លាស់មកខេត្តកំពង់ឆ្នាំង ដោយគាត់បានធ្វើការជាប់ជាមួយ ចេង អន ដែលគ្រប់គ្រងផ្នែកពាណិជ្ជកម្មរដ្ឋ ។

មួយរយៈខ្លីក្រោយមក ខ្មែរក្រហមពង្រីកទ័ពបានបីកងវរសេនាតូច និងបង្កើតទៅជាកងពល គឺកងពលទី១ ដែលមាន សឿង ជាប្រធាន និង វឿន ជាអនុប្រធានកងពល មានមូលដ្ឋាននៅខេត្តកំពង់ឆ្នាំង ។ នៅក្នុងអំឡុងពេលគ្រប់គ្រងកងទ័ព វឿន បានដឹកនាំកម្លាំងឡើងទៅវាយប្រយុទ្ធជាមួយកងទ័ព លន់ នល់ នៅសមរភូមិបឹងប្រយ៉ាប ព្រែកត្នោត កំពង់ហ្លួង ឧត្តុង្គ លង្វែក ពន្លៃ ខេត្តកំពង់ឆ្នាំង រហូតដល់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។ ចំណែក កងទ័ពរបស់ លន់ នល់ ដឹកនាំដោយឧត្តមសេនីយ៍ អ៊ឹ សាវុធ ជាមួយនឹងទ្រង់ ច័ន្ទរង្សី បានបើកការវាយលុកយ៉ាងខ្លាំងក្លាទៅលើខ្មែរក្រហមចាប់តាំងពីសមរភូមិឧត្តុង្គ រហូតដល់ស្រុកបរិបូណ៌ ។ ប៉ុន្តែមិនបានធ្វើឲ្យយោធាខ្មែរក្រហមថមថយកម្លាំងនោះទេ គឺកងយោធាដែលដឹកនាំដោយ សឿង និង វឿន រក្សាបានទីតាំងឈរជើងនៅដដែល ។

នៅឆ្នាំ១៩៧៥ វឿន បានទទួលបញ្ជាពីថ្នាក់លើឲ្យវាយយកទីក្រុងភ្នំពេញ ឬហៅថា សមរភូមិ៩៩០ ឲ្យបាននៅថ្ងៃទី១៨ ខែមេសា ប៉ុន្តែដោយសារភាពអង់អាចរបស់កងយោធាទាំង១២កងពល ទើបខ្មែរក្រហមវាយយកទីក្រុងភ្នំពេញបាននៅវេលាម៉ោងប្រមាណ៩ព្រឹក ថ្ងៃទី១៧ ខែមេសា គឺមួយថ្ងៃមុនផែនការកំណត់ ។ វឿន ឃើញទាហាន លន់ នល់ ឈរស្មៀមជាមួយឯកសណ្ឋានយោធា ប៉ុន្តែមិនមានកាន់អាវុធនៅដៃទេ ចំណែកប្រជាជនបាននាំគ្នាចង “ទង់ស” នៅតាមផ្ទះរៀងៗខ្លួន ហើយកងទ័ពខ្មែរក្រហមក៏ចាប់ផ្តើមធ្វើការប្រមូលអាវុធ ។

នៅក្រុងភ្នំពេញ វឿន បានជួបមេបញ្ជាការកងទ័ពខ្មែរក្រហមជាច្រើននៅក្នុងកិច្ចប្រជុំកងទ័ពដែលប្រារព្ធធ្វើនៅស្តាតអូឡាំពិក រួមមាន ឈុក និង វ៉ែន (កូនប្រសារ តាម៉ុក) បញ្ជាការកងទ័ពជើងគោក, ស៊ូ ម៉េត និង ល្វៃ បញ្ជាការកងទ័ពជើងអាកាស, មុត

(កូនប្រសារ តាម៉ុក) និង សារឿន (ត្រូវជាបងប្អូនជីដូនមួយរបស់គាត់) បញ្ជាការកងទ័ពជើងទឹក ព្រមទាំងបានជួបមេបញ្ជាការ និងកម្មាភិបាលក្រសួងជាច្រើនរូបទៀត ។ ប៉ុន្តែក្រោយមកបងប្អូនជីដូនមួយរបស់ វឿន រួមមាន សារឿន, ពីន (ដែលគាត់ជួបដំបូងបង្អស់នៅខេត្តកំពង់ឆ្នាំង) និងសមមិត្តនារី អៀវ ជាកម្មាភិបាលធ្វើការជាមួយ នង សួន ត្រូវខ្មែរក្រហមចាប់ខ្លួន និងសម្លាប់ចោលទាំងអស់ ។

មួយសប្តាហ៍ក្រោយពីទទួលជ័យជម្នះ អង្គការបានដក វឿន ឲ្យទៅនៅបែកចាន រួចហើយក៏បញ្ជូនបន្តទៅកំពង់ត្រាច ខេត្តកំពត ដើម្បីយាមការពារផ្លូវរទេះភ្លើង ។ នៅឆ្នាំ១៩៧៥ដដែល អង្គការបានផ្លាស់ វឿន ឲ្យទៅប្រចាំការនៅខេត្តកោះកុង ។ វឿន បានដឹកនាំកម្លាំង៣.០០០នាក់ ដើម្បីយាមការពារព្រំដែនសមុទ្រនៅខេត្តកោះកុង រួមមាន កោះយ៉ កោះមូល និងកោះចាំយាម ។

ក្នុងអំឡុងពេលនោះ កងទ័ពរបស់ វឿន បានប៉ះទង្គិចជាមួយកងទ័ពថៃអស់រយៈពេលជាងមួយសប្តាហ៍ រហូតដល់មានការប្រើប្រាស់យន្តហោះទម្លាក់គ្រាប់បែកធ្វើការវាយប្រហារគ្នា ដោយសារមូលហេតុថៃចូលមកឆ្ការព្រៃដើម្បីដាក់របងលួស និងចាប់ត្រីក្នុងដែនសមុទ្រខ្មែរ និងលួចចូលមកស៊ើបការណ៍នៅលើកោះខ្មែរ ។ ប៉ុន្តែ វឿន បានទទួលបញ្ជាពី សុន សេន ឲ្យអត់ធ្មត់ ស្ងៀមស្ងាត់ និងកុំឲ្យតបតជាមួយកងទ័ពថៃដែលនាំប្រទេសថៃយល់ថាខ្មែរក្រហមជាអ្នកបង្កសង្គ្រាម ។ ដោយឡែក សុន សេន ណែនាំគាត់ឲ្យខិតខំការពារទឹកដីនិងពង្រឹងទាំងផ្នែកជើងទឹក ជើងគោក និងជើងអាកាស កុំឲ្យខ្មាំងរំលោភឈ្លានពាន រីឯបញ្ហាខ្សែព្រំដែនមិនមានទំនាស់នោះទេ ។

ក្នុងអំឡុងពេលប៉ះទង្គិច សុន សេន មិនបានចុះមកបញ្ជាផ្ទាល់ទេ គឺគាត់ទាក់ទងមក វឿន តាមរយៈទូរលេខ និងវិទ្យុទាក់ទង ឬឲ្យប្រធានកងពល (សឿង) ទៅជួបគាត់ក្នុងរយៈពេលមួយសប្តាហ៍ ឬមួយខែម្តង ឬតំណាងភូមិភាគបស្ចិម ចុះទៅជួបគាត់ផ្ទាល់តែម្តង ។ សុន សេន ក៏បញ្ជាឲ្យគាត់ទប់ស្កាត់អ្នកដែលរត់ឆ្លងទៅថៃ ហើយត្រូវរាយការណ៍ ។ បន្ទាប់ពីទទួលបញ្ជានោះ វឿន ចាប់បានទូក និងកាណូតរបស់ជនជាតិវៀតណាមខាងត្បូងជាច្រើនគ្រឿងនិងមនុស្សរាប់រយនាក់ ដែលមានបំណងរត់ទៅថៃ និងបន្តទៅរស់នៅប្រទេសអាមេរិក ដោយចាប់បញ្ជូនទៅសេនាធិការដែលមានមូលដ្ឋាននៅកំពង់សោម ។ វឿន មិនដឹងថាជនជាតិវៀតណាមដែលកងទ័ពរបស់គាត់ចាប់បានត្រូវអង្គការដោះស្រាយយ៉ាងណានោះទេ ព្រោះមានតំណាងខាងក្រសួងការងារបរទេសវៀតណាមមកជួបចរចាគ្នា ។

ក្រោយមកទៀត មានសភាពការណ៍ប៉ះទង្គិចគ្នារវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាម នៅតាមបណ្តោយព្រំដែនខេត្តតាកែវ ព្រៃវែង ស្វាយរៀង និងមណ្ឌលគិរីបានផ្ទុះឡើង និងចាប់ផ្តើមវាយប្រយុទ្ធគ្នាខ្លាំងនៅស្រុកស្នួល ខេត្តក្រចេះ និងខេត្តកំពង់ចាម ។ វឿន បានបញ្ជូនកម្លាំងរបស់គាត់យ៉ាងសន្ធឹកសន្ធាប់ទៅសមរភូមិនោះ ដោយ នៅសល់កងទ័ពប្រមាណ៥០០នាក់ប៉ុណ្ណោះ យាមការពារនៅតាមបណ្តោយព្រំដែនភាគខាងលិច ។

នៅខែសីហា ឆ្នាំ១៩៧៨ ប៉ុល ពត បានហៅ វឿន មកជួបនៅវត្តខណ្ឌលោម ដើម្បីចាត់តាំងគាត់ទៅរៀបចំប្រជាជននៅខេត្តព្រះវិហារ ដោយសារតែមានការបោសសម្អាត និងការចាប់ខ្លួនប្រជាជនយ៉ាងច្រើននៅទីនោះ ។ វឿន បានបង្ហាញពីភាពស្ទាក់ស្ទើរនៅចំពោះមុខ ប៉ុល ពត ពេលគាត់ឮពីការចាប់ខ្លួន ប៉ុន្តែ ប៉ុល ពត បានលើកឡើងថា «បើបក្សសំណូមពរហើយ ត្រូវតែទៅ» ។

ប៉ុល ពត បានពន្យល់ វឿន រយៈពេលបីម៉ោងពីសភាពការណ៍ដែលកងទ័ពវៀតណាមវាយ នៅតាមបណ្តោយព្រំដែន និងពីសភាពការណ៍នៅតំបន់ព្រះវិហារ ដែលកំពុងតែមានការចាប់ខ្លួនប្រជាជនកាន់តែច្រើនឡើង ។ ប៉ុល ពត បានបញ្ជា វឿន ឲ្យទៅពិនិត្យមើលការចាប់ប្រជាជនដោយសារមូលហេតុអ្វី? និងបញ្ជាឲ្យដោះអ្នកទោសនៅសៀមរាប ។ ប៉ុន្តែពេលនោះ ប៉ុល ពត មិនបានឲ្យ វឿន នាំកងទ័ពទៅជាមួយទេ គឺឲ្យកងការពារប្រមាណ២០នាក់ប៉ុណ្ណោះទៅការពារគាត់ ហេតុដូច្នេះហើយទើបធ្វើឲ្យគាត់មានការភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួន ។

ស្របពេលនោះដែរ វឿន បានឮដំណឹង ខៀវ សំផន និង នួន ជា គ្រោងធ្វើរដ្ឋប្រហារ ព្រោះព្រះវិហារជាតំបន់ស្វយ័តរបស់គាត់ទាំងពីរនាក់គ្រប់គ្រង ហើយអំណាចរបស់អង្គការ ព្រមទាំងសម្ភាររួមមាន មុង ភួយ ស្ករស ទឹកដោះគោ របស់របរហូបចុក ថ្នាំពេទ្យច្រើនលើសលប់ត្រូវបានផ្តល់ទៅតំបន់នោះ ប៉ុន្តែរបស់ទាំងនោះមិនបានទៅដល់ដៃអ្នកស្រុកទេ ។

វឿន មិនស្គាល់ភូមិសាស្ត្រនៅព្រះវិហារទេ ដូច្នេះគាត់ត្រូវ

មើលផែនទី និងមើលតាមត្រីវិស័យ ។ ទៅដល់ដំបូង វឿន ឃើញមន្ទីរខេត្តត្រូវបានរើរុះ ហើយខណៈពេលនោះគាត់ក៏ទៅធ្វើការ និងរស់នៅជាមួយប្រជាជននៅស្រុករវៀង ។ នៅទីនោះ វឿន បានឃើញពីការលំបាក និងការខ្វះខាត (បាយហូប) និងឃើញមានការចាប់ខ្លួនប្រជាជនយ៉ាងច្រើន ហើយសូម្បីតែឮសូរសំឡេងរថយន្តក៏ប្រជាជនមានការភ័យខ្លាចដែរ ។ វឿន បានសួរអ្នកស្រុកថា នៅវិទ្យាល័យ គ្រូទៅណាអស់ហើយ? ប្រជាជនប្រាប់ថា ជម្លៀសចេញអស់ហើយ ។ វឿន សួរបន្តថា ចុះផ្ទះធំៗរបស់ប្រជាជនទៅណា? អ្នកនៅទីនោះតបថា រុះរើចេញអស់ហើយដែរ ។ ឮដូច្នេះ វឿន ដើរស្រាវជ្រាវរកឃើញឈ្មោះ ព្រំ ស៊ូ កំបុតដៃ ជាគ្រូបង្រៀន និងបានដើរប្រមែប្រមូលប្រជាជនពីក្នុងព្រៃ និងអ្នកទទួលខុសត្រូវសហករណ៍ឲ្យមករស់នៅក្នុងភូមិវិញ ។

នៅពេលនោះ មានប្រជាជនម្នាក់ដែលជម្លៀសទៅពីភ្នំពេញ ហើយដែលធ្លាប់ស្គាល់ វឿន បានប្រាប់ វឿន ថាកម្មាភិបាលនៅទីនោះបានរករឿងគាត់ ប៉ុន្តែគាត់ខំទ្រាំរស់ ។ គាត់បាន សំណូមពរឲ្យ វឿន រៀបចំការរស់នៅដោយឲ្យធ្វើស្រែ និងឲ្យហូបតាមផលស្រូវដែលធ្វើបានទោះបីមិនមានប្រព័ន្ធប្រឡាយក៏ដោយ ។ សំណូមពរនេះស្របទៅនឹងបទបញ្ជារបស់ ប៉ុល ពត ដែលបានលើកឡើងពេល វឿនជួបគាត់នៅវត្តខណ្ឌលោម គឺទី១) រៀបចំឲ្យប្រជាជនធ្វើស្រែ ហើយឲ្យប្រជាជនហូបខ្លួនឯង និងទី២ ) ត្រូវរៀបចំធ្វើផ្ទះឲ្យប្រជាជនស្នាក់នៅ ។

វឿន បានសាងសង់ផ្ទះឲ្យប្រជាជនបានប្រមាណ៣០ខ្នង ក្នុងរយៈពេលតែបួនខែប៉ុណ្ណោះ ក៏កងទ័ពវៀតណាមចូលមកដល់ ។ វឿន បានរត់ឡើងភ្នំដងរែក ខេត្តឧត្តរមានជ័យ ជាមួយកងទ័ពប្រមាណជាង៧.៧០០នាក់ ។ បន្ទាប់មក វឿន បានដឹកនាំកម្លាំងទាំងនោះចូលរួមជាមួយ សុខ ភាព ប្រធានកងពល៤៥០ នៅម៉ាឡៃ ហើយកម្លាំងមួយទៀត អង្គការបញ្ចូលទៅក្នុងកងពលនៅប៉ៃលិន ក្រោមការគ្រប់គ្រងរួមរបស់ អៀង សារី ។ ក្រោយមកដោយសារកងពល៥១៩ របស់ ឌុល សារឿន ដែលឈរជើងនៅសមរភូមិខាងជើងស៊ីសុផុន រួមមាន ស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ មិនមានអ្នកតស៊ូដើងចាស់ដឹកនាំ ទើប វឿន ទៅធ្វើជាជំនួយការនៅក្នុងកងពលនោះ ។ ប៉ុន្តែមួយរយៈខ្លីក្រោយមកដោយសារ វឿន មានរបួស និងមិនអាចធ្វើការបាន ទើបគាត់សុំ អៀង សារី លាឈប់ពីតួនាទីកងទ័ព ហើយ អៀង សារី ក៏ចាត់ឲ្យគាត់ទៅគ្រប់គ្រងប្រជាជន នៅជំរំតាង៉ុក (ជំរំទី៨) ។

ក្រោយពេលសមាហរណកម្មឆ្នាំ១៩៩៦ វឿន ក៏ត្រឡប់មករស់នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យវិញ តាមរយៈអង្គការទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ ។ បន្ទាប់មក វឿន បាន ចូលជាគ្រិស្តសាសនិក ហើយនៅពេលនោះគាត់ក៏បានជួប កាំង ហ្កេចអ៊ាវ ហៅ ឌុច (ប្រធានមន្ទីរស-២១) ដែលជាអ្នកជឿព្រះគ្រិស្តដូចគាត់ដែរ តាមរយៈគ្រូគង្វាលរស់នៅក្នុងឃុំផ្គាំ ស្រុកស្វាយចេក ។



មាស វឿន ពេលធ្វើសក្ខីកម្មនៅសាលាក្តីខ្មែរក្រហមកាលពីខែតុលាកន្លងទៅ

វឿន បានទទួលស្គាល់ការកាប់សម្លាប់នៅក្រោមរបបខ្មែរក្រហម និងនៅតំបន់ព្រះវិហារ ក្នុងអំឡុងពេលគាត់ធ្វើជាមេបញ្ជាការកងទ័ព និងក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ។ ប៉ុន្តែ គាត់ក៏បានអះអាងពីការខិតខំប្រឹងប្រែងក្នុងការជួយដោះលែងអ្នកទោស ការកែប្រែរបៀបរបបការងារ និងការធ្វើឲ្យជីវភាពប្រជាជនបានប្រសើរជាងមុន ។

**សោម ប៊ុនថន**

# អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចបិទផ្លូវតវ៉ាទាក់ទងនឹងការខ្វះសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ។ កាលពីខែកញ្ញា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចជាលើកទីពីរថា ជនជាប់ចោទ អៀង ធីរិទ្ធ ដែលស្ថិតក្នុងវ័យ៨០ឆ្នាំ ត្រូវដោះលែងចេញពីមន្ទីរឃុំឃាំងដោយឥតលក្ខខណ្ឌ បន្ទាប់ពីរកឃើញថាជនជាប់ចោទពុំមានសម្បទាខាងបញ្ញាស្មារតីក្នុងការចូលរួមការជំនុំជម្រះ ដោយសារតែជំងឺវង្វេងវង្វាន់ស្មារតី ដែលទំនងបណ្តាលមកពីជំងឺភ្លេចភ្លាំងចេះតែវិវឌ្ឍធ្ងន់ធ្ងរទៅៗ ។ ដោយសារតែសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចទាក់ទងតែលក្ខខណ្ឌក្នុងការដោះលែងជនជាប់ចោទ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតភ្លាមៗឲ្យដោះលែងជនជាប់ចោទពីការឃុំឃាំងដោយស្ថិតក្រោមលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួន ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចពីភាពសមរម្យនៃការដាក់ជនជាប់ចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ នៅពេលដែលការរំពឹងទុកយ៉ាងធ្ងន់ប្រហែលថាជនជាប់ចោទ អៀង ធីរិទ្ធ នឹងមិនអាចយកមកជំនុំជម្រះបានតទៅទៀត ។

អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌលើកទីមួយនៅខែវិច្ឆិកា ឆ្នាំ២០១១ បន្ទាប់ពីបានរកឃើញថា ជនជាប់ចោទពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ដោយបំបែកបទចោទប្រកាន់ចេញពីសំណុំរឿង០០២ និងផ្អាកនីតិវិធីប្រឆាំងនឹងជនជាប់ចោទរូបនេះ ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូល ដែលបង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទក្នុងរយៈពេល៦ខែទៀត ដើម្បីឲ្យប្រឹងប្រែងក្នុងការប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវវិធានការទាំងឡាយដែលមានក្នុងការជួយជនជាប់ចោទឲ្យមានភាពប្រសើរឡើង ដើម្បីអាចចូលរួមការជំនុំជម្រះបាន ។



អៀង ធីរិទ្ធ នៅក្នុងបន្ទប់សវនាការ

ក្នុងខែសីហា ឆ្នាំ២០១២ អ្នកជំនាញបីរូប បានផ្តល់សក្ខីកម្មថា ស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ធ្លាក់ដុនដាបជាលំដាប់ ។ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា ពុំមានការរំពឹងសមហេតុសមផលដែលថាការធ្លាក់ចុះខ្សោយផ្នែកបញ្ញាស្មារតី អាចត្រូវបានធ្វើឲ្យប្រសើរឡើងវិញបានទេ ហើយថាបើទោះបីជាមិនលើកចោលបទចោទប្រកាន់ក៏ដោយ គឺត្រូវផ្អាកកិច្ចដំណើរការនីតិវិធីដោយមិនកំណត់រយៈពេលប្រឆាំងនឹងជនជាប់ចោទ «ដែលមានន័យថា ការផ្អាកកិច្ចដំណើរការនីតិវិធីត្រូវបន្តដរាបណាអង្គជំនុំជម្រះបង្គាប់ឲ្យមានការជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទ» ។ អង្គជំនុំជម្រះសម្រេចថា ដោយសារតែការផ្អាកកិច្ចដំណើរការនីតិវិធីមានមានលក្ខណៈជាអចិន្ត្រៃយ៍ «ខ្លួនមិនអាចអនុវត្តនូវយុត្តាធិការលើជនជាប់ចោទសម្រាប់រយៈពេលណាមួយនៃការផ្អាកនោះបានទេ» ហើយថាខ្លួនពុំមានមូលដ្ឋានផ្លូវច្បាប់ច្បាស់លាស់ក្នុងការសម្រេចដាក់លក្ខខណ្ឌដោយបន្ទុកឬក៏ដាក់ឲ្យស្ថិតក្រោមទម្រង់ផ្សេងៗនៃការត្រួតពិនិត្យតាមផ្លូវតុលាការ លើជនជាប់ចោទក្នុងអំឡុងពេលនេះ ។ ហេតុដូច្នេះ ខ្លួនបង្គាប់ឲ្យដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ ក៏ប៉ុន្តែស្នើសុំឲ្យជនជាប់ចោទស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជូនដំណឹងដល់តុលាការក្នុងពេលណាមួយដែលមានការផ្លាស់ប្តូរអាសយដ្ឋាន ថែមទាំងគួរយល់ព្រមឲ្យអ្នកជំនាញពិនិត្យជារៀងរាល់ឆ្នាំ ដើម្បីស្វែងរកការព្យាបាលថ្មីណាមួយដែលទំនងនឹងធ្វើឲ្យប្រសើរឡើងនៃការធ្លាក់ចុះផ្នែកបញ្ញាស្មារតី ដែលនាំឲ្យជនជាប់ចោទមានសម្បទាក្នុងការចូលរួមការជំនុំជម្រះ ។

នៅក្នុងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានលើកហេតុផលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយមិនបានប្រើប្រាស់យុត្តាធិការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព» ហើយជាថ្មីម្តងទៀត បានស្នើសុំលក្ខខណ្ឌ ៦ចំណុច ត្រូវបានដាក់ចំពោះការដោះលែង៖

១) ត្រូវស្នាក់នៅផ្ទះដែលមានអាសយដ្ឋានជាក់លាក់ណាមួយដែលនឹងត្រូវផ្តល់ជូនដោយសហមេធាវី ។

២) ត្រូវមានវត្តមាននៅពេលដែលមានការពិនិត្យរៀងរាល់សប្តាហ៍ដោយអាជ្ញាធរឬមន្ត្រីដែលតុលាការចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង ។

៣) ត្រូវប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណមកតុលាការ ។

៤) មិនត្រូវទាក់ទងដោយផ្ទាល់ ឬប្រយោលជាមួយនឹងសហជនជាប់ចោទផ្សេងទៀត លើកលែងតែជនជាប់ចោទ អៀង សារី ។

៥) មិនត្រូវទាក់ទងផ្ទាល់ ឬប្រយោលជាមួយសាក្សី ឬជនរងគ្រោះដែលត្រូវមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ និងមិនជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ។

៦) ត្រូវទទួលការពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់៦ខែម្តងដោយអ្នកអនុវត្តវេជ្ជសាស្ត្រដែលតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូង ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញនូវភាពផ្ទុយគ្នាចំនួនពីរដែលមាននៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដំបូងដែលថាខ្លួនមិនអាចអនុវត្តនូវយុត្តាធិការលើជនជាប់ចោទ អៀង ធីរិទ្ធ បន្ទាប់ពីទទួលបានការដោះលែងដោយសារតែការផ្អាកកិច្ចដំណើរការនីតិវិធីមានលក្ខណៈជាអចិន្ត្រៃយ៍ មួយ) ការយល់ឃើញរបស់ខ្លួនថាកិច្ចដំណើរការនីតិវិធីអាចត្រូវបានចាប់ផ្តើមឡើងវិញ ប្រសិនបើយល់ឃើញថាជនជាប់ចោទមានសម្បទាគ្រប់គ្រាន់នៅពេលក្រោយ និងពីរ) ការព្រមព្រៀងរបស់ខ្លួនក្នុងការអនុវត្តវិធានការមួយចំនួនក្នុងគោលបំណងធ្វើយ៉ាងណាឲ្យកិច្ចដំណើរការនីតិវិធីនេះអាចដំណើរការឡើងវិញបាន ប្រសិនបើមានការវិវឌ្ឍផ្នែកវេជ្ជសាស្ត្រ ។

អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ដែរថា មិនដូចតុលាការដែលប្រើប្រាស់ប្រព័ន្ធច្បាប់ខំមិនឡ *Common Law* ប្រព័ន្ធច្បាប់ស៊ីវិល ដូចជានៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំមានឆន្ទានុសិទ្ធមិនបន្តបណ្តឹងអាជ្ញាដែលខ្លួនបានចាប់ផ្តើមធ្វើរួចទៅហើយនោះទេ លើកលែងតែមានហេតុផលដែលចែងយ៉ាងជាក់លាក់ក្នុងច្បាប់ ៖ «ច្បាប់ដែលអាចយកមកអនុវត្តនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានចែងអំពីលទ្ធភាពបញ្ចប់ដំណើរនីតិវិធីនៅក្នុងករណី ដែលរកឃើញថាជនជាប់ចោទមិនមានសម្បទាចូលរួមនៅក្នុងសវនាការនោះទេ»

ប៉ុន្តែបានចែងអំពីលទ្ធភាពផ្អាកដំណើរការនីតិវិធីក្នុងកាលៈទេសៈជាក់លាក់មួយចំនួនដោយសារតែឧបសគ្គ" ដើម្បីបន្តកិច្ចដំណើរការនីតិវិធី ។

ដោយកត់សម្គាល់លើ "ភាពគ្មានតឹង" រវាងសិទ្ធិជាសារវ័ន្តមូលដ្ឋានរបស់ជនជាប់ចោទដែលទំនងជាមិនអាចនាំយកទៅជំនុំជម្រះបាន និងផលប្រយោជន៍យុត្តិធម៌ក្នុងការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ" អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យយ៉ាងល្អិតល្អន់លើវិធាន និងការអនុវត្តដែលមាននៅក្នុងកម្រិតអន្តរជាតិ ក៏ដូចជាការអនុវត្តនៅក្នុងស្រុកដែរ" ដើម្បីសម្រេចថាតើការអនុវត្តនូវស្តង់ដារអន្តរជាតិអាចតម្រូវឲ្យមានការបញ្ចប់នីតិវិធីឬយ៉ាងណា? ក្នុងចំណោមការយល់ឃើញរបស់ខ្លួន គឺថា "ដំណោះស្រាយបន្តផ្អាកនីតិវិធីបណ្តោះអាសន្នប្រឆាំងនឹងជនជាប់ចោទដែលពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមជំនុំជម្រះ និងបន្តការអនុវត្តនូវយុត្តាធិការត្រូវបានគាំទ្រដោយតុលាការអន្តរជាតិជាច្រើនរួចមកហើយ" ដូចជាតុលាការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងប្រព័ន្ធតុលាការក្នុងស្រុកជាច្រើនទៀតដោយរួមទាំងបារាំងដែលក្រមរបស់ខ្លួនផ្តល់ជាគំរូដល់វិស័យនីតិវិធីកម្ពុជា ។

ជារួម អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដែលពុំមានសម្បទាគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ត្រូវបានបញ្ចប់ ហើយតុលាការបានបោះបង់ចោលនូវយុត្តាធិការលើជនជាប់ចោទគឺនូវតែជាករណីពិសេស" ។ យុត្តាធិការ "អនុញ្ញាតឲ្យតុលាការចាត់វិធានការនានាដែលត្រូវបានចាត់ទុកចាំបាច់ និងសមស្របនៅក្នុងកាលៈទេសៈទាំងនោះដើម្បីអាចបន្តកិច្ចដំណើរការនីតិវិធី ប្រសិនបើមានឱកាស" ដោយសារតែលក្ខខណ្ឌវេជ្ជសាស្ត្ររបស់ជនជាប់ចោទ និងវិទ្យាសាស្ត្រផ្នែកវេជ្ជសាស្ត្រគឺ "អាចផ្លាស់ប្តូរតាមពេលវេលា" និង "អាស្រ័យលើកំហុសរបស់មនុស្ស និងអាកប្បកិរិយាពុំស្មោះត្រង់របស់ជនជាប់ចោទ ។

អាស្រ័យលើសំអាងហេតុទាំងអស់នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា "អង្គជំនុំជម្រះសាលាដំបូងបានកំពុងប្រឡំផ្នែកអង្គច្បាប់នៅក្នុងការសន្និដ្ឋានថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនត្រូវបានអនុញ្ញាតឲ្យអនុវត្តយុត្តាធិការលើជនជាប់ចោទ ក្នុងអំឡុងពេលនៃការផ្អាកនីតិវិធី ដោយពុំមានពេលវេលាកំណត់ច្បាស់លាស់ប្រឆាំងនឹងជនជាប់ចោទ ដោយហេតុថាសេចក្តីសន្និដ្ឋានបែបនេះពុំមានទាំងហេតុផលគាំទ្រដោយច្បាប់ដែលអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬការអនុវត្តនៅក្នុងបទដ្ឋានជាតិ និងអន្តរជាតិជាធរមាន" ។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើអំណះអំណាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាពុំមាន "មូលដ្ឋានផ្នែកគតិយុត្តិជាក់លាក់ក្នុងការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធី ។ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា "ការផ្អាកកិច្ចដំណើរការនីតិវិធីមិនបានរារាំងតុលាការក្នុងការធ្វើចំណាត់ការលើដំណើរការនីតិវិធី និងអនុវត្តវិធានការ ដើម្បីធានាការបន្តនីតិវិធីសុចរិតភាពរបស់ខ្លួនឡើយ" ។ បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថាមានមូលដ្ឋានគតិយុត្តិជាផ្លូវការសម្រាប់អនុវត្តវិធានការទូទៅដែលទាក់ទងនឹងការឃុំខ្លួន និងការត្រួតពិនិត្យតាមផ្លូវតុលាការនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ជាផលវិបាកនៅក្នុងការយល់ឃើញរបស់ខ្លួនបញ្ហាសំខាន់ដែលកើតចេញពីការផ្អាកកិច្ចដំណើរការនីតិវិធីគ្មានពេលវេលាកំណត់ដោយសារភាពគ្មានសម្បទាជាអចិន្ត្រៃយ៍របស់ជនជាប់ចោទលើវិធានការត្រួតពិនិត្យតាមផ្លូវតុលាការមិនមែនជាការខ្វះយុត្តាធិការ ឬមូលដ្ឋានច្បាប់នោះទេ ប៉ុន្តែគឺជាបញ្ហានៃភាពចាំបាច់ និងសមាមាត្រនៃវិធានការនេះនៅក្នុងកាលៈទេសៈបច្ចុប្បន្ន" ដែលបញ្ហានេះពុំត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងសោះ ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដោយសារតែលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលស្នើឡើងដោយសហព្រះរាជអាជ្ញាដាក់កម្រិតដល់សិទ្ធិជាសារវ័ន្តដែលការពារដោយសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយៈ

*ពុំមានភាពគ្រប់គ្រាន់ដែលថា ការរឹតបន្តឹងនេះមានមូលដ្ឋានច្បាប់ជាផ្លូវការ ដូចដែលបានពិភាក្សាខាងលើ តុលាការអាចកំណត់ដាក់វិធានការទាំងនេះ ដែលមាន*

*ភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ និងស្របទៅតាមគោលការណ៍សមាមាត្រដោយធ្វើឲ្យមានភាពសមរម្យដើម្បីសម្រេចឲ្យបាននូវតួនាទីការពាររបស់ខ្លួនដែលជាឧបករណ៍ដែលមានភាពបំពានតិចតួចក្នុងចំណោមឧបករណ៍ដទៃទៀតដែលអាចសម្រេចបាននូវលទ្ធផលដែលចង់បាន និងមានភាពសមាមាត្រជាមួយនឹងផលប្រយោជន៍ដែលត្រូវការពារ ។*

ដោយសារតែមានក្តីរំពឹងតិចតួចដែលថាជនជាប់ចោទ អៀង ធីរិទ្ធ អាចមានសម្បទាគ្រប់គ្រាន់ ហើយនាំយកមកជំនុំជម្រះបាន នោះវិធានការទាំងនោះដែលមានការប៉ះពាល់តិចតួចជាក់ស្តែងលើសិទ្ធិជនជាប់ចោទអាចត្រូវបានចាត់ទុកថា មានភាពសមាមាត្រ ។ ប៉ុន្តែ«វិធានការដែលមានការប៉ះពាល់» ត្រូវបានកំណត់ដោយយោងលើសំអាងហេតុជាក់ស្តែងដែលថា ជនជាប់ចោទម្នាក់ដែលពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមជំនុំជម្រះគឺជនជាប់ចោទនោះពុំមានលទ្ធភាពអនុវត្តសិទ្ធិរបស់ខ្លួនឲ្យបានពេញលេញ ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថា ទាំងជនជាប់ចោទពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតាមលក្ខខណ្ឌដែលបានដាក់ដោយអង្គជំនុំជម្រះប្រឆាំងនឹងខ្លួន ដោយសារបញ្ហាធ្លាក់ចុះនៃបញ្ញាស្មារតី ទាំងភាពលំបាកក្នុងការអនុវត្តលក្ខខណ្ឌប្រឆាំងនឹងជនជាប់ចោទមិនមែនមានន័យថាលក្ខខណ្ឌទាំងនោះមិនអាចអនុវត្តបានដោយជនជាប់ចោទ អៀង ធីរិទ្ធ នោះទេ គឺតាមកូនស្រីរបស់ជនជាប់ចោទដែលត្រូវបានតែងតាំងជាអាណាព្យាបាលរបស់ជនជាប់ចោទ ។

ទាក់ទងនឹងវិធានការដាក់លាក់ដែលដាក់ដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ៈ

◆ ទទួលការវាយតម្លៃវេជ្ជសាស្ត្ររៀងរាល់៦ខែម្តង ដើម្បីត្រួតពិនិត្យមើលភាពជាក់លាក់នៃលក្ខខណ្ឌរបស់ជនជាប់ចោទ និងការវិវត្តដោយសមរម្យ និងត្រឹមត្រូវតាមក្រមកម្ពុជា ។

◆ អនុវត្តការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ ហើយចាំបាច់ត្រូវរក្សាវត្តមានជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងប្រទេសកម្ពុជា និងផ្តល់អាស័យដ្ឋានជូនអង្គជំនុំជម្រះ ។

◆ ពុំមានការសមាមាត្រចំពោះការរក្សាទុកអត្តសញ្ញាណប័ណ្ណនិងការប្រគល់លិខិតឆ្លងដែនពីព្រោះ «វាធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ជនជាប់ចោទក្នុងការមានឯកសារពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់ខ្លួន»

◆ ការចុះពិនិត្យគួរតែមានការរំខានតិចបំផុតដោយមន្ត្រីនគរបាលយុត្តិធម៌ និងបម្រើដល់គោលបំណងនៃការផ្ទៀងផ្ទាត់ថា តើជនជាប់ចោទនៅតែស្នាក់នៅអាសយដ្ឋានដែលប្រគល់ជូនតុលាការឬយ៉ាងណា

◆មិនមានភាពចាំបាច់ក្នុងការហាមឃាត់ជនជាប់ចោទមិនឲ្យជ្រៀតជ្រែកកិច្ចការតុលាការដោយសារមានភាពតម្រូវពីកាតព្វកិច្ចអន្តរជាតិស្រាប់ ។

◆ពុំមានភាពពិតប្រាកដចំពោះការគំរាមកំហែងដែលថា ជនជាប់ចោទនឹងជ្រៀតជ្រែកសាក្សីនៅក្នុងសំណុំរឿង០០២ ក្នុងអំឡុងពេលផ្អាកនីតិវិធីប្រឆាំងជនជាប់ចោទ និងការចុះខ្សោយនៃសតិបញ្ញា ។

បច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងត្រូវបានស្នើឲ្យធ្វើការត្រួតពិនិត្យលក្ខខណ្ឌទាំងនេះរៀងរាល់១២ខែម្តង ដើម្បីធានាថា ជនជាប់ចោទ អៀង ធីរិទ្ធ «មិនត្រូវបានដាក់កំហិតតាមអំពើចិត្តទៅលើសិទ្ធិជាឯកជន និងសេរីភាពក្នុងការដើរហើរ» ។ លើកលែងតែមានការផ្លាស់ប្តូរនៅក្នុងលក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រនេះគឺជាការសម្រេចចុងក្រោយបង្អស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លើបញ្ហាសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។

**អាន ហាញឌុល**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

*មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីសំឡេងអំពើប្រល័យពូជសាសន៍ ៈ យុត្តិធម៌ និងការអត់ឃ្មាន ផ្សាយតាមវិទ្យុជាតិកម្ពុជា AM៩១៨MHz ជារៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ៧ៈ០០-៧ៈ៣០ព្រឹក និង៥ៈ៣០-៦ៈ០០ល្ងាច ។*

*សូមអរគុណ!*

# ការចងក្រងឯកសារក្រោយពីអំពើឃោរឃៅកើតឡើង

***(តពីលេខមុន)***

### ២) ការប្រមូលឯកសារប្រវត្តិសាស្ត្ររបស់ប្រទេសសម័យអន្តរកាល

ការកើតឡើងបទដ្ឋាននៃកាតព្វកិច្ចចងក្រងឯកសារបង្កប់ន័យការទទួលខុសត្រូវជាច្រើនរបស់រដ្ឋ ។ ការរក្សាឯកសារប្រវត្តិសាស្ត្រនៃការរំលោភបំពានឲ្យមានប្រសិទ្ធភាព ទាមទារធ្វើបញ្ជីសារពើព័ន្ធ រៀបចំ និងរក្សាឯកសារ ព្រមទាំងបង្កើតវិធាន និងសេចក្ដីណែនាំដែលគាំទ្រការផ្សព្វផ្សាយព័ត៌មានឲ្យស្របនឹងគោលបំណងខាងសន្តិសុខ និងឯកជនភាព ។ ភារកិច្ចទាំងនោះ ជាពិសេសភារកិច្ចចុងក្រោយ បង្កការលំបាកដល់សូម្បីតែប្រទេសអ្នកមាន និងប្រទេសប្រជាធិបតេយ្យក្នុងការគ្រប់គ្រងឲ្យមានប្រសិទ្ធភាព ។ គ្រប់តថភាពទាំងអស់នៃការប្រមូលឯកសាររំលោភបំពានសិទ្ធិមនុស្សបង្កឲ្យមានការប្រឈមក្នុងសង្គមដែលងាកចេញពីការត្រួតត្រាសង្កត់សង្កិន ។ ការប្រឈមទាំងនោះចាប់ផ្ដើមជំហានទីមួយគឺការប្រមូលឯកសារជាប់ពាក់ព័ន្ធអំពើឃោរឃៅ ។មេដឹកនាំប្រើអំពើរំលោភបំពានហើយកម្រទុកឯកសារឲ្យរដ្ឋាភិបាលក្រោយណាស់ ។ ជារឿយៗរដ្ឋាភិបាលចាស់ព្យាយាមបំផ្លាញឯកសារចោល ពេលដែលខ្លួនធ្លាក់ពីអំណាច ។ នៅពេលដែលរបបមួយបាត់បង់ការត្រួតត្រាលើមូលដ្ឋានសន្តិសុខ ក្រុមខុទ្ទាម កងកម្លាំងយោធាបរទេស អ្នកសារព័ត៌មានអ្នកគាំទ្រសិទ្ធិ មនុស្ស និងអ្នកដទៃជាធម្មតារឹបអូសយកឯកសារ ។ តើឯកសារ ទាំងនោះគួរតែត្រូវគេយកទៅណា?

វិធីសាស្ត្រជាមូលដ្ឋានផ្ដោតលើរបៀបចងក្រងឯកសារដែលមានលក្ខណៈផ្លូវច្បាប់និងដែលអាចរកបានស្ដីពីការរំលោភបំពានពីអតីតកាល ។ ការប្រមូលឯកសារត្រូវរៀបចំឲ្យបានប្រសើរតាមរយៈការពិចារណាពីចំណុចបច្ចេកទេស ប៉ុន្តែវាត្រូវមានមូលដ្ឋានផ្លូវច្បាប់ដែលចេញពីសាធារណមតិដែលបង្ហាញការពិតតាមរបៀបត្រឹមត្រូវ និងមិនលម្អៀង ។ ផ្លូវទៅរករឿងនេះខុសគ្នាពីករណីមួយទៅករណីមួយ ។ គំនិតដ៏ប្រសើរគឺត្រូវផ្ដល់ឯកសារឲ្យទៅទីរក្សាឯកសារប្រវត្តិសាស្ត្រជាតិដែលមានសុវត្ថិភាព និងមានការគាំទ្រផ្នែកថវិកាល្អប្រសើរ ។ ទោះបីជាយ៉ាងនេះក៏ដោយ ជម្រើសខាងលើមិនអាចធ្វើទៅរួចទេ ជាពិសេសក្នុងសង្គមដែលងើបចេញពីអំពើឃោរឃៅធ្ងន់ធ្ងរ ។ ជារឿយៗ កិច្ចខិតខំប្រឹងប្រែងប្រមូលឯកសារកើតឡើងក្នុងតំបន់អស្ថិរភាពនយោបាយ និងផ្លូវច្បាប់មុនពេលដែលរបបចាស់ត្រូវ គេទាត់ចោល ឬមុនពេលរដ្ឋាភិបាលស្របច្បាប់ថ្មីចាប់កំណើត ។ ករណីផ្សេងទៀត រដ្ឋាភិបាលថ្មីខ្វះឆន្ទៈ ឬសមត្ថភាពប្រមូលនិងរក្សាឯកសារអំពីក្រុមភេរវករពីអតីតកាល ។ ប្រសិនបើរដ្ឋាភិបាលមិនអាច ឬគ្មានឆន្ទៈបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការកត់ត្រាតួអង្គជាប់ពាក់ព័ន្ធដទៃមានសិទ្ធិនិងការទទួលខុសត្រូវធ្វើការងារនេះ ។

ផ្នែកខាងលើលើកឡើងថា ចង់ឲ្យរដ្ឋធ្វើការងារប្រមូលឯកសារ ប៉ុន្តែពេលខ្លះស្ថាប័នមិនមែនរដ្ឋាភិបាលក៏មានហេតុផលស្របច្បាប់ធ្វើការប្រមូលឯកសារប្រវត្តិសាស្ត្រដែរ ។ គោលគន្លឹះផ្សេងៗជាច្រើនគួរតែថ្លឹងថ្លែងក្នុងការកំណត់ថាតើនរណាមានមូលដ្ឋានប្រមូលឯកសារដូចជា តើវាស្របច្បាប់ដល់កម្រិតណាពេលដែលរដ្ឋាភិបាលប្រជាធិបតេយ្យកំពុងកាន់អំណាចក្នុងប្រទេសដែលការរំលោភបំពានកើតឡើង ថាតើសុឆន្ទៈនិងសមត្ថភាពគ្រប់គ្រងឯកសារឆ្លើយតបយ៉ាងដូចម្ដេច? ថាតើរដ្ឋាភិបាលបានយល់ព្រមឲ្យមានការប្រមូលឯកសារដោយអង្គភាពក្រៅពីរដ្ឋាភិបាលយ៉ាងដូចម្ដេច? តើការចូលរួមរបស់អង្គភាពក្នុងតំបន់ដល់កម្រិតណា? ថាតើរដ្ឋសង្កត់សង្កិនធ្វើកំណត់ត្រាឬកំណត់ត្រាត្រូវប្រជាជនសាមញ្ញ និងប្រភពដទៃរឹបអូសដោយវិធីណា?

### ក) តួនាទីរបស់ទីរក្សាឯកសារជាតិ

វិធានទូទៅក្រោមច្បាប់អន្តរជាតិនិងប្រព័ន្ធច្បាប់ជាតិភាគច្រើនចែងថា កំណត់ត្រាផ្លូវការជាកម្មសិទ្ធិរបស់រដ្ឋ ។ ការកើតឡើងបទដ្ឋាននៃកាតព្វកិច្ចចងក្រងឯកសារបានផ្ដោតលើទំនួលខុសត្រូវ

របស់រដ្ឋក្នុងការរក្សាទីតម្កល់ឯកសារ ។ ក្នុងករណីជាច្រើន រដ្ឋនាំមុខក្នុងការបង្កើតទីតម្កល់ឯកសារទាក់ទងនឹងការរំលោភបំពានសិទ្ធិមនុស្សកាលពីអតីតកាល ឧទាហរណ៍ រដ្ឋាភិបាលអេស្ប៉ាញបានប្រមូលឯកសារស្តីពីការសង្កត់សង្កិនក្រោមរបបហ្វ្រង់កូដាក់ក្នុងទីតម្កល់ឯកសារជាតិស្តីពីសង្គ្រាមស៊ីវិលនៅទីក្រុងសាលាម៉ាន់កា ហើយក្រោយមកក៏បង្កើតជាមជ្ឈមណ្ឌលឯកសារជាតិស្តីពីការចងចាំប្រវត្តិសាស្ត្រ ។ អតីតរដ្ឋកុម្មុយនីស្តមួយចំនួននៅអឺរ៉ុបខាងកើត និងអឺរ៉ុបកណ្តាលបានបង្កើតទីតម្កល់ឯកសារស្តីពីសិទ្ធិមនុស្សដែរ ។ រដ្ឋាភិបាលអាល្លឺម៉ង់បានរក្សាទីតម្កល់ឯកសារពីពួកស្តាស៊ី (ប៉ូលីសសម្ងាត់អាល្លឺម៉ង់ខាងកើត) នៅទីក្រុងប៊ែឡាំង ។ ប្រទេសប៉ូឡូញ ប្រទេសហុងគ្រី និងប្រទេសស្លូវ៉ាគី បានអនុម័តច្បាប់ ឬបទបញ្ញត្តិដែលគ្រប់គ្រងទីតម្កល់ឯកសារស្តីពីការរំលោភបំពាន ។ ប្រទេសមួយចំនួននៅអាមេរិកខាងត្បូង ដូចជាប្រទេសអាហ្សង់ទីន និងប្រេស៊ីលក៏បានធ្វើដូចគ្នាដែរ ។

កត្តាមួយចំនួនបានធ្វើឲ្យរដ្ឋដើរតួនាទីយ៉ាងសំខាន់ ។ រដ្ឋាភិបាលគ្រប់គ្រងខាងរូបវន្តលើទីតម្កល់ឯកសារដែលរដ្ឋាភិបាលរបបមុនបានធ្វើការសង្កត់សង្កិន បានរក្សាទុក ហើយផ្នែកមួយចំនួនត្រូវរៀបចំនិងថែរក្សាបានល្អរួចទៅហើយ ។ រដ្ឋាភិបាលថ្មីក្នុងប្រទេសទាំងនោះក៏មានសមត្ថភាពខ្លាំងក្នុងការគ្រប់គ្រងទីតម្កល់ឯកសារដែរ ។ សំខាន់ជាងនេះទៀត រដ្ឋាភិបាលទាំងនោះមានការលើកទឹកចិត្តខាងនយោបាយក្នុងការដឹកនាំដំណើរការប្រមូលឯកសារ ដើម្បីបំពេញចិត្តសាធារណជនក្នុងការស្វែងរកការពិតនិងដើម្បីការរក្សាគ្រប់គ្រងព័ត៌មានដែលត្រូវផ្សព្វផ្សាយ ។

ទីតម្កល់ឯកសារស្តីពីសិទ្ធិមនុស្សរបស់រដ្ឋត្រូវគេចាត់ចូលក្នុងទីតម្កល់ឯកសារជាតិ ឬទីតម្កល់ឯកសារជំនាញដោយឡែកណាមួយ ។ របាយការណ៍របស់ក្រុមប្រឹក្សាអន្តរជាតិស្តីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់អង្គការយូណេស្កូដែលបានសរសេរកាលពីឆ្នាំ២០០៩ ផ្តល់ជាយោបល់ឲ្យបង្កើតទីតម្កល់ឯកសារជំនាញដោយផ្តោតលើអំឡុងពេលនៃការរំលោភបំពាន និងការផ្តោតលើឯកសារពាក់ព័ន្ធនៃការរំលោភសិទ្ធិមនុស្ស ។ វាសមហេតុផលណាស់ដែលការគ្រប់គ្រងឯកសារសិទ្ធិមនុស្សទាមទារឲ្យមានជំនាញ ហើយថាសំណើជាច្រើនទំនងជាធ្វើឡើងដើម្បីទាមទារឲ្យមានធនធានមនុស្ស និងហិរញ្ញវត្ថុដែលអាចពង្រីកសមត្ថភាពរបស់ទីតម្កល់ឯកសារជាតិ ។ បន្ទាប់មក របាយការណ៍លើកឡើងថាទីតម្កល់ឯកសារជំនាញអាចត្រូវបញ្ចូលទៅជាតែមួយនឹងទីតម្កល់ឯកសារធម្មតា ។

មានផលប្រយោជន៍ជាច្រើនដែលមានទីតម្កល់ឯកសារជាតិឬក៏អង្គភាពរដ្ឋាភិបាលដឹកនាំដំណើរការប្រមូលឯកសារ ។ របាយការណ៍របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិកាលពីឆ្នាំ២០០៩ បានបង្កើតករណីសម្រាប់ដាក់កំណត់ត្រាក្នុងទីតម្កល់ឯកសារជាតិដូចខាងក្រោម ៖

> *ការរក្សាកំណត់ត្រារបស់រដ្ឋាភិបាលទាំងអស់ក្នុងទីតម្កល់ឯកសារជាតិមានអត្ថប្រយោជន៍សំខាន់ចំនួនបី ។ ទីមួយ ជួយធានាភាពស្របគ្នានៃការអនុវត្តការដាក់កំហិត និងការទទួលបានឯកសារ ។ ទីពីរ តាមរយៈការទុកកំណត់ត្រាឯកសារសម្ងាត់ភាគច្រើននៅទីនោះ ទីតម្កល់ឯកសារជាតិអាចដោះស្រាយបញ្ហាកំណត់ត្រាលើអ្វីដែលធ្លាប់មានពីមុន ។ ចុងបញ្ចប់ វាចំណាយលុយតិចក្នុងការគ្រប់គ្រងទីតម្កល់ឯកសារជាតិតែមួយ ជាជាងប្រើស្ថាប័នច្រើន ។*

ក្រៅពីនេះ ការនាំមុខរបស់រដ្ឋក្នុងដំណើរការចងក្រងឯកសារបង្ហាញឲ្យឃើញពីចំណុចរបត់នៃការប្រព្រឹត្តពីអតីតកាល ហើយជាពិសេស វាភ្ជាប់ទៅនឹងដំណើរការលើកស្ទួយការចងចាំនឹងការទទួលខុសត្រូវ ។ ការនាំមុខរបស់រដ្ឋរួមចំណែកដល់បទដ្ឋាននៃកាតព្វកិច្ចក្នុងការកត់ត្រាឯកសារ ។ បើពិចារណាជាក់ស្តែង រដ្ឋគឺជាអង្គភាពតែមួយប៉ុណ្ណោះដែលមានធនធានគ្រប់គ្រាន់រៀបចំទីតម្កល់ឯកសារធំក្នុងសង្គមអន្តរកាល ។ ដោយហេតុនេះ យុទ្ធសាស្ត្រជាមូលដ្ឋានលើកឡើងថា ពេលដែលស្ថាប័នជាតិមានសមត្ថភាពដែលបង្កើតដោយមេដឹកនាំជ្រើសតាំងតាមផ្លូវច្បាប់ ស្ថាប័នទាំងនោះគឺជាកន្លែងដ៏ស័ក្តិសមសម្រាប់ជាទីតម្កល់ឯកសារស្តីពីសិទ្ធិមនុស្ស ។

### ១) ការប្រមូលឯកសារដោយអង្គការក្រៅរដ្ឋាភិបាល

ពិតប្រាកដណាស់ រដ្ឋទាំងអស់មិនអាចគ្រប់គ្រងទីតម្កល់ឯកសារឲ្យមានប្រសិទ្ធភាពបានទាំងស្រុងទេ ។ អង្គការក្រៅរដ្ឋាភិបាលអាចមានសិទ្ធិក្នុងការធ្វើការងារនេះនៅពេលដែលរដ្ឋខ្វះឆន្ទៈ ខ្វះសមត្ថភាពឬភាពស្របច្បាប់ដើម្បីប្រមូលឯកសាររំលោភបំពានពី

អតីតកាលឲ្យមានប្រសិទ្ធភាព ។ ពិតប្រាកដណាស់ថា អង្គការក្រៅរដ្ឋាភិបាលមានអំណាចស្របច្បាប់គ្រប់គ្រងកំណត់ត្រាខ្លួន និងកំណត់ត្រាឯកជន ។ ដូច្នេះហើយ ឯកសារមិនចាំបាច់ធ្វើតាមសេចក្ដីបង្គាប់របស់ដីកា ឬសេចក្ដីបង្គាប់ផ្លូវច្បាប់របស់រដ្ឋ ។ ច្បាប់អន្តរជាតិនិយាយតិចតួចណាស់ពីសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការគ្រប់គ្រងកំណត់ត្រារបស់រដ្ឋ ។ រដ្ឋត្រូវប្រគល់សិទ្ធិអំណាចឲ្យអង្គការក្រៅរដ្ឋាភិបាលធ្វើការប្រមូលឯកសារ ។ ប៉ុន្តែស្ថានភាពកាន់តែស្មុគស្មាញពេលដែលរដ្ឋមិនផ្ដល់សិទ្ធិអំណាចក្នុងការងារនេះ ហើយទាមទារឲ្យប្រគល់ឯកសារទៅរដ្ឋាភិបាលវិញ ។

កម្ពុជាបានគូសបញ្ជាក់ពីការប្រមូលឯកសាររបស់អង្គការក្រៅរដ្ឋាភិបាល ដែលផ្ដល់សិទ្ធិអំណាចផ្លូវការដោយរដ្ឋ ។ ក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានរកឃើញឯកសារជាច្រើនដែលមានព័ត៌មានសំខាន់អំពីរបបខ្មែរក្រហម ។ ឯកសារទាំងនោះរួមមាន កំណត់ត្រា និងរូបភាពរបស់គុកទួលស្លែង ហើយក្រោយមកបានក្លាយជាផ្នែកមួយនៃទីតម្កល់ឯកសាររបស់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដែលគ្រប់គ្រងដោយរដ្ឋ ។ ឯកសារជាច្រើនផ្សេងទៀតបានរក្សាទុកក្នុងបន្ទប់សម្ងាត់ក្នុងក្រសួងមហាផ្ទៃរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលជារដ្ឋាភិបាលគាំទ្រដោយវៀតណាម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានបង្កើតដោយកម្មវិធីប្រល័យពូជសាសន៍កម្ពុជារបស់សកលវិទ្យាល័យយែល នៅសហរដ្ឋអាមេរិកបានទទួលឯកសារទាំងនោះពីក្រសួងមហាផ្ទៃក្នុងឆ្នាំ១៩៩៥ ។

កាលគ្រានោះ ទីតម្កល់ឯកសារជាតិកម្ពុជាខ្វះមូលនិធិ សមត្ថភាពនិងស្ថិតក្នុងសភាពទ្រុឌទ្រោមខ្លាំង ។ ឯកសារជាប្រវត្តិមិនត្រូវបានប៉ះពាល់ចាប់តាំងពីឆ្នាំ១៩៧៩ ហើយក៏គ្មានការងារណាមួយត្រូវគេធ្វើឡើងដើម្បីរៀបចំ ឬរក្សាឯកសារនោះ ។ ឯកសារជាច្រើនជាឯកសារបោះពុម្ព ឬសរសេរដោយដៃលើក្រដាសគុណភាពអន់ហើយក៏ខូចជាតំណចាប់តាំងពីពេលដែលបង្កើតឡើង ។ ក្នុងបរិបទនេះ ការចូលរួមរបស់ស្ថាប័នខាងក្រៅដែលមានថវិកា និងជំនាញក្នុងការបង្កើតទីតម្កល់ឯកសារ គឺមានសារសំខាន់ណាស់ ។ រដ្ឋាភិបាលបានចេញលិខិតផ្ដល់សិទ្ធិអំណាចឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបង្កើតទីតម្កល់ឯកសារខ្មែរក្រហម ។ ដោយសារតែគ្មានច្បាប់ស្ដីពីការប្រមូលឯកសារ លិខិតផ្ដល់សិទ្ធិអំណាចរបស់រដ្ឋាភិបាលមានតួនាទីដូចបទបញ្ជារដ្ឋបាល ។ មានអ្នករិះគន់មួយចំនួនតូចលើកឡើងថាជារឿងខុសច្បាប់ដែលរដ្ឋាភិបាលប្រគល់ឯកសារឲ្យទៅអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែវត្តមានក្នុងប្រទេសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងការយល់ព្រមឲ្យមានការចងក្រងឯកសាររបស់រដ្ឋាភិបាលបានផ្គាប់ចិត្តមជ្ឈដ្ឋានជាច្រើន ។

តាំងពីពេលនោះមក មជ្ឈមណ្ឌលឯកសារកម្ពុជាអាចបង្កើតទីតម្កល់ឯកសារធំមួយដោយមានការគាំទ្រ និងជំនួយមូលនិធិពីដៃគូអន្តរជាតិផ្សេងៗ ។ ការប្រមូលឯកសារធ្វើនៅតែភ្នំពេញ ហើយមានសារៈសំខាន់ចំពោះគំនិតផ្ដួចផ្ដើមការចងចាំនិងការស្វែងរកយុត្តិធម៌ ដោយបានដើរតួនាទីយ៉ាងសំខាន់ផ្នែកឯកសារដល់សាលាក្ដីខ្មែរក្រហមដែលគាំទ្រដោយអង្គការសហប្រជាជាតិ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាបម្រើជាមូលដ្ឋានសម្រាប់គម្រោងស្រាវជ្រាវនិងអប់រំជាច្រើនរួមមាន សៀវភៅសិក្សា ទស្សនាវដ្ដីប្រចាំខែ ការតាំងពិពណ៌នៅសារមន្ទីរ កុន កម្មវិធីផ្សាយវិទ្យុ បាឋកថាសាធារណៈ ។ ឯករាជ្យភាពខាងនយោបាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់ជំនឿទុកចិត្តដល់កិច្ចខិតខំប្រឹងប្រែង ហើយបានទាក់ទាញម្ចាស់ជំនួយជាច្រើនដែលមានហេតុផលផ្លូវច្បាប់ និងនយោបាយមិនផ្ដល់ថវិកាផ្ទាល់ទៅរដ្ឋាភិបាលកម្ពុជា ។ រដ្ឋាភិបាលកម្ពុជាបានធ្វើការរួមជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាលើកម្មវិធីអប់រំប្រល័យពូជសាសន៍ ហើយបានផ្ដល់ដីមួយកន្លែងដល់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់បង្កើតមជ្ឈមណ្ឌលឯកសារជាអចិន្ត្រៃយ៍ ។

គំរូរបស់កម្ពុជាបង្ហាញថា ទីតម្កល់ឯកសារប្រកបដោយវិជ្ជាជីវៈមិនត្រូវគ្រប់គ្រងដោយភ្នាក់ងាររដ្ឋាភិបាលដែលមានភាពស្របច្បាប់ជាសាធារណៈ ឬដែលទទួលបានការគាំទ្រពីរដ្ឋ ។ ឥទ្ធិពលដ៏សំខាន់របស់ទីតម្កល់ឯកសារគឺជាវត្តមានក្នុងប្រទេសរបស់ខ្លួន និងភាពម្ចាស់ការក្នុងតំបន់ ។ វិធាននិងនិយតកម្មបានជំរុញទំនុកចិត្តការប្រមូលឯកសារដោយបើកចំហនិងសុចរិត ។ គំរូរបស់កម្ពុជាគឺជាស្ថានតភ្ជាប់ដ៏ប្រសើរខណៈដែលស្ថាប័នជាតិស្ថិតក្នុងដំណើរឆ្ពោះទៅមុខ ឬខណៈដែលការជឿជាក់លើបញ្ហាសិទ្ធិមនុស្សរបស់រដ្ឋាភិបាលស្ថិតក្នុងក្ដីមន្ទិល ។ ជាលទ្ធផលដ៏គាប់ប្រសើរដែលរដ្ឋាភិបាលផ្ដល់ការគាំទ្រ ហើយអង្គការក្រៅរដ្ឋាភិបាលអាចធ្វើ

ការងារនោះបានល្អ ។

គំរូដូចគ្នានេះ អាចសមស្របនឹងស្ថានភាពផ្សេងផងដែរ ។ ក្នុងប្រទេសអាហ្គានីស្ថាន ឯកសារត្រូវមើលឃើញថា ជាការឆ្លុះបញ្ចាំងពីការរំលោភបំពាននៃប្រវត្តិសោកនាដកម្មរបស់ប្រទេស ។ ទោះបីជាយ៉ាងនេះក្តី សមត្ថភាពរបស់ទីតម្កល់ឯកសារជាតិអាហ្គានីស្ថាននៅមានកំណត់ ហើយរដ្ឋាភិបាលបានធ្វើការងារតិចតួចណាស់ក្នុងការចងក្រងឯកសារអំពើឃោរឃៅពីអតីតកាល ។ ដោយសារតែគ្មានការចូលរួមពីរដ្ឋាភិបាលម្ចាស់ជំនួយអន្តរជាតិបានបែររកអង្គការក្រៅរដ្ឋាភិបាលដែលជាតួអង្គគន្លឹះក្នុងដំណើរការរៀបចំឯកសារ ។

ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការប្រមូលឯកសារ បានក្លាយជារឿងដ៏ស្មុគស្មាញ ពេលរដ្ឋាភិបាលម្ចាស់ផ្ទះមិនផ្តល់ការយល់ព្រម ។ នៅទីក្រុងប៊ែលក្រាត ប្រទេសស៊ែប មជ្ឈមណ្ឌលច្បាប់ស្តីពីមនុស្សធម៌បានស្វែងរកឯកសារអំពីអំពើឃោរឃៅដែលប្រព្រឹត្តឡើងអំឡុងសង្គ្រាមបាកង់ *(Bakan)* ក្នុងទសវត្សរ៍៩០រួមមាន ឧក្រិដ្ឋកម្មរបស់កងកម្លាំងស៊ែប ។ រដ្ឋាភិបាលស៊ែបនិងសារព័ត៌មានបានរិះគន់មជ្ឈមណ្ឌលនេះ និងលោក ណាតាសាកាដិក ដែលជាស្ថាបនិករបស់មជ្ឈមណ្ឌលនេះ ។ ប៉ុន្តែការគាំទ្រពីសំណាក់បរទេសបានជួយការពារមជ្ឈមណ្ឌលនេះ និងជួយឲ្យមជ្ឈមណ្ឌលអាចធ្វើបទសម្ភាសន៍ និងទទួលបាននូវកំណត់ត្រារបស់រដ្ឋាភិបាលទាក់ទិននឹងព័ត៌មានអំពើល្មើសច្បាប់ ។ ឯកសារសំខាន់រួមមានវីដេអូអំពីការសម្លាប់រង្គាលមកលើក្រុមម៉ូស្លីមបូស្នៀនៅតំបន់ស្រីប្រឺនីកាក្នុងឆ្នាំ១៩៩៥ ដោយពួកស្កូភៀន ដែលជាអង្គភាពរបស់ក្រសួងមហាផ្ទៃប្រទេសស៊ែប ។ ក្រោយមក មជ្ឈមណ្ឌលច្បាប់ស្តីពីមនុស្សធម៌ប្រគល់ខ្សែវីដេអូទៅតុលាការឧក្រិដ្ឋកម្មសង្គ្រាមរបស់ស៊ែប ហើយប្រគល់វីដេអូថតចម្លងទៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ មជ្ឈមណ្ឌលច្បាប់ស្តីពីមនុស្សធម៌មានកំណត់ត្រារបស់រដ្ឋាភិបាលមួយចំនួនដែលត្រូវបានប្រើសម្រាប់លើកស្ទួយការទទួលខុសត្រូវផ្លូវច្បាប់ ។ ការប្រគល់ឯកសារទាំងនោះភ្លាមៗឲ្យរដ្ឋាភិបាលស៊ែបបានបង្កឲ្យមានហានិភ័យ ។ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលច្បាប់ស្តីពីមនុស្សធម៌ទេ ឯកសារជាច្រើននឹងត្រូវបានបំផ្លាញ ។

ប្រសិនបើគ្មានការគាំទ្រពីរដ្ឋ ទីតម្កល់ឯកសារស្តីពីសិទ្ធិមនុស្សដែលមានកំណត់ត្រាសាធារណៈជាច្រើននឹងរងនឹងការប្រឈមខាងផ្លូវច្បាប់ ឬការគំរាមកំហែងផ្នែកសន្តិសុខ ។ រដ្ឋគ្មានសេរីភាពដែលជិតស់អំពើខុសឆ្គងពីអតីតមានការថ្លឹងថ្លែងរវាងផលប្រយោជន៍ក្នុងការគោរពភាពជាម្ចាស់នៃកំណត់ត្រាសាធារណៈរបស់រដ្ឋ និងការបង្កើតទីតម្កល់ឯកសារស្តីពីការរំលោភសិទ្ធិ ។ រឿងមួយដែលអាចធ្វើទៅបានគឺសាលាក្តីអន្តរជាតិដាក់ឯកសារឲ្យស្ថិតនៅក្រោមការឃ្លាំមើលរបស់អង្គការសហប្រជាជាតិ ប៉ុន្តែអធិបតេយ្យភាពនៅតែជាការចោទ ។ ជម្រើសដ៏ប្រសើរដើម្បីកាត់បន្ថយហានិភ័យដែលឯកសារអាចត្រូវបំផ្លាញ តុលាការអាចធ្វើការថតចម្លងឯកសារទាំងនោះនៅបរទេសដែលជាទម្រង់នៃការរក្សាកំណត់ត្រាតាមផ្លូវច្បាប់ ហើយប្រគល់ត្រឡប់ច្បាប់ដើមទៅរដ្ឋវិញ ។ ដំណោះស្រាយដ៏ប្រសើរត្រូវផ្តល់ដំហរផ្លូវច្បាប់ដល់អង្គភាពក្រៅរដ្ឋាភិបាលក្នុងការដេញដោលអំណះអំណាងរបស់រដ្ឋចំពោះឯកសារក្នុងតុលាការឬវេទិកាក្នុងតំបន់ឬអន្តរជាតិ ។

### ខ.១) សិទ្ធិកាន់កាប់កម្លាំងយោធា

ជានិច្ចកាល អ្នកប្រមូលឯកសារ និងអង្គការក្រៅរដ្ឋាភិបាលមិនប្រមូលឯកសារសិទ្ធិមនុស្សទេ ។ កងទ័ពគឺជាមនុស្សដ៏សំខាន់ដែលប្រមូលកំណត់ត្រាសាធារណៈក្នុងតំបន់ដែលខ្លួនកាន់កាប់ ។ ក្នុងករណីប្រទេសអ៊ីរ៉ាក់ អាហ្គានីស្ថាន លីប៊ី និងករណីប្រទេសដទៃទៀត កងកម្លាំងយោធាប្រឆាំងរុករកឯកសារនៅសមរភូមិនិងអគារធ្វើការ ។ កងកម្លាំងយោធាធ្វើការរុករកឯកសារដោយមានមូលហេតុដូចជាការទទួលបានព័ត៌មានសម្ងាត់ ការដឹងពីយុទ្ធសាស្ត្ររបស់សត្រូវ ការរៀបចំការចោទប្រកាន់នាពេលអនាគត និងការបិទបាំងការពិត ។ ឯកសារទាំងនោះរួមមាន ការរំលោភសិទ្ធិមនុស្ស ។

សន្ធិសញ្ញាអន្តរជាតិជាច្រើនបានដាក់បញ្ចូលបទបញ្ញត្តិស្តីពីការរឹបអូសឯកសារ ។ បទបញ្ញត្តិសំខាន់បំផុតគឺទាក់ទងនឹងសិទ្ធិរឹបអូសកំណត់ត្រាផ្លូវការរបស់រដ្ឋដោយកងកម្លាំងបរទេស ។ និយតកម្មទាំងនេះបំពេញបន្ថែមដល់អនុសញ្ញាក្រុងឡាអេឆ្នាំ១៩០៧ ដែលគោរពច្បាប់ និងទំនៀមទម្លាប់សង្គ្រាមស្តីពីការហាមឃាត់ការរឹបអូសយកដីឬការបំផ្លាញសម្ភារៈផ្សេងៗដែលមិនជាតម្រូវការក្នុងការធ្វើសង្គ្រាម ។ ប៉ុន្តែពាក្យពេចន៍ក្នុងអនុសញ្ញាលើកឡើងថា កង

កម្លាំងអាចរឹបអូសយកឯកសារដូចជា ផែនការធ្វើសឹក ឯកសាររបស់អង្គភាព ឯកសារឆ្លើយឆ្លងរបស់មន្ត្រី និងឯកសារផ្សេងៗទៀត ។ ការរឹបអូសយកឯកសារសត្រូវអំឡុងពេលសង្គ្រាមគឺជារឿងសាមញ្ញរហូតដល់ឆ្នុះបញ្ចាំងទម្លាប់ច្បាប់អន្តរជាតិ ។

នៅពេលដែលកងយោធាបរទេសក្លាយជាកងយោធាកាន់កាប់បទបញ្ញាដែលអនុញ្ញាតឲ្យយោធារឹបអូសយកទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋដែលប្រើសំរាប់ប្រតិបត្តិការសឹក អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩០៧ លើកឡើងផងដែរថា កងយោធាកាន់កាប់អាចរឹបអូសយកឯកសារដែលប្រើសម្រាប់គ្រប់គ្រងរដ្ឋដោយសារអំណាចផ្លូវច្បាប់ ។ អំណាចកាន់កាប់គឺត្រូវចាត់វិធានការគ្រប់បែបយ៉ាងដើម្បីស្តារ និងធានាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពតាមតែអាចធ្វើទៅរួចខណៈដែលការគោរពច្បាប់ក្នុងប្រទេសនេះនៅជាធរមាន ។ អំណាចគ្រប់គ្រងរដ្ឋរួមមានការស្តារ និងការថែរក្សាកំណត់ត្រាផ្លូវការ ទីតម្កល់ឯកសារដែលបង្ហាញឯកសារសាធារណៈទាំងអស់ដល់អ្នកកាន់អំណាច ។ នៅពេលដែលអំណាចរដ្ឋបាលរបស់អ្នកកាន់កាប់បានបញ្ចប់ពាក្យពេចន៍ក្នុងអនុសញ្ញាក្រុងឡាអេលើកឡើងថា អ្នកកាន់អំណាចត្រូវប្រគល់ឯកសារត្រឡប់ទៅរដ្ឋវិញ ។

អនុសញ្ញាក្រុងឡាអេឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងករណីជម្លោះប្រដាប់អាវុធផ្តល់កាតព្វកិច្ចដល់ប្រទេសជាហត្ថលេខីក្នុងការការពារសម្បត្តិវប្បធម៌រួមមានសៀវភៅ ឬឯកសារ ប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួន និងទីតម្កល់ឯកសារ ។ អនុសញ្ញានោះរារាំងកងកម្លាំងកាន់កាប់ពីការបំផ្លាញឯកសារចោល ប៉ុន្តែមិនបានហាមឃាត់ការប្រើប្រាស់ឯកសារ ឬកំណត់ត្រាក្នុងគោលបំណងរដ្ឋបាលឡើយ ។ ជារឿងមន្ទិលដែលអំណាចនេះធ្វើឲ្យកងកម្លាំងកាន់កាប់អាចយកកំណត់ត្រាចេញពីប្រទេសក្នុងន័យអភិរក្ស ។ ប៉ុន្តែពាក្យពេចន៍យ៉ាងច្បាស់នៃអនុសញ្ញានេះមិនបានដកចេញនូវលទ្ធភាពក្នុងការយកឯកសារចេញពីប្រទេសនោះឡើយ ។

ច្បាប់អន្តរជាតិដាក់បទដ្ឋានតឹងរ៉ឹងដល់ការប្រមូលឯកសារឯកជន ។ អនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩០៧ពោលថា ទ្រព្យសម្បត្តិឯកជនមិនអាចរឹបអូសបានទេក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ ។ ទោះបីជាយ៉ាងនេះក្តី បទបញ្ញត្តិផ្សេងៗនៃច្បាប់អន្តរជាតិរារាំងការដាក់កំហិតនេះតាមរយៈការអនុញ្ញាតឲ្យយោធាយកឯកសារយោធាពីឈ្លើយសឹក និងអនុញ្ញាតឲ្យកងកម្លាំងកាន់កាប់ឃុំខ្លួនបុគ្គលសង្ស័យធ្វើអំពើប្រឆាំងនឹងរដ្ឋខណៈដែលកំពុងប្រមូលឯកសារ ។ មាត្រាទី៣នៃអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដាក់កម្រិតមាត្រដ្ឋានស្រដៀងគ្នាទៅនឹងជម្លោះប្រដាប់អាវុធក្នុងស្រុក ។

**(នៅមានត)**

**ចន ឆរឆីអារី**

# ដំណឹងស្វែងរកគ្រួសារ

*ចេង ឈុន អៀង អាយុ៦៦ឆ្នាំ មានស្រុកកំណើតសង្កាត់បឹងរាំង ពីសង្គមសង្កាត់លេខ៤ ក្រុងភ្នំពេញ ។ សព្វថ្ងៃនេះរស់នៅសែនអេម៉ានទីក្រុងបារីស Seineet Marne ប្រទេសបារាំង ។ ចេង ឈុន អៀង ជាប្អូនបង្កើតរបស់ ចេង ឈុន ស្រេង ។ ឈ្មោះ ង្គួន អេង (ហៅ តានី) មានតួនាទីជាវិស្វករ មានប្រពន្ធឈ្មោះ ចេង ឈុន ស្រេង ។ ចេង ឈុន ស្រេង ជាបងបង្កើតរបស់ឈ្មោះ ចេង ឈុន អៀង ។ ចំណែក ចេង ឈុន ស្រេង ជាម្តាយរបស់ក្មេងទាំងនាក់មានឈ្មោះដូចខាងក្រោម ដូច្នេះ ចេង ឈុន អៀង ដែលត្រូវជាឪពុកមាបង្កើតសូមប្រកាសរកក្មួយបង្កើតឈ្មោះ ១) ង្គួន សៅយុត ភេទប្រុស ឆ្នាំ១៩៧០-១៩៧១ (មានអាយុប្រហែលជា១០ឆ្នាំ) បានចេញទៅតាមម្តាយដើម្បីរកឪពុកឈ្មោះ ង្គួន អេង ចាប់តាំងពីនោះមកបាត់ដំណឹងរហូត ។ ២) ង្គួន វុត្ថា ភេទប្រុស ៣) ង្គួន ចាន់បុប្ផា ភេទស្រី ៤) ង្គួន វុត្ថារី ភេទស្រី ៥) មិនចាំឈ្មោះ ។ ប្រសិនបើនរណាម្នាក់ក្នុងចំណោមក្មេងទាំងប្រាំនាក់ដែលរៀបរាប់ខាងលើឮពីដំណឹងនៃការស្វែងរកនេះ សូមទំនាក់ទាក់ទងទូរស័ព្ទលេខ ០១២ ២២៧ ៩៣៦ ។*

***សូមអរគុណ!***

# ការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សនៅតំបន់អាស៊ីអាគ្នេយ៍

## មូលសង្ខេប

នៅក្នុងឆ្នាំ២០០៩ និង២០១០ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា "អាស៊ាន" បានបង្កើតក្រុមសិទ្ធិមនុស្សថ្មីចំនួនពីរគឺគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មាធិការទទួលបន្ទុកការពារសិទ្ធិស្ត្រី និងកុមារ ។ អត្ថបទនេះនឹងពិនិត្យទៅលើដំណើរការក្នុងការឈានទៅរកការបង្កើតស្ថាប័នទាំងពីរនេះដោយផ្តោតលើការតស៊ូមតិអំពីបទដ្ឋាន និងគោលនយោបាយដែលបង្កើតឲ្យមានយន្តការសិទ្ធិមនុស្សជាច្រើនកន្លងមកនិងបញ្ហាប្រឈមនានា ។ បន្ទាប់មកយើងនឹងធ្វើការវិភាគទៅលើចរិតលក្ខណៈរបស់គណៈកម្មាធិការ និងបង្ហាញពីបែបបទដែលអាចរារាំងដល់លទ្ធភាពបច្ចុប្បន្ននៅក្នុងការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស ។ ចុងក្រោយនៃអត្ថបទនេះនឹងពិភាក្សាទៅលើលទ្ធភាពនៃការវិវត្តរបស់ស្ថាប័នទាំងពីរពេលខាងមុខនេះ ។

## ១) សេចក្តីផ្តើម

នៅក្នុងឆ្នាំ២០០៧ ប្រមុខរដ្ឋទាំងដប់ប្រទេសនៃសមាគមអាស៊ានរួមមាន ប្រ៊ុយណេ, កម្ពុជា, ឥណ្ឌូនេស៊ី, ឡាវ, ម៉ាឡេស៊ី, ភូមា, ប្ញមីយ៉ាន់ម៉ា, ហ្វីលីពីន, សិង្ហបុរី, ថៃ និងវៀតណាម បានចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងលើកដំបូងក្នុងការបង្កើតក្រុមសិទ្ធិមនុស្ស ។ ភាគច្រើននៃការផ្តល់ឲ្យក្នុងការចុះកិច្ចព្រមព្រៀងគឺមាត្រាមួយដែលប្រកាសថា អាស៊ាននឹងបង្កើតក្រុមសិទ្ធិមនុស្សថ្មីមួយ ។ កិច្ចព្រមព្រៀងនោះហើយដែលនាំឲ្យឈានដល់ការបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សរបស់អាស៊ាននៅក្នុងឆ្នាំ២០០៩ ក្នុងគោលបំណង "លើកស្ទួយនិងការពារសិទ្ធិមនុស្សព្រមទាំងសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់ប្រជាជននៃសមាគមអាស៊ាន" ។ ប្រមាណជាប្រាំមួយខែក្រោយមក ដោយអនុលោមទៅតាមសេចក្តីប្រកាសជាផ្លូវការ សមាគមអាស៊ានបានបង្កើតគណៈកម្មាធិការមួយផ្សេងទៀតគឺគណៈកម្មាធិការទទួលបន្ទុកលើកស្ទួយនិងការពារសិទ្ធិស្ត្រីនិងកុមាររបស់សមាគមអាស៊ាន ដោយផ្តោតលើកិច្ចការជាក់លាក់ផ្សេងៗជាច្រើនទៀត ។

ដំណើរការនៃការបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សរបស់អាស៊ាន និងគណៈកម្មាធិការទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិស្ត្រី និងកុមាររបស់សមាគមអាស៊ាន គឺមិនមែនជារឿងងាយស្រួល និងឆាប់រហ័សនោះទេ ។ ទោះបីជាគំនិតនៃសិទ្ធិមនុស្សក្នុងតំបន់បានលេចឡើងជាលើកដំបូងនៅក្នុងរបៀបវារៈអាស៊ានជាផ្លូវការក្នុងឆ្នាំ១៩៩៣ យ៉ាងណាក៏ដោយ យើងបានចំណាយពេលវេលាអស់ដប់ប្រាំមួយឆ្នាំ និងធ្វើការតស៊ូមតិជាច្រើនលើកច្រើនសាទាំងនៅក្នុងតំបន់ក្នុងចំណោមប្រទេសស្ថិតក្នុងអាស៊ាន និងដៃគូធំៗ មកពីបណ្តាប្រទេសខាងក្រៅជាច្រើនទៀតក្នុងការចូលរួមដើម្បីបង្កើតជាផែ្នផ្កាសម្រាប់គណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាគមអាស៊ាន និងគណៈកម្មាធិការទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិស្ត្រី និងកុមាររបស់សមាគមអាស៊ាន ។ ការបង្កើតនេះបានក្លាយជាទីចាប់អារម្មណ៍សម្រាប់សមាគមដោយសារជាយូរហើយគឺជាប់ទាក់ទងទៅនឹងបទដ្ឋាននៃភាពគ្មានសិទ្ធិជ្រៀតជ្រែក និងការទប់ទល់ទៅនឹងសម្ពាធសិទ្ធិមនុស្សដែលជាអាទិភាពក្នុងកម្រិតតំបន់ជាពិសេសគឺសិទ្ធិដែលទាក់ទងទៅនឹងសេរីភាពស៊ីវិលនិងនយោបាយ ។ ម្យ៉ាងវិញទៀត ប្រតិកម្មរបស់អ្នកគាំទ្រសិទ្ធិមនុស្សត្រូវបានបែកចេញតាមលំដាប់នៅក្នុងកម្រិតនៃការយកចិត្តទុកដាក់ខ្ពស់បំផុតទៅកាន់កម្រិតមធ្យម ។ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សគឺជាប្រភពចម្បងនៃការឲ្យយោបល់និងមតិរិះគន់ ។ អ្នកខ្លះបានកាត់សេចក្តីថាវាគឺជាឧបករណ៍ដែលគ្មានប្រយោជន៍ ហើយពណ៌នាវាថាជា "ការបន្លំភ្នែក" ឬ "ឥតប្រសិទ្ធភាព" ។ ហើយអ្នកខ្លះទៀតរួមមាននិទោសកម្មអន្តរជាតិ និងអ្នកឃ្លាំមើលសិទ្ធិមនុស្សបានឆ្លើយតបទៅនឹងការមកដល់នៃស្ថាប័នថាមានភាពទន់ខ្សោយនិងការប្រុងប្រយ័ត្នដោយសម្លឹងឃើញពីជំហានសក្តានុពល ប៉ុន្តែក៏មានការព្រួយបារម្ភនៅខណៈពេលដែលមានកង្វះខាតខាងអាជ្ញាធរឯករាជ្យ ។

អត្ថបទនេះពិនិត្យទៅលើមូលហេតុដែលបណ្តាលឲ្យគណៈកម្មាធិការត្រូវបានបង្កើតឡើង និងហេតុដែលនាំឲ្យសមត្ថភាពមូលដ្ឋាននៅមានកម្រិត និងមធ្យោបាយមួយចំនួនដែលអាចឲ្យមានការវិវត្ត ។ ការតស៊ូមតិនៅទីនេះគឺថាគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាគមអាស៊ាន និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយនិងការពារសិទ្ធិស្ត្រីនិងកុមារអាស៊ានបានបង្កើតសិទ្ធិមនុស្សនៅក្នុងគោលបំណងពីរផ្សេងគ្នា ។ ទីមួយ គឺ "ការបង្កើត" សិទ្ធិមនុស្សដើម្បីគ្រប់គ្រងបរិយាកាសការិយាធិបតេយ្យ ហើយនិងអនុញ្ញាតឲ្យសមាជិកអាស៊ានវិនិច្ឆ័យនូវការរិះគន់ដោយការពិភាក្សាលើសិទ្ធិមនុស្សស្របទៅតាមលក្ខខណ្ឌនយោបាយដ៏មានសុវត្ថិភាពជាមួយនឹងសមាជិករដ្ឋាភិបាលក្នុងការគ្រប់គ្រងទៅតាមដំណាក់កាល និងអត្ថន័យក្នុងកិច្ចពិភាក្សា ។ គោលបំណងទីពីរ គឺគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាគមអាស៊ាន និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយនិងការពារសិទ្ធិស្ត្រីនិងកុមារ បង្កើតសិទ្ធិមនុស្សនៅក្នុងបរិបទដើម្បីធ្វើឲ្យបទដ្ឋានកាន់តែមានភាពច្បាស់លាស់និងការគ្រប់គ្រងមានទំនួលខុសត្រូវដោយត្រូវតែគោរពទៅតាមច្បាប់ ។

គណៈកម្មាធិការថ្មីនេះគឺជាតំណាងនៃភាពតានតឹងលើបទដ្ឋាន និងនយោបាយជុំវិញការជម្លោះរបស់អាស៊ានទៅលើបែបបទនៃការដោះស្រាយបញ្ហាសិទ្ធិមនុស្ស ។ ផ្នែកទីពីរនៃអត្ថបទនេះ គឺត្រូវបានពិភាក្សាអំពីផលវិបាកលើបទដ្ឋាន និងនយោបាយនៃការតស៊ូមតិនៅលើមាគ៌ាឆ្ពោះទៅកាន់ការបង្កើតយន្តការសិទ្ធិមនុស្សអាស៊ាន ។ ផ្នែកទីបីនឹងធ្វើការពិនិត្យទៅលើនីតិវិធីរបស់អាស៊ានលើសិទ្ធិមនុស្សដែលត្រូវបានឆ្លុះបញ្ចាំងពីចរិតលក្ខណៈនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សរបស់អាស៊ាន ។ ផ្នែកទីបួនគឺធ្វើការសង្ខេបពីភាពខុសគ្នានៃគណៈកម្មាធិការទទួលបន្ទុកការពារសិទ្ធិស្ត្រីនិងកុមារ និងទំនាក់ទំនងទៅនឹងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស ។ ចុងក្រោយ ផ្នែកទីប្រាំនឹងសរុបពីការពិភាក្សាទៅលើលទ្ធភាពយ៉ាងខ្លីខាងមុខពីការវិវត្តរបស់ស្ថាប័ន ។

## ២) មាគ៌ាឆ្ពោះទៅកាន់ក្រុមអាស៊ានសិទ្ធិមនុស្ស

### ក) កិច្ចខិតខំប្រឹងប្រែងក្នុងជម្លោះបទដ្ឋាន

បើយោងតាមទស្សនវិស័យរបស់សិទ្ធិមនុស្ស អាស៊ានពុំមានលទ្ធភាពក្នុងការសម្រេចបានកិច្ចការនេះទេ កាលពីដំបូងឡើយ ។ សមាគមត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦៧ នៅពេលដែលរដ្ឋាភិបាលប្រទេសអភិរក្សទាំងប្រាំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានចូលរួមរៀបចំបង្កើតដើម្បីជៀសវាងជម្លោះរវាងប្រទេសជិតខាង និងការបណ្តេញនូវរាល់លទ្ធិកុម្មុយនីស្ត ។ សមាគមបានអភិវឌ្ឍន៍នូវបទដ្ឋានមួយ ហើយអនុវត្តទៅតាមរាល់ការរៀបចំទំនាក់ទំនងអន្តររដ្ឋាភិបាលដោយមិនអនុញ្ញាតឲ្យសមាជិកនៅក្នុងរដ្ឋណាមួយជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសណាមួយឡើយ ។ ទាំងនោះរួមមានបទដ្ឋានដ៏តឹងរ៉ឹងនៃភាពគ្មានសិទ្ធិជ្រៀតជ្រែក និង "កិច្ចការអាស៊ាន" តាមផ្លូវការទូតដែលសង្កត់ធ្ងន់ទៅលើការប្រឹក្សា និងការព្រមព្រៀងជាជាងនីតិវិធីនៃការសម្រេចចិត្តផ្លូវការ និងស្របច្បាប់ ។ សមាជិករដ្ឋាភិបាលគឺមានភាពរីករាយក្នុងការចូលរួមចំណែកនៅក្នុងការវិនិច្ឆ័យកិច្ចការប្រទេសជាតិជាកិច្ចឆ្លើយតបសម្រាប់សហប្រតិបត្តិការ និងឧបសគ្គប្រឈមនានាក្នុងតំបន់ និងចែករំលែកនូវអ្វីដែលលោក អេរីក កូហុនគា បានឲ្យឈ្មោះថា គឺជា "សន្តិភាពអសេរីភាព" ។ សន្តិភាពអសេរីភាពរបស់អាស៊ានគឺចង់សំដៅទៅលើអសេរីភាពរបស់រដ្ឋក្នុងសង្គ្រាមអន្តររដ្ឋ ប៉ុន្តែសន្តិភាពអសេរីភាពនេះបែរជានាំមកនូវអន្តរាយ គឺថាសមាជិករដ្ឋាភិបាលប្រឈមនឹងមតិរិះគន់ក្នុងតំបន់នៅពេលដែលប្រើប្រាស់របបកុម្មុយនីស្ត និងការបំបែកនិយមក្នុងការបង្ហាញភាពលាក់បាំងការអនុវត្តផ្ទៃក្នុង ។

បញ្ហាសិទ្ធិមនុស្សកម្រនឹងត្រូវបានលាតត្រដាងក្នុងការពិភាក្សាជាផ្លូវការអំឡុងពេលសង្គ្រាមត្រជាក់ ។ រាជរដ្ឋាភិបាលបានជួបប្រទះនឹងសម្ពាធម្តងៗពីខាងអ្នកគាំទ្រ និងពួកមូលធនខាងលិចនៅក្នុងការបញ្ជាក់ពីការរំលោភបំពានលើសិទ្ធិមនុស្ស ជាពិសេសគឺនៅពេលដែលគណបក្សឆ្វេងនិយមមានសិទ្ធិអំណាចខ្លាំងនៅប្រទេសអាមេរិកនិងខាងប៉ែកអឺរ៉ុប ប៉ុន្តែសម្ពាធទាំងនេះជាទូទៅគឺនៅមានកម្រិតខ្សោយ ។ រដ្ឋរបស់អាស៊ានហើយនិងដៃគូសន្តិសុខប្រទេសលោកខាងលិចរបស់ពួកគេមានការព្រួយបារម្ភទៅលើការត្រៀមខ្លួនប្រឆាំងជាមួយនឹងសត្រូវកុម្មុយនីស្ត ស្របពេលជាមួយនឹងការលាតសន្ធឹងនៃកុបកម្មនិងសង្គ្រាមឥណ្ឌូចិន ។

### ខ) ការជំរុញសិទ្ធិមនុស្សជំហានដំបូងរបស់អាស៊ាន

បញ្ហាសិទ្ធិមនុស្សគឺត្រូវបានគេបញ្ច្រៀតចូលទៅក្នុងកិច្ច

ពិភាក្សាអាស៊ានជាច្រើនចាប់តាំងពីដើមទសវត្សរ៍៩០ ។ សម្ពាធទាំងខាងក្រៅនិងខាងក្នុងទៅលើរដ្ឋាភិបាលអាស៊ានបានតម្រូវឲ្យមានការធ្វើការផ្លាស់ប្តូរឲ្យបានឆាប់រហ័ស ។ នៅខណៈពេលដែលការគំរាមកំហែងពីសង្គ្រាមត្រជាក់ត្រូវបានធ្លាក់ចុះ វាបានក្លាយបញ្ហាកាន់តែលំបាកសម្រាប់រដ្ឋាភិបាលនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ ធ្វើការកំណត់នូវការគ្រប់គ្រងនយោបាយក្នុងស្រុក ព្រមទាំងរឿងរ៉ាវអតីតកាលមិនល្អដែលធ្លាប់បានកើតឡើង បានទាញចំណាប់អារម្មណ៍អន្តរជាតិ ជាពិសេសទៅលើការរំលោភបំពានសិទ្ធិនៅក្នុងតំបន់ ។ ជាឧទាហរណ៍ជាក់ស្តែងដែលបានកើតឡើងនៅក្នុងប្រទេសភូមា រដ្ឋាភិបាលយោធាបានបដិសេធ និងមិនព្រមទទួលយកនូវលទ្ធផលនៃការបោះឆ្នោតជាតិក្នុងឆ្នាំ១៩៩០ ហើយព្រមទាំងបានដាក់គុកលោកស្រី អ៊ុងសាន ស៊ូជី ថែមទៀតផង និងការសម្លាប់ដ៏ឃោរឃៅទៅលើអ្នកប្រឆាំងជនជាតិទីម័រ នៅក្នុងតំបន់ឌីលីដោយក្រុមទាហានឥណ្ឌូនេស៊ីនៅក្នុងឆ្នាំ១៩៩១និងឆ្នាំ១៩៩២ ។ "ខែឧសភាងងឹត" ដែលត្រូវបានគេស្គាល់ថាជាព្រឹត្តិការណ៍មួយការដាក់ទណ្ឌកម្មទៅលើទាហានប្រឆាំងគាំទ្រលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសថៃដែលទាំងនេះជាហេតុនាំឲ្យមានការរិះគន់ពីសំណាក់ជាតិ និងអន្តរជាតិ ។

បើទោះបីជាការរិះគន់ត្រូវបានបញ្ជូនដោយផ្ទាល់ទៅកាន់រាជរដ្ឋាភិបាលជាតិនីមួយៗក៏ដោយ អាស៊ាននៅតែត្រូវបានប្រឈមមុខនឹងការទាមទារឲ្យធ្វើសកម្មភាពឲ្យបានច្បាស់លាស់ ។ សម្ពាធពីខាងក្រៅមកពីប្រភពផ្សេងៗគ្នានោះរួមមានទាំងក្រុមឃ្លាំមើលអន្តរជាតិ និងរដ្ឋាភិបាល ។ រដ្ឋាភិបាលប្រទេសលោកខាងលិចបានដាក់ទណ្ឌកម្មទៅលើប្រទេសភូមា ហើយលោកស្រី អ៊ុងសាន ស៊ូជី បានទទួលពានរង្វាន់ណូបែលសន្តិភាពនៅក្នុងឆ្នាំ១៩៩១ ។ មិត្តរបស់ភាគីប្រទេសលោកខាងលិចមិនរីករាយក្នុងការទទួលយកនូវមតិដែលមិនគួរសមណាមួយទេ ។ សហរដ្ឋអាមេរិកបានបន្ថយទំនាក់ទំនងខាងផ្នែកយោធាជាមួយទីក្រុងបាងកកនិងទីក្រុងចាកាតាដែលនេះជាសញ្ញាមួយបង្ហាញថា ទីក្រុងវ៉ាស៊ីនតោនមានឆន្ទៈនៅក្នុងការលើកស្ទួយនូវសិទ្ធិសេរីភាពនិយម ព្រមទាំងមិនព្រមទទួលយកនូវការសុំជំនួយពីខាងយោធានៅក្នុងការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយក្នុងសង្គមថ្មីនេះ ។ លើសពីនេះទៅទៀត អាស៊ានចាប់ផ្តើមប្រឈមមុខទៅនឹងសម្ពាធនៃការយកចិត្តទុកដាក់ទៅលើសិទ្ធិមនុស្សពីគ្រប់តំបន់ ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងនេះទៀតនោះគឺអ្នកដឹកនាំនៃវិទ្យាស្ថានស្ថិតិ និងសិក្សាអន្តរជាតិរបស់អាស៊ានដែលជាបណ្តាញនៃក្រុមអ្នកជំនាញដ៏មានសក្តានុពលមួយ បានស្នើសុំនៅក្នុងឆ្នាំ១៩៩២ ឲ្យរដ្ឋមន្ត្រីការបរទេសអាស៊ានគួរតែពិចារណាពីការបង្កើតយន្តការសិទ្ធិមនុស្សក្នុងតំបន់ ។

មានការកត់ត្រាមួយបានបង្ហាញថារដ្ឋមន្ត្រីអាស៊ានជាច្រើនបានចូលរួមក្នុងកិច្ចប្រជុំមួយដែលមានប្រទេសមកពីគ្រប់តំបន់អាស៊ីបានចូលរួមទៅលើសិទ្ធិមនុស្សនៅខែមីនា ឆ្នាំ១៩៩៣នៅទីក្រុងបាងកក ។ ដោយនៅទីនោះ រដ្ឋាភិបាលតំណាងឲ្យប្រទេសក្នុងតំបន់អាស៊ីជាមួយនឹងការរំពឹងទុកនៃសន្និសីទអង្គការសហប្រជាជាតិ ពិភពលោកបានធ្វើការប្រកាសជាសាធារណៈអំពីឆន្ទៈរបស់ខ្លួនទៅលើសិទ្ធិមនុស្ស និងបណ្តុះស្មារតីក្នុងការបង្កើតក្រុមសិទ្ធិមនុស្សក្នុងតំបន់ ដោយនិយាយបញ្ជាក់ម្តងហើយម្តងទៀតថា "តម្រូវការពេលវេលាដើម្បីជំរុញលទ្ធភាពនៅក្នុងការរៀបចំបង្កើតឲ្យមានក្នុងតំបន់នូវការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ី" ។

កន្លងបានពីរបីខែក្រោយមក សន្និសីទអង្គការសហប្រជាជាតិពិភពលោកបានចេញនូវសេចក្តីប្រកាសជាសាធារណៈ នៅទីក្រុងវៀន ប្រទេសអូទ្រីស និងកម្មវិធីសកម្មភាពហើយបានអំពាវនាវទៅកាន់រដ្ឋជាសមាជិកទាំងអស់ឲ្យបង្កើតនូវក្រុមសិទ្ធិមនុស្សដែលពុំធ្លាប់មានពីមុនមក ។ នៅក្នុងអំឡុងពេលកិច្ចប្រជុំប្រចាំឆ្នាំដែលធ្វើឡើងនៅក្នុងខែកក្កដា ឆ្នាំ១៩៩៣ រដ្ឋមន្ត្រីការបរទេសអាស៊ានបានធ្វើការបញ្ជាក់ថា "ខ្លួនមានឆន្ទៈនៅក្នុងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន" ហើយក៏បានយល់ស្របថា "អាស៊ានគួរតែពិចារណាទៅលើការបង្កើតយន្តការសិទ្ធិមនុស្សដ៏សមរម្យមួយក្នុងតំបន់" ។ ពីរខែក្រោយមក ស្ថាប័នអន្តររដ្ឋសភាអាស៊ានដែលបង្កើតឡើងក្នុងឆ្នាំ១៩៧៧ នៅអាស៊ីអាគ្នេយ៍ ដើម្បីបង្កឲ្យមានទំនាក់ទំនងប្រសើរ រវាងមន្ត្រីអាស៊ាននៅនឹងអ្នកគាំទ្ររបស់ខ្លួនបានប្រកាសជាសាធារណៈទៅតាមមតិស្នើសុំនោះ ។

### ក) ការការពារ "ទស្សនៈយល់ឃើញក្នុងតំបន់អាស៊ី"

ទោះបីជាប្រទេសមានការអភិវឌ្ឍន៍យ៉ាងណាក៏ដោយ រដ្ឋាភិបាលអាស៊ាននៅតែស្ថិតនៅឆ្ងាយពីការធានាតួនាទីយ៉ាងសំខាន់របស់សមាគមនៅក្នុងការលើកស្ទួយ និងការការពារសិទ្ធិ

មនុស្ស ។ ជាច្រើនឆ្នាំបន្ទាប់មកទៀត ពុំមានរដ្ឋាភិបាលអាស៊ាន រូបណាបានមកបង្ហាញពីការស្នើសុំដីដាក់លាក់មួយ ឬមួយក៏ដាក់បញ្ហានានាទៅក្នុងរបៀបវារៈរបស់មន្ត្រីការបរទេសឡើយ ។ លើសពីនេះទៅទៀតសេចក្តីប្រកាសជាសាធារណៈនៅទីក្រុងបាងកក កាលពីឆ្នាំ១៩៩៣នោះមិនគ្រាន់តែបានបញ្ជាក់តែពីសារសំខាន់នៃរឿងសិទ្ធិមនុស្សប៉ុណ្ណោះទេ ថែមទាំងឆ្លៀតឱកាសបង្ហាញពីការរិះគន់របស់ប្រទេសលោកខាងលិចទៅលើការកើនឡើងនៃកប៉ាល់យោធាក្នុងទ្វីបអាស៊ី ហាក់បីដូចជាការបង្ហាញច្បាស់នៃជម្លោះលើ "ទស្សនៈយល់ឃើញតំបន់អាស៊ី" ។

មានការសរសេរជាច្រើនអំពីការតស៊ូមតិទៅលើទស្សនៈយល់ឃើញរបស់អាស៊ីដែលរួមមាននាយករដ្ឋមន្ត្រីម៉ាឡេស៊ី លោក មហាធៀ មហាម៉េត អ្នកដឹកនាំសិង្ហបុរីលោក លី ក្វាន់យូ ហើយនិងអ្នកផ្សេងៗទៀតបានចោទប្រកាន់ទៅកាន់លោកខាងលិចដែលបង្ខំឲ្យអាស៊ីទទួលយកនូវគំនិតសិទ្ធិមនុស្ស នៅខណៈពេលដែលអាស៊ីពឹងផ្អែកទៅលើវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ខ្លួនជាប់រហូតរៀងមក ។ អ្នកគាំទ្រទៅនឹងទស្សនៈយល់ឃើញរបស់អាស៊ីបានអះអាងថា សង្គមអាស៊ីបានដាក់ចំណងទាក់ទងសំខាន់ទៅលើសហគមន៍ច្រើនជាងខ្លួនឯង ។ មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងបានប្រកែកថា ស្ថិរភាពនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចគឺជាការចាំបាច់ដែលនាំមកនូវសិទ្ធិសេរីភាពខាងនយោបាយដែលវាផ្ទុយពីគំនិតរបស់អ្នកជំនាន់មុន ហើយសិទ្ធិរបស់អ្នកជំនាន់ក្រោយជារឿយៗ គឺត្រូវបានប្រើនៅក្នុងកិច្ចពិភាក្សាលោកខាងលិចដែលក្តោបទៅលើសិទ្ធិសង្គមស៊ីវិល និងសិទ្ធិសេរីភាពខាងនយោបាយជាអាទិភាព ។

ទោះបីជាការតស៊ូមតិពីទស្សនៈយល់ឃើញរបស់អាស៊ីជាធម្មតាគឺបានធ្លាក់ចូលទៅក្នុងការជជែកវែកញែកដ៏ក្តៅគគុកទៅលើបញ្ហាវប្បធម៌ និងនីតិវិធីនយោបាយដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួននោះ ក៏ប៉ុន្តែវាបានឆ្លុះបញ្ចាំងពីការតស៊ូជម្នះយកលក្ខខណ្ឌបទដ្ឋានដ៏ពិតប្រាកដមួយ ព្រមទាំងបានចង្អុលបង្ហាញពីការព្រួយបារម្ភផ្នែកនយោបាយលើដំណើរការសិទ្ធិមនុស្សទៅកាន់តំបន់ពោរពេញដោយអំណាចនៅអាស៊ី ។ ការព្រួយបារម្ភទាំងនេះហើយបង្កើតបានជាទុននៅក្នុងការចូលរួមបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកការពារសិទ្ធិស្ត្រីនិងកុមារ ។

អ្វីដែលជាការព្រួយបារម្ភដ៏ខ្លាំងក្លារបស់អាស៊ីនោះគឺ ដំណើរការសិទ្ធិមនុស្សនឹងត្រូវបានគេប្រើជាធ្នាក់សម្រាប់ការអនុវត្តបុព្វសិទ្ធិនយោបាយលោកខាងលិច ។ សេចក្តីប្រកាសជាសាធារណៈនៅទីក្រុងបាងកកក្នុងឆ្នាំ១៩៩៣ បានព្រមានប្រឆាំងទៅនឹងគំនិតដែលថា "ស្តង់ដារទ្វេ" និងការប្រើប្រាស់សិទ្ធិមនុស្សក្នុងលក្ខខណ្ឌនៃការអភិវឌ្ឍន៍ណាមួយនោះឬក៏ថាជា "ឧបករណ៍នៃសម្ពាធនយោបាយ" ។ លើសពីនេះទៅទៀតនោះ សេចក្តីប្រកាសនោះក៏បានសង្កត់ធ្ងន់ទៅលើចំណុចសំខាន់មួយចំនួនដូចជាភាពគ្មានសិទ្ធិជ្រៀតជ្រែកនៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ តួនាទីមូលដ្ឋានរបស់រដ្ឋដែលជាអ្នកឃ្លាំមើលសិទ្ធិមនុស្ស និងតម្រូវការពិចារណាទៅលើលក្ខណៈពិសេសជាតិ និងតំបន់រួមទាំងផ្នែកវប្បធម៌ ។ ទាំងនេះគឺជាការបញ្ជាក់ទៅកាន់ក្រុមប្រទេសខាងលិចយ៉ាងច្បាស់ណាស់ថា គឺគំរាមមិនឲ្យប្រើប្រាស់សិទ្ធិមនុស្សនៅក្នុងការទាញយកផលប្រយោជន៍ បន្ទុចបន្ទាក់ការកាន់តំណែងនៅក្នុងតំបន់អាស៊ី ។ ម្យ៉ាងទៀតដោយសារតែមន្ត្រីអាស៊ានជាច្រើនធ្លាប់មានបទពិសោធទៅនឹងច្បាប់អាណានិគម និងការឈ្លានពានទឹកដីរបស់ជនបរទេសបានធ្វើឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ព្រមទាំងយល់ច្បាស់ពីឧបាយកលរបស់លោកខាងលិចដោយគ្រាន់តែយកបញ្ហារំលោភបំពានសិទ្ធិមនុស្សមកធ្វើជាលេស ។

មន្ត្រីនៅអាស៊ីជាច្រើន ក៏មានភាពភ័យខ្លាចផងដែរទៅនឹងដំណើរការសិទ្ធិមនុស្សនេះ ហើយជាពិសេសគឺការជំរុញឲ្យមានសិទ្ធិនយោបាយ និងសិទ្ធិសង្គមស៊ីវិលគឺជាការបំបិទផ្លូវខ្លួនឯង ។ មន្ត្រីអាស៊ានភាគច្រើនបានចំណាយពេលវេលាជាច្រើនទសវត្សរ៍នៅក្នុងការរួមបញ្ចូលច្បាប់គ្រប់គ្រងថ្មី និងរៀបចំនូវសណ្តាប់ធ្នាប់សង្គមនិងប្រជាជនឲ្យមានរបៀបរៀបរយដោយរួមបញ្ចូលទាំងទុនដែលបានមកពីអំណាចជនបរទេស ។ ការបង្កើននូវសិទ្ធិសេរីភាពខាងនយោបាយមានន័យថាជាការបង្កឲ្យមានហានិភ័យនៃស្ថេរភាពក្នុងស្រុក ការធ្វើឲ្យច្របូកច្របល់ផ្នែកសេដ្ឋកិច្ច និងការធ្វើឲ្យបាត់បង់សិទ្ធិអំណាចផ្ទាល់ខ្លួន ។

ក្រុមគាំទ្រអង្គការអន្តរជាតិ និងរដ្ឋាភិបាលប្រទេសលោកខាងលិច ហាក់បីដូចជាមានទំនោរទៅរកសិទ្ធិស៊ីវិល និងនយោបាយថាជាសិទ្ធិរួមមានសេរីភាពក្នុងការបញ្ចេញមតិសេរីភាពក្នុងការចូល

រួម និងសេរីភាពក្នុងការសរសេរគឺជាសិទ្ធិដ៏ត្រឹមត្រូវមួយដែលអាចមានអំណាចលើអ្នកប្រឆាំងខាងនយោបាយ ។ ក្រុមទាំងនោះក៏មានទំនោរទៅលើតម្រូវការទេគឺការការពារសិទ្ធិមនុស្ស និងតម្រូវការប្រជាធិបតេយ្យ ទាំងនេះហើយដែលបន្ថែមគំនាបទៅលើជនមូលធននិយមនៅអាស៊ី ។ រដ្ឋាភិបាលអាស៊ីបាននិយាយសង្កត់ធ្ងន់មកវិញទៅលើសិទ្ធិខាងសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដូចជាសិទ្ធិទទួលបាននូវការអប់រំសុខភាព និងការរស់នៅសមរម្យ ។ ការថ្លែងការណ៍ជាសាធារណៈនៅទីក្រុងបាងកកក្នុងឆ្នាំ១៩៩៣ បានសង្កត់ធ្ងន់ទៅលើ «ភាពមិនអាចបែងចែកបាននៃសិទ្ធិខាងសេដ្ឋកិច្ច សង្គម វប្បធម៌ស៊ីវិល និងនយោបាយ» ដែលបញ្ជាក់អំពីយន្តការសិទ្ធិមនុស្សដ៏គួរឲ្យព្រួយបារម្ភ «ជាប់ទាក់ទងចម្បងទៅនឹងផ្នែកតែមួយនៃសិទ្ធិ» និងលើកយកពាក្យសម្ដីដែលថា ការលុបបំបាត់ភាពក្រីក្រគឺជាការបំពេញតម្រូវការសិទ្ធិមនុស្ស ។ សេចក្ដីប្រកាសជាសាធារណៈមួយអំពី «សិទ្ធិនៅក្នុងការអភិវឌ្ឍ» យោងតាម «សិទ្ធិសកល និងសិទ្ធិពីកំណើត» ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងពិធីថ្លែងការណ៍ទូទៅរបស់សភាអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៨៦ ។

ការបង្វែរទិសដៅពីសេរីភាពខាងស៊ីវិល និងនយោបាយទៅជាសេចក្ដីត្រូវការខាងផ្នែកសេដ្ឋកិច្ចគឺមានភាពសមស្របទៅនឹងគោលបំណងនៃការអភិវឌ្ឍន៍ ។ ចំណុចនេះមានន័យថា គឺជាការកាត់បន្ថយនូវការយកចិត្តទុកដាក់ទៅលើសេរីភាពខាងនយោបាយ និងការប្រើភាសាសិទ្ធិមនុស្សនៅក្នុងការកំណត់ពីតួនាទីចម្បងរបស់រដ្ឋាភិបាលអាស៊ី ដើម្បីរៀបចំការអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន ហើយជួនកាលលាក់កំបាំងនូវសត្រូវនយោបាយដោយប្រើប្រាស់នូវប្រយោជន៍ទាំងអស់នេះ ។ វាក៏បានគាំទ្រពីការបើកចំហនូវវេទិកាពិភាក្សារិះគន់ពីលោកខាងលិចដែលមានភាពយឺតយ៉ាវក្នុងការទទួលស្គាល់ពីសិទ្ធិសេដ្ឋកិច្ច និងសង្គមជាជាងសិទ្ធិស៊ីវិល និងនយោបាយ ។ «សិទ្ធិនៅក្នុងការអភិវឌ្ឍ» បានដាក់បន្ទុកយ៉ាងធ្ងន់ទៅលើប្រទេសអភិវឌ្ឍក្នុងការការពារដែលបង្កប់ន័យថាប្រទេសអភិវឌ្ឍន៍គឺមានតួនាទីក្នុងការផ្ដល់ជំនួយហិរញ្ញវត្ថុនានាទៅកាន់ប្រទេសក្រីក្រដើម្បីធ្វើការអភិវឌ្ឍន៍ ។

ការតបតអាស្រ័យលើការយល់ឃើញរបស់អាស៊ីដែលដឹកនាំដោយប្រមុខរដ្ឋជាន់ខ្ពស់អាស៊ានគឺបានចាក់ឫសទៅក្នុងផ្នែកមួយនៃការយល់ឃើញខុសប្លែកគ្នាដែលមានទំនាក់ទំនងទៅនឹងភាពខុសប្លែកគ្នានៃសារសំខាន់សង្គមតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយប្រមុខរដ្ឋមួយចំនួនគឺមានមូលដ្ឋានអំណាចនយោបាយនៃការកាន់ដំណែងរួចទៅហើយ ។ អ្នកដឹកនាំ «ផ្ដាច់ការ» ដូចជាលោក មាហាធៀ, លីក្វាន់យូ និងលោក ស៊ូហារតូ មិនបានបដិសេធទៅនឹងសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗដែលជាតម្រូវការសង្គមទេ ប៉ុន្តែលោក លីអាន ថៃយូ បានបដិសេធថា វាជា «យុទ្ធសាស្ត្រទូទៅ» តែប៉ុណ្ណោះ ។ នៅត្រង់ចំណុចនេះគាត់មិនទទួលយកថា សិទ្ធិមនុស្សគឺជាសិទ្ធិពីធម្មជាតិឬពីកំណើតដែលឈានដល់ការសម្រេចនីមួយៗរបស់រដ្ឋាភិបាល ប៉ុន្តែគាត់បែរជាគិតថាអ្នកទាំងនោះប្រើប្រាស់សិទ្ធិដូចជា ទំនិញនៅក្នុងកិច្ចពិភាក្សាសង្គមដោយពឹងលើវប្បធម៌សង្គម និងដំណាក់កាលនៃការអភិវឌ្ឍន៍ទៅវិញ ។

ការសំខាន់នោះគឺអ្នកនយោបាយគាំទ្រដំណើរការការយល់ឃើញអាស៊ីបានចាត់ទុកខ្លួនឯងថាជាអាជ្ញាធរដ៏សមរម្យនៅក្នុងការដឹកនាំកិច្ចពិភាក្សាថាតើសិទ្ធិណាដែលគួរតែត្រូវបានគេទទួលស្គាល់ និងទៅតាមកម្រិត ។ គ្មានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលទេដែលអ្នកកាន់ដំណែងទាំងនោះចង្អុលបង្ហាញអ្វីដែលជាកិច្ចព្រមព្រៀងរបស់សង្គម ហើយបន្តជំរុញឲ្យក្រិត្យក្រមរបស់ពួកគេត្រូវបានគេទទួលស្គាល់និងបញ្ចៀសនូវប្រព័ន្ធបក្សចម្រុះដែលនាំឲ្យមានការបាចសាចនៅក្នុងការសម្រេចចិត្តទៅលើសិទ្ធិមនុស្ស ។ ប្រទេសថៃ និងហ្វីលីពីនបោះសន្ទុះទៅមុខទៅលើសិទ្ធិមនុស្ស ប៉ុន្តែនៅខណៈពេលដែលអាស៊ានបានបន្ថែមប្រទេសគ្មានសេរីភាពពេញលេញចំនួនបួនទៅក្នុងបញ្ជីឈ្មោះសមាជិក នៅចន្លោះឆ្នាំ១៩៩៥និង១៩៩៩ រួមមានប្រទេសកម្ពុជា ភូមា ឡាវ និងវៀតណាម នាំឲ្យមានអតុល្យភាពពីការបើកចំហនៃសិទ្ធិសេរីភាពលើផ្នែកស៊ីវិលនិងនយោបាយ ។

## ឃ) ការផ្លាស់ប្ដូរឥទ្ធិពលនៅអាស៊ី

ទោះបីជាមានការតស៊ូមតិទស្សនៈយល់ឃើញរបស់អាស៊ី និងបញ្ហាសិទ្ធិអំណាចនៅក្នុងប្រទេសកម្ពុជា ភូមា ឡាវ និងវៀតណាម ដែលជាសមាជិកថ្មីរបស់អាស៊ានយ៉ាងណាក៏ដោយការបញ្ជ្រាបសិទ្ធិមនុស្សគឺបានកើនឡើងគួរឲ្យកត់សម្គាល់នៅក្នុងរបៀបវារៈរបស់អាស៊ាននៅឆ្នាំ បន្ទាប់ពីការប្រកាសជាផ្លូវការនៅទីក្រុងបាងកកឆ្នាំ១៩៩៣ ។ ការដាក់សម្ពាធរបស់ប្រទេសលោកខាងលិចមានលក្ខណៈច្រើនសណ្ឋានដូចជា ការប្រកាសជាសាធារណៈពីអ្នកដែល

មិនគោរពតួនាទី ការគាំទ្រក្រុមសង្គមស៊ីវិលក្នុងតំបន់ ការផ្លាស់ប្តូរប្រព័ន្ធអប់រំ ការដាក់ទណ្ឌកម្ម និងការពន្យារពេលផ្តល់ជំនួយជាដើម ។ អ្វីដែលសំខាន់គឺជាគន្លឹះនៃការផ្លាស់ប្តូរនយោបាយក្នុងស្រុកនៅតំបន់អាស៊ី និងឥទ្ធិពលនៃការគាំទ្រនៅអាស៊ី រួមមានការបង្កើនចល័តភាពនៃក្រុមសង្គមស៊ីវិលអាស៊ាន ក្រុមអ្នកជំនាញនិងមន្ត្រីមនុស្សធម៌ ។

ក្រុមសង្គមស៊ីវិល និងក្រុមជំនាញ គឺជាភ្នាក់ងារដ៏ចាំបាច់សម្រាប់ការផ្លាស់ប្តូរ និងជួយសម្របសម្រួលកាត់បន្ថយសម្ពាធសិទ្ធិមនុស្សរបស់រដ្ឋាភិបាលអាស៊ីទៅលើរបៀបវារៈអាស៊ាន ។ នៅក្នុងឆ្នាំ១៩៩៤ វិទ្យាស្ថានស្ថិតិនិងសិក្សាអភិវឌ្ឍន៍ក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន បានធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចពិភាក្សាប្រចាំឆ្នាំជាលើកដំបូងរបស់វិទ្យាស្ថានស្ថិតិនិងសិក្សាអន្តរជាតិអាស៊ានទៅលើសិទ្ធិមនុស្ស ។ ឆ្នាំបន្តបន្ទាប់ទៀត អង្គការអន្តរជាតិមួយដែលមានឈ្មោះជាភាសាអង់គ្លេសថា *LAWASIA* ដែលដឹកនាំដោយមេធាវីចៅក្រម និងក្រុមអ្នកច្បាប់បានបង្កើតការងារក្រុមមួយសម្រាប់យន្តការសិទ្ធិមនុស្សអាស៊ាន ដែលជាសក្ខីភាពក្នុងការបង្កើតក្រុមសិទ្ធិមនុស្ស ។ ក្នុងឆ្នាំ១៩៩៨ អាស៊ានបានចូលខ្លួនជាផ្លូវការថាជាដៃគូនៅក្នុងការងារក្រុម ។ ក្រុមការងារនេះជាអ្នកប្រកាសពីកិច្ចប្រជុំជាផ្លូវការជាច្រើនដែលទាក់ទងនឹងសង្គមស៊ីវិលនិងតំណាងរដ្ឋាភិបាល ព្រមទាំងការធ្វើបទបង្ហាញពីសេចក្តីព្រាងសម្រាប់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សក្នុងតំបន់នៅឆ្នាំ២០០០ ។

នៅក្នុងឆ្នាំនោះវិទ្យាស្ថានស្ថិតិ និងសិក្សាអន្តរជាតិអាស៊ាន ក៏បានចាប់ផ្តើមផ្តល់ឲ្យរដ្ឋសភាប្រជាជនអាស៊ាននូវដំណើរការការទូត “ជំហានទី២” ដែលផ្តល់ភាពងាយស្រួលក្នុងការភ្ជាប់ទំនាក់ទំនងមន្ត្រីជាមួយនឹងអ្នកគាំទ្រសង្គមស៊ីវិល ។ របាយការណ៍លើកដំបូងរបស់រដ្ឋសភាប្រជាជនអាស៊ានបង្កើតនូវការស្នើសុំស្នូលទាំងប្រាំបួនសម្រាប់ប្រមុខរដ្ឋអាស៊ានរួមនឹងចំណុចដ៏ជាក់លាក់ទាំងប្រាំយោងទៅតាមសិទ្ធិមនុស្ស ។ រដ្ឋសភាប្រជាជន អាស៊ានបានរៀបចំនូវតារាងពិន្ទុសិទ្ធិមនុស្សអាស៊ានថ្មីមួយ និងបានអំពាវនាវឲ្យអ្នកដឹកនាំអាស៊ានទាំងអស់ត្រូវបង្កើតយន្តការក្នុងតំបន់សម្រាប់លើកស្ទួយនិងការពារសិទ្ធិមនុស្ស ។

សន្ទុះនយោបាយអន្តររដ្ឋបានដើរតួនាទីដូចជា រដ្ឋាភិបាលអាស៊ីមួយចំនួនដែលសំឡឹងឃើញថាសមាគមនេះ គួរតែពង្រីងតួនាទីក្នុងការការពារសិទ្ធិមនុស្សបន្ថែមទៀត ។ នៅចុងទសវត្សរ៍៩០ មន្ត្រីអាស៊ីស្របខាងសេរីនិយមចាប់ផ្តើមប្រឈមមុខទៅនឹងបទដ្ឋាននៃភាពគ្មានសិទ្ធិជ្រៀតជ្រែក ហើយនៅពេលដែលមន្ត្រីការបរទេសថៃ ដែលឥឡូវនេះជាលេខាធិការជាន់ខ្ពស់អាស៊ានគឺលោក សូរិន្ទ ពិតសូវ៉ាន់ គាំទ្រនូវគោលនយោបាយ “ការបត់បែននៃកិច្ចសន្យា” ជាមធ្យោបាយក្នុងការដោះស្រាយបញ្ហាដែលភាយចេញពីប្រទេសភូមាបានធ្វើឲ្យខូចខាតទៅដល់កេរ្តិ៍ឈ្មោះខាងក្រៅរបស់អាស៊ាន និងរំខានដល់ទំនាក់ទំនងជាមួយប្រទេសលោកខាងលិច ។

សន្ទុះក្នុងតំបន់ដ៏សំខាន់មួយទៀតគឺទំនោរឆ្ពោះទៅរកការបង្កើតសិទ្ធិមនុស្សជាមួយនឹងគន្លឹះនៃរដ្ឋអាស៊ាន ។ អំឡុងក្រោយពេលសង្គ្រាមត្រជាក់មានតែប្រទេសហ្វីលីពីនដែលមានគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨៦ ដោយការសម្រេចរបស់ប្រធានាធិបតី ខូរ៉ាសិន អាគីណូ អនុលោមទៅតាមជនផ្តាច់ការ ហ្វឺឌីណង់ ម៉ាកូស ។ នៅក្នុងឆ្នាំ១៩៩៣ ប្រទេសឥណ្ឌូនេស៊ីក៏បានបង្កើតគណៈកម្មាធិការជាតិមួយគឺខមណាសហាម មានសណ្តានចិត្តយ៉ាងទូលំទូលាយនៅក្នុងការចូលរួមទៅតាមសម្លេងស្រែករបស់អន្តរជាតិលើការលុបលាងការសម្លាប់រង្គាលក្នុងតំបន់ឌីលី ។ ការផ្លាស់ប្តូរយ៉ាងសំខាន់នោះគឺប្រទេសឥណ្ឌូនេស៊ី ដែលធ្លាប់កាន់របបយោធាដ៏តឹងរ៉ឹងបែរមករករដ្ឋាភិបាលមួយមានប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពពេញលេញបន្ទាប់ពីការធ្លាក់ដំណែងរបស់លោក ស៊ូហារតូ ក្នុងឆ្នាំ១៩៩៨ ។ ប្រទេសម៉ាឡេស៊ីបានបង្កើតគណៈកម្មាធិការមួយដែលមានឈ្មោះថា សុហាខាម ។ ក្នុងឆ្នាំ១៩៩៩ នៅខណៈពេលដែលអ្នកដឹកនាំប្រឆាំងគឺលោក អាន់វ៉ា អ៊ីប្រាហ៊ីម និងអនុប្រធានាធិបតីរបស់សហរដ្ឋអាមេរិក លោក អាល់ហ្គ័រ បានធ្វើការរិះគន់យ៉ាងខ្លាំងទៅលើកំណត់ត្រាសិទ្ធិមនុស្សរបស់លោក មហាធៀ ។ ថៃបានបង្កើតគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សជាតិមួយក្នុងឆ្នាំ២០០១ ហើយបានបញ្ឈប់បដិវត្តន៍គណៈរដ្ឋមន្ត្រីក្នុងរយៈពេលខ្លីបន្ទាប់ពីកិច្ចការ“ខែឧសភាងងឹត”ក្នុងឆ្នាំ១៩៩២នៅពេលដែលរដ្ឋាភិបាលថៃប្រឈមមុខនឹងសម្ពាធដ៏ធ្ងន់ធ្ងរពីអង្គការសិទ្ធិមនុស្សមួយចំនួន ។

### ៨) ផែនការសម្រាប់ទីភ្នាក់ងារលើសិទ្ធិស្ត្រីនិងកុមារ

នៅចុងទសវត្សរ៍៩០ សិទ្ធិមនុស្សគឺបានចាក់ឫសទៅក្នុងការ

ថ្លែងសុន្ទរកថារបស់អាស៊ានហើយទិសដៅសិទ្ធិមនុស្សរបស់សមាគមក៏មានសភាពច្បាស់លាស់ និងមានមហិច្ឆតាប្រសើរជាងមុន ។ ក្នុងឆ្នាំ១៩៩៨ ផែនការសកម្មភាពរបស់ទីក្រុងហាណូយដែលជាក្រុមផែនការប្រាំឆ្នាំលើកដំបូងដើម្បីឲ្យសម្រេចបានគោលដៅក្នុងឆ្នាំ២០២០ ក្នុងតំបន់អាស៊ាននៃ «សន្តិភាព ស្ថេរភាព និងវិបុលភាព» សមាជិកទាំងអស់បានយល់ព្រមទៅលើតែ «ការបន្ថែមការផ្លាស់ប្តូរព័ត៌មាននៅក្នុងផ្នែកសិទ្ធិមនុស្ស» ហើយនឹងកិច្ចការឆ្ពោះទៅរកការអនុវត្តអនុសញ្ញាអន្តរជាតិលើសិទ្ធិស្ត្រីនិងកុមារ ។ ដំណើរការនេះគឺមានភាពងាយស្រួលក្នុងការទទួលយកក្នុងតំបន់ដោយសាររដ្ឋសមាជិកអាស៊ានធ្លាប់បានទទួលស្គាល់សិទ្ធិស្ត្រីនិងកុមារក្នុងច្បាប់អន្តរជាតិរួចទៅហើយ ។ ប្រទេសទាំងអស់បានផ្តល់សច្ចាប័ន ឬការយល់ព្រមទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ហើយប្រទេសស្ទើរតែទាំងអស់បានផ្តល់សច្ចាប័នឬការយល់ព្រមទៅលើអនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។

ក្នុងរវាងឆ្នាំ២០០៨និង២០១០នៃកម្មវិធីសកម្មភាពទីក្រុងវៀងចាន់សមាជិកទាំងអស់បានយល់ព្រមក្នុងការ «លើកស្ទួយសិទ្ធិមនុស្ស» ត្រួតពិនិត្យសាឡើងវិញនូវយន្តការសិទ្ធិមនុស្សដែលមានស្រាប់បង្កើតនូវអនុស្សរណៈយោគយល់ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការ លើកស្ទួយនូវការអប់រំ សិទ្ធិមនុស្ស «កែលម្អលើមធ្យោបាយក្នុងការការពារ និងលើកស្ទួយសិទ្ធិកម្មករអន្តោប្រវេសន៍» និង «ការបង្កើតគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើការលើកស្ទួយ និងការពារសិទ្ធិស្ត្រី និងកុមារ» ដើម្បីសម្រេចឲ្យបានក្នុងឆ្នាំ២០១០ ។ ក្រុមការងារយន្តការអាស៊ានក្នុងតំបន់ទៅលើសិទ្ធិមនុស្សសម្លឹងឃើញថា គណៈកម្មាធិការមួយនេះផ្តោតចង្អៀត និងដូចជាមានវាទប្បដិវាទតិចតួចទៅលើតែប្រធានបទស្ត្រី និងកុមារ ហើយថាជា «ជំហានដំបូង» ក្នុងការឆ្ពោះទៅរកការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សទូទៅ ។ ផ្ទុយទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រីភេទនៅក្នុងឆ្នាំ២០០៤ មានសមាជិកអាស៊ានតែបួនប្រទេសប៉ុណ្ណោះបានចូលរួមក្នុងអនុសញ្ញាអន្តរជាតិលើសិទ្ធិស៊ីវិល និងនយោបាយ ហើយមានត្រឹមតែប្រទេសបួនបានផ្តល់សច្ចាប័នឬយល់ព្រមទៅលើអនុសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ចសិទ្ធិសង្គមនិងវប្បធម៌ ។

នៅចន្លោះឆ្នាំ២០០៤និង២០០៧ សមាជិកអាស៊ានបានធ្វើការសរុបសេចក្តីថ្លែងការណ៍បីក្នុងតំបន់ទៅលើឆន្ទៈក្នុងការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ការរារាំងនូវការជួញដូរមនុស្សជាពិសេសទៅលើស្ត្រី និងកុមារ និងលើកស្ទួយសិទ្ធិកម្មករអន្តោប្រវេសន៍ ។ សមាជិកទាំងអស់ក៏បានបង្កើតគណៈកម្មាធិការមួយនៅក្នុងការប្រតិបត្តិសេចក្តីថ្លែងការណ៍អាស៊ានទៅលើការការពារនិងលើកស្ទួយសិទ្ធិកម្មករអន្តោប្រវេសន៍ ។ ការព្រមព្រៀងក្នុងការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ទាំងនេះនិងការបង្កើតគណៈកម្មាធិការគឺជាអ្វីដែលអាចធ្វើទៅរួច ពីព្រោះមានទំនាក់ទំនងផ្ទាល់តិចតួចទៅនឹងការបារម្ភជាស្នូលទៅលើការប្រឆាំងនឹងនយោបាយ ។ អ្នកតំណាងគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សរបស់អាស៊ាន ប្រទេសថៃបច្ចុប្បន្ន លោកស្រី ប្រាជា ពិតចមអ៊ីសស្រី បានពន្យល់ថា «សិទ្ធិស្ត្រីនិងកុមារត្រូវបានចាត់ទុកថា ជាបញ្ហាងាយស្រួល និងការគំរាមកំហែងតិចតួចទៅលើសមាជិកអាស៊ានជាជាងសិទ្ធិសេរីភាពខាងស៊ីវិល និងនយោបាយ ។ តាមការពិតបញ្ហាទាំងនេះ គឺអាចបណ្តាលឲ្យមានវាទប្បដិវាទដូចដែលឆ្លុះបញ្ចាំងពីការបម្រុងជាច្រើនរបស់រដ្ឋអាស៊ានដែលបានចូលរួមនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រីភេទ ។ **(នៅមានត)**

**ចន ឆរធីអាវី**

## សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩» ចាប់តាំងពីឆ្នាំ២០០៧មកនិងបានចែកចាយដល់សិស្ស-និស្សិតនិងសាធារណជនទូទាំងប្រទេសជាងមួយនាក់ ។ ជាមួយគ្នានោះដែរ សៀវភៅនេះត្រូវបានបកប្រែជាច្រើនភាសា ហើយអាចរកបានតាមរយៈ

*http://dccam.org/Projects/Genocide/A Hisotry of DK 2007.htm*

# សេចក្ដីប្រកាសទីក្រុងភ្នំពេញ ស្ដីពីសិទ្ធិមនុស្សអាស៊ាន

ក្នុងអំឡុងកិច្ចប្រជុំអាស៊ានលើទី២១ នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ ថ្នាក់ដឹកនាំប្រទេសដែលជាសមាជិកនៃសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ “អាស៊ាន” បានប្ដេជ្ញាចំពោះការលើកស្ទួយនិងការពារសិទ្ធិមនុស្ស ។ ប្រមុខរដ្ឋនៃប្រទេសអាស៊ានទាំងដប់ “ទទួលស្គាល់ពីសារសំខាន់នៃតួនាទីរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ាន ស្ដីពីសិទ្ធិមនុស្សជាស្ថាប័នដ៏មានឥទ្ធិពល ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្សអាស៊ាន ដែលរួមចំណែកដល់ការកសាងសហគមន៍ប្រជាជាតិអាស៊ាន ហើយក៏ជាយានដើម្បីអភិវឌ្ឍន៍សង្គមជឿនលឿន និងយុត្តិធម៌ និងសម្រេចបាននូវសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ និងកម្រិតជីវភាពខ្ពស់សម្រាប់ប្រជាជាតិអាស៊ាន” ។

ប្រមុខរដ្ឋនៃសមាជិកអាស៊ានទាំងដប់បានយល់ព្រមបីចំណុចខាងក្រោមគឺ ៖

១) ចេញសេចក្ដីប្រកាសស្ដីពីសិទ្ធិមនុស្សអាស៊ាន ។

២) បញ្ជាក់អំពីការប្ដេជ្ញាចំពោះការអនុវត្តយ៉ាងម៉ឺងម៉ាត់នៃសេចក្ដីប្រកាសស្ដីពីសិទ្ធិមនុស្សអាស៊ានដើម្បីធ្វើឲ្យប្រសើរឡើងចំពោះការលើកស្ទួយ និងការការពារសិទ្ធិមនុស្សក្នុងតំបន់ ។

៣) បញ្ជាក់អំពីការប្ដេជ្ញាចំពោះការធានាដែលថាការអនុវត្តសេចក្ដីប្រកាសស្ដីពីសិទ្ធិមនុស្សអាស៊ានត្រូវស្របជាមួយនឹងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស សេចក្ដីប្រកាសទីក្រុងវៀនណា និងផែនការសកម្មភាព និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងៗ ដែលរដ្ឋសមាជិកអាស៊ានទាំងនោះគឺជាភាគីនៃសេចក្ដីប្រកាសអាស៊ាននិងលិខិតុបករណ៍សិទ្ធិមនុស្ស ។




ថ្នាក់ដឹកនាំនៃបណ្ដាប្រទេសដែលជាសមាជិកអាស៊ាន និងដៃគូអាស៊ានទាំងអស់ ។ រូបថត ៖ រស្មីកម្ពុជា

# ពិភពមួយដែលគ្មានសង្គ្រាម

សេចក្តីថ្លែងការណ៍ជាសាកលឆ្នាំ១៩៤៨ ស្តីពីសិទ្ធិមនុស្ស បានទទួលស្គាល់សិទ្ធិជាច្រើន រួមមានសិទ្ធិទទួលបានការអប់រំ ការគាំពារសុខុមាលភាព និងការរស់នៅសមរម្យ ។ កន្លះសតវត្សរ៍ក្រោយមក ប្រជាជនពិភពលោកភាគច្រើននៅតែរងភាពក្រីក្រ ។ ខ្ញុំសុបិនឃើញពិភពលោកមួយដែលគ្មានសង្គ្រាមដែលជាពិភពលោកមួយដែលផ្ទុយពីប្រទេសកម្ពុជាជាទីដែលខ្ញុំចាប់កំណើត ។ វាជាពិភពលោកមួយដែលវដ្តនៃភាពគ្មានអំពើហិង្សាគ្របដណ្តប់លើវដ្តនៃភាពមានអំពើហិង្សាដែលមនុស្សគ្រប់គ្នាមិនដែលឮជម្លោះប្រដាប់អាវុធ ហើយជាទីដែលមនុស្សគ្រប់គ្នាអាចបំពេញសក្តានុពលរបស់ខ្លួន និងជាពិភពលោកមួយដែលយើងគ្រប់គ្នាមានមោទកភាពចំពោះ ។ ខ្ញុំជឿថាវាជាទីដែលមានឆន្ទៈ និងមាគ៌ាមួយដែលក្នុងន័យសន្តិភាព និងសង្គ្រាម គឺជាជម្រើសរបស់យើង ។ ការសិក្សាពីសន្តិភាព គឺសំខាន់មិនត្រឹមតែការសិក្សានេះទាញផ្នែកសិក្សាជាច្រើន ថែមទាំងវាប្រមើលមើលសន្តិភាពមួយដែលអាចសម្រេចបាន ។ ដើម្បីនិយាយយោងទៅលើប្រធានបទ ខ្ញុំចាប់ផ្តើមធ្វើការពិភាក្សាពីអត្ថន័យនៃពាក្យ "ពិភពលោកដែលគ្មានសង្គ្រាម" ដោយផ្អែកលើនិយមន័យនៃពាក្យសន្តិភាព និងហិង្សារបស់លោក ចូហាន ហ្គាល់តាំង អ្នកស្រាវជ្រាវសន្តិភាពជាតិន័រវេជ៍ល្បីល្បាញម្នាក់ ។

បន្ទាប់មក ខ្ញុំធ្វើការប្រៀបធៀបរវាងពាក្យ "ពិភពលោកដែលគ្មានសង្គ្រាម" និងដែនដីសេចក្តីសុខក្សេមក្សាន្តដើម្បីគូសបញ្ជាក់ថា ពិភពលោកដែលគ្មានសង្គ្រាម គឺអាចសម្រេចបាន ។ ខ្ញុំបានស្រមើស្រមៃពិភពលោកមួយដ៏សមស្របដែលគ្មានសង្គ្រាម និងពិពណ៌នាថាតើវាអាចកើតឡើងយ៉ាងដូចម្តេច ។ ទស្សនវិស័យនេះកើតចេញពីប្រវត្តិផ្ទាល់របស់ខ្ញុំជាជនរងគ្រោះដោយសារសង្គ្រាម ហើយជាចុងក្រោយ ខ្ញុំស្នើជាដំណោះស្រាយដែលអាចនាំយកនូវពិភពលោកមួយដែលគ្មានសង្គ្រាម ។

## ២) ពិភពលោកដែលគ្មានសង្គ្រាម

### ក) ការកំណត់និយមន័យពិភពលោកដែលគ្មានសង្គ្រាម

ពាក្យ "ពិភពលោកដែលគ្មានសង្គ្រាម" មានន័យពីរយ៉ាង ។ ដូចជាពាក្យគ្មានសង្គ្រាម មានន័យថា សន្តិភាព ។ យោងតាមលោក ចូហាន ហ្គាល់តាំង ពាក្យសន្តិភាពមានន័យវិជ្ជមានផង និងអវិជ្ជមានផង ។ សន្តិភាពអវិជ្ជមានគឺជាការអវត្តមាននៃអំពើហិង្សា និងសង្គ្រាមដោយផ្ទាល់រួមមាន ពិភពលោកពេលបច្ចុប្បន្នដែលមនុស្សភាគច្រើននៅភាគខាងត្បូងរស់នៅក្នុងភាពក្រីក្រ និងពិភពលោកមួយដែលស្ថិតក្រោមការគាបសង្កត់ផ្តាច់ការដូចជាការគាបសង្កត់របស់ពួកណាហ្ស៊ី ។

ផ្ទុយទៅវិញ សន្តិភាពវិជ្ជមាន និយាយសំដៅទៅលើរចនាសម្ព័ន្ធសង្គម និងវប្បធម៌ដែលមិនបណ្តាលឲ្យមានអំពើហិង្សា ។ សន្តិភាពវិជ្ជមានគួរតែគ្របដណ្តប់លើសន្តិភាពអវិជ្ជមានពីព្រោះដំបូងអំពើហិង្សាត្រូវតែបញ្ឈប់មុនពេលដែលការរស់នៅសុខសាន្តមួយបានកើតឡើង ដូច្នេះហើយ ពិភពលោកដែលគ្មានសង្គ្រាមត្រូវតែជាពិភពលោកមួយដែលស្ថិតក្នុងសន្តិភាពវិជ្ជមានដែលមិនមានអំពើហិង្សា ជាទម្រង់ផ្ទាល់ ជារចនាសម្ព័ន្ធ និងជាទម្រង់វប្បធម៌ ។ លោក បារាស និងលោក វេបេល បានលើកឡើងថា ការប្រឆាំងទៅនឹងសង្គ្រាមតែមួយគឺមិនគ្រប់គ្រាន់ទេ ។ យើងត្រូវការអ្វីច្រើនជាងនេះ ។ វាជាសន្តិភាពវិជ្ជមាននិងសន្តិភាពតាមការអះអាង ។

អ្នកសន្តិនិយមជាច្រើនបានគាំទ្រទស្សនៈរបស់ខ្ញុំដែលយល់ឃើញថា ពិភពលោកមួយដែលគ្មានសង្គ្រាម មិនមែនគ្រាន់តែគ្មានសង្គ្រាមនោះទេ ប៉ុន្តែជាពិភពលោកមួយដែលមានរចនាសម្ព័ន្ធមួយដែលធ្វើនិរន្តរភាពសន្តិភាព ។ បើតាមសៀវភៅ "Engaging the Powers" លោក វល់ធ័រ វិង បានពន្យល់ទស្សនៈរបស់គាត់ស្តីពីពិភពលោកមួយដែលមានសន្តិភាព និងគ្មានអំពើហិង្សាក្នុងទម្រង់ជាសហគមន៍កុលសម្ព័ន្ធដែលហៅថា បាទិក ណេហ្ក្រិតូ ដែលរស់នៅក្នុងព្រៃនៃឧបទ្វីបម៉ាឡេ ។ លោក វល់ធ័រ វិង បានពន្យល់ថា កុលសម្ព័ន្ធបាទិក គឺជាសង្គមសមភាពនិយមមួយលើគ្រប់ទិដ្ឋភាពទាំងអស់ ។ មនុស្សគ្រប់រូបស្មើភាពគ្នា ហើយមនុស្សប្រុសមិនត្រួតត្រាលើមនុស្សស្រី ។ មិនមានការទាមទារកិត្តិនាម និងឋានៈទេ ។ ប៉ុន្តែ

សង្គមនោះ គឺមានសន្តិភាពហើយមានចំណងយ៉ាងជិតស្និទ្ធក្នុងចំណោមសមាជិករបស់ខ្លួន ។ លោក វល់ធ័រ វិង ជឿថា “មនុស្សអាចរស់នៅដោយគ្មានសង្គ្រាម ហើយថា ពិភពលោកមួយដែលគ្មានសង្គ្រាម គឺមិនមែនល្អឥតខ្ចោះ ឬជាអ្វីមួយដែលមិនអាចសម្រេចបាននោះទេ ។ លោក តូនី អូហ្គ្រេក ពិពណ៌នាពីពិភពលោកវិជ្ជមានមួយដែលគ្មានសង្គ្រាមថា ជាប្រជាជនដែលមិនស្គាល់អ្វីថាជាសង្គ្រាម ហើយមិនយល់ហេតុអ្វីបានជាមានសារសំខាន់ក្នុងការប្រើអាវុធ ។ បញ្ហាជាច្រើនស្រដៀងគ្នាទៅនឹងបញ្ហាសង្គ្រាមដែលទាមទារការខំប្រឹងប្រែងដើម្បីដោះស្រាយគឺបញ្ហាបរិស្ថាន និងគ្រោះធម្មជាតិ ខណៈដែលការសម្លាប់ និងការបង្កបួសស្នាមដាក់គ្នាទៅវិញទៅមកមិនត្រូវបានគេមើលឃើញ ។ លោក ចន លេនិន ដែលជាអ្នកចម្រៀងដ៏ល្បីបានបង្ហាញពិភពលោកមួយក្នុងសន្តិភាពដោយមានចម្រៀងមានចំណងជើងថា *Imagine* របស់គាត់ដែលថា មិនមានរឿងអ្វីមួយដែលត្រូវសម្លាប់ ឬត្រូវស្លាប់ចំពោះនោះទេ ហើយមនុស្សរស់នៅដោយសន្តិភាព ។ ពេលដែលមនុស្សគ្រប់រូបស្រឡាញ់សន្តិភាព ពិភពលោកនឹងក្លាយជារបស់តែមួយ ។

ជាងនេះទៅទៀត ពិភពលោកមួយដែលគ្មានសង្គ្រាមគឺខុសពីទស្សនៈនៃដែនដីសុខក្សេមក្សាន្ត យោងតាមវចនានុក្រម *Cambridge Advanced Learner* ដែនដីសុខក្សេមក្សាន្ត (*Utopia*) គឺជាសង្គមមួយដែលល្អឥតខ្ចោះដែលមនុស្សគ្រប់គ្នាធ្វើការយ៉ាងប្រសើរជាមួយអ្នកដទៃ ហើយមានភាពរីករាយ ។ យោងតាម *Oxford Encyclopedic English Dictionary* ដែនដីសុខក្សេមក្សាន្ត (*Utopia*) កើតចេញពីពាក្យ (*Ou min*) និង *topos* (កន្លែង) ដូច្នេះហើយដែនដីសុខក្សេមក្សាន្តមានន័យថា ជាកន្លែងល្អឥតខ្ចោះតាមការស្រមើស្រមៃ ។ ដែនដីសុខក្សេមក្សាន្ត គឺជាចំណងជើងរឿងប្រលោមលោក *Utopia* របស់លោក ថូម៉ាស ម័រ (*Thomas More*) ក្នុងឆ្នាំ១៩៥៦ ដែលពិពណ៌នាអំពីកោះមួយដែលនៅដាច់ពីគេ ដែលមានសង្គមល្អឥតខ្ចោះ ។ ពាក្យ *Utopia* ដែលផ្តល់និយមន័យដោយវចនានុក្រមផ្សេងៗបង្ហាញចំណុចរួមជាច្រើនដូចជាពិភពលោកមួយដែលល្អឥតខ្ចោះតាមការស្រមើស្រមៃគ្រប់ទិដ្ឋភាពទាំងអស់ ។

ទិដ្ឋភាពផ្សេងៗជាច្រើននៃដែនដីសុខក្សេមក្សាន្តដែលត្រូវអនុវត្ត ។ អ្នកនយោបាយដែលមានទស្សនៈស្តីពីដែនដីសុខក្សេមក្សាន្តបានបង្កមហន្តរាយដែលមិនអាចនឹកស្មានដល់សង្គម ដោយសារទស្សនៈរបស់អ្នកទាំងនោះគឺពិបាកអនុវត្ត ។ លោកសាស្ត្រាចារ្យ អេនធ្រូ រីកបាយ និយាយថា មិនមានអ្វីមួយគ្រោះថ្នាក់ជាងអ្នកដែនដីសុខក្សេមក្សាន្តដែលមានអំណាចអនុវត្តផែនការរបស់ខ្លួន ដូចក្នុងប្រទេសអាល្លឺម៉ង់អំឡុងការគ្រប់គ្រងរបស់ណាហ្ស៊ី ឬក្នុងប្រទេសចិន អំឡុងពេលបដិវត្តន៍វប្បធម៌ ឬក្នុងប្រទេសកម្ពុជាអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ១៩៧៥-៧៩ ។

សរុបសេចក្តីមក តាមនិយមន័យរបស់ខ្ញុំនៃពាក្យពិភពលោកមួយដែលគ្មានសង្គ្រាមខាងលើ ដែនដីសុខក្សេមក្សាន្ត (Utopia) និងពិភពលោកមួយដែលគ្មានសង្គ្រាម (*A world-without-war*) គឺជាទស្សនៈពីរខុសប្លែកពីគ្នា ។ ដែនដីសុខក្សេមក្សាន្ត (*Utopia*) គឺជាសុបិនហើយមិនប្រាកដនិយម រីឯពិភពលោកដែលគ្មានសង្គ្រាម (*world-without-war*) គឺជាពិភពលោកមួយស្ថិតក្នុងសន្តិភាពដែលអាចសម្រេចបាននិងប្រាកដនិយម ហើយវាជាអ្វីមួយដែលយើងចាំបាច់ត្រូវមាននាពេលបច្ចុប្បន្ន ទោះបីជាមានការបំផ្លិចបំផ្លាញដោយសព្វាវុធរបស់យើងក៏ដោយ ។ ប្រសិនបើមានដែនដីសុខក្សេមក្សាន្តពិភពលោកមួយដែលគ្មានសង្គ្រាមត្រូវតែកើតឡើងជាដំបូង ។

## ១) ការស្រមើស្រមៃពិភពលោកមួយដែលគ្មានសង្គ្រាម

កាលខ្ញុំនៅក្មេង ខ្ញុំបានមើលឃើញទាហាន និងអ្នកភូមិដែលរងរបួសត្រូវបានសែងតាមប្រង់ការ ដោយដោតជាប់ដោយឈាម កាត់ភូមិខ្ញុំឆ្ពោះទៅមន្ទីរពេទ្យដ៏កខ្វក់មានតែមួយ និងមានមនុស្សកុះករនៅឯទីប្រជុំជន ។ សម្លេងផ្ទុះបានឮស្ទើររៀងរាល់ថ្ងៃ ។ ប្រជាជនដែលប្រថុយទៅស្រែត្រូវរងពិការដាច់ដៃជើង និងស្លាប់ ដោយសារមីន និងអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះដែលបន្សល់ពីការទម្លាក់គ្រាប់បែករបស់អាមេរិក និងសង្គ្រាមលើកមុន ។ ប្រជាជនទាំងអស់សុទ្ធតែខ្វះខាតអាហារហូបចុក ។ ក្មេងៗរៀននៅក្រោមដើមឈើធំៗ ខណៈដែលទាហានខ្មែរក្រហមនៅបរិវេណសាលាបានបាញ់ផ្លោងជាច្រើន ។ គ្មានយប់ណាមួយដែលមិនមានសម្លេងផ្ទុះទេ ហើយភាពភ័យខ្លាច មិនដែលស្រាកស្រាន្តឡើយ ។ ចំពេលដែលមានសង្គ្រាមរ៉ាំរ៉ៃ មនុស្សបាននិយាយពី “សុខសាន្តត្រាណ” ហើយបានចង់ចាំ

ពេលវេលារីករាយ រុងរឿង និងសុខសាន្ត អំឡុងពេលសង្គមរាស្ត្រនិយមក្នុងទសវត្សរ៍៥០ និង៦០ ។ ពាក្យ “សុខសាន្តត្រាណ” សំខាន់ណាស់ សម្រាប់យើងគ្រប់គ្នា ខណៈដែលប្រទេសកម្ពុជាកាលសម័យនោះ កំពុងស្ថិតក្នុងសង្គ្រាមអស់ជាងមួយទសវត្សរ៍ ។ ពាក្យនេះបានផ្តល់ក្តីសង្ឃឹមដល់យើងដែលស្ថិតនៅក្នុងស្ថានភាពមួយដែលមើលទៅមិនមានការបញ្ចប់សង្គ្រាម ។

រឿងទាំងអស់ចាប់ផ្តើមឡើងពេលដែលសង្គ្រាមវៀតណាមផ្ទុះឡើង ។ ដំបូង សម្តេច សីហនុ បានអនុម័តគោលនយោបាយអព្យាក្រឹត ដើម្បីបញ្ចៀសសង្គ្រាមរវាងប្រទេសមហាអំណាច ។ ពេលដែលសង្គ្រាមនៅតែបន្ត ប្រទេសកម្ពុជារងនូវអស្ថេរភាពសេដ្ឋកិច្ចនិងនយោបាយ ។ អង្ករដែលជាប្រភពចំណូលដ៏សំខាន់ត្រូវបានរត់ពន្ធដើម្បីចិញ្ចឹមប្រជាជនតស៊ូនៅប្រទេសជិតខាង ។ ជនភៀសសឹក ជាពិសេសខ្មែរក្រោម សម្រុកចូលពីវៀតណាមខាងត្បូង ។ នៅចុងទសវត្សរ៍៦០ ទាហានវៀតណាមខាងជើងចាប់ផ្តើមបង្កើតជំរុំនៅភាគឦសានប្រទេសកម្ពុជា ហើយគាំទ្រ និងបណ្តុះបណ្តាលក្រុមកុម្មុយនីស្តប្រឆាំង សម្តេច សីហនុ ដែលបានបាក់ស្បាតបន្ទាប់ពីការបង្ក្រាបដ៏សាហាវ ។ ស្របពេលជាមួយគ្នានេះ សហរដ្ឋអាមេរិក និងវៀតណាមខាងត្បូងចាប់ផ្តើមតាមប្រមាញ់ទាហានវៀតណាមខាងជើងក្នុងដីកម្ពុជា ។ កាលនោះ សីហនុ គាំទ្រភាគីទាំងពីរវៀតណាម និងអាមេរិកតាមរយៈការជួយភាគីនីមួយៗ ។ លន់ នល់ ដែលជានាយករដ្ឋមន្ត្រីរបស់ សម្តេច សីហនុ និងជាអ្នកប្រឆាំងក្រុមកុម្មុយនីស្តដាច់ខាតដែលគាំទ្រដោយសហរដ្ឋអាមេរិក បានទម្លាក់សម្តេច សីហនុ ដោយរដ្ឋប្រហារក្នុងឆ្នាំ ១៩៧០ ។

ខណៈដែល សម្តេច សីហនុ ចូលរួមជាមួយកម្លាំងកុម្មុយនីស្តដើម្បីក្តាប់អំណាចសាជាថ្មី ដែលគាំទ្រដោយវៀតណាមខាងជើង ហើយ លន់ នល់ គាំទ្រដោយសហរដ្ឋអាមេរិក ប្រទេសកម្ពុជា បានធ្លាក់ចូលសង្គ្រាមវៀតណាមក្នុងឆ្នាំ១៩៧០ ។ សង្គ្រាមបង្ហូរឈាមនៅបន្តរយៈពេលប្រាំឆ្នាំ ហើយបញ្ចប់ពេលដែលខ្មែរក្រហមត្រួតត្រាភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ។ វៀតណាមខាងជើងបានបញ្ចប់សង្គ្រាមនៅទីក្រុងសៃហ្គននៅខែដូចគ្នានោះដែរ ។ សម្រាប់វៀតណាមនោះគឺជាការបញ្ចប់សង្គ្រាម ដូច្នេះហើយប្រទេសវៀតណាមបានចាប់ផ្តើមស្តារឡើងវិញ ។ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជាវិញ រឿងអាក្រក់បំផុតមិនទាន់កើតឡើងនៅឡើយទេ ។ ក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ប្រជាជនកម្ពុជាពីរលាននាក់ ឬ៣០ភាគរយនៃប្រជាជនសរុបបានស្លាប់ដោយសារការសម្លាប់ភ្លាមៗ ពលកម្មបង្ខំ ជំងឺ និងការបង្អត់អាហារ ។ ប៉ុន្តែវាមិនមែនជាទីបញ្ចប់នោះទេ ។ ខណៈដែលវៀតណាមលុកលុយនិងរំដោះប្រទេសចេញពីប្រល័យពូជសាសន៍ចុងឆ្នាំ១៩៧៩ ខ្មែរក្រហមដែលត្រូវបានលោកខាងលិចគាំទ្រថាជារដ្ឋាភិបាលនិរទេសហើយមានអាសនៈនៅអង្គការសហប្រជាជាតិរហូតដល់ឆ្នាំ ១៩៨៩ ។ ដោយមានការគាំទ្រពីលោកខាងលិច ខ្មែរក្រហមអាចស្តារការបរាជ័យ ហើយអាចប្រយុទ្ធបានដប់ឆ្នាំទៀត ។ សង្គ្រាមនៅកម្ពុជាគឺជាចំណុចដ៏ក្តៅរបស់សង្គ្រាមត្រជាក់នៅបរទេស ។ ប្រទេសមហាអំណាចបាននាំសង្គ្រាមមកកម្ពុជាហើយបានជាប់ពាក់ព័ន្ធយ៉ាងខ្លាំងអំឡុងសង្គ្រាមស៊ីវិលទសវត្សរ៍៨០ ។ ដោយសារតែសង្គ្រាម ជីវិតរាប់លាននាក់បានបាត់បង់មនុស្សជាច្រើនរងរបួសផ្លូវចិត្ត បែកបាក់គ្រួសារ ការចិញ្ចឹមជីវិតត្រូវបានបំផ្លាញ ហើយប្រទេសរងការបាត់បង់ព្រៃឈើ និងសត្វព្រៃ ដោយជំនួសទៅវិញដោយគ្រាប់មីន និងការបំផ្លាញ ។ អំពើពុករលួយ ការរួចទោស និងអំពើហិង្សា គឺជាការអនុវត្តយ៉ាងសាមញ្ញ ។

ខ្ញុំចង់បានពិភពលោកមួយដែលគ្មានអំពើហិង្សា មនុស្សគ្រប់រូបចិញ្ចឹមជីវិតគ្រប់គ្រាន់មនុស្ស ត្រូវបានផ្តល់សម្លៀកបំពាក់ជម្រក និងចំណីអាហារគ្រប់គ្រាន់ ហើយមិនបារម្ភពីការវាយប្រហារដោយទ័ពព្រៃ ឬកម្លាំងប្រដាប់អាវុធ ហើយអាចដើរហើរលើដីរបស់ខ្លួនដោយមិនភ័យខ្លាចពីមីន ហើយពេលដែលឈឺត្រូវបានព្យាបាលយ៉ាងត្រឹមត្រូវកូនក្មេងទាំងអស់មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំ ។ សិទ្ធិមនុស្សត្រូវបានគេគោរពមនុស្សមិនពុជម្លោះប្រដាប់អាវុធ មនុស្សគ្រប់រូបអាចបំពេញ សក្តានុពលរបស់ខ្លួន ហើយវាជាពិភពលោកមួយដែលយើងមានមោទនភាពចំពោះ ។

## ៣) ដំណោះស្រាយសម្រាប់ពិភពលោកមួយដែលគ្មានសង្គ្រាម

ខ្ញុំស្នើដំណោះស្រាយចំនួនបួនដាច់ដោយឡែកពីគ្នាសម្រាប់ពិភពលោកមួយដែលគ្មានសង្គ្រាម ។ ដំណោះស្រាយពីរដំបូងកើតចេញពីសកម្មភាពរបស់ពិភពលោកដែលសន្តិភាពកើតឡើងដោយមិនរងឥទ្ធិពលនៃអ្នកជាប់ពាក់ព័ន្ធដោយស្រដៀងគ្នាទៅនឹងទ្រឹស្តី

*Invisible Hand* របស់លោក អាដាម ស្មីត ក្នុងសេដ្ឋកិច្ចទីផ្សារសេរី ។ ដំណោះស្រាយទីបី គឺបដិវត្តន៍អហិង្សាដើម្បីបង្កើតរចនាសម្ព័ន្ធសកលមួយ គ្មានហិង្សា ដែលអាចសម្រេចបានតាមរយៈការធ្វើអន្តរាគមន៍ និងកិច្ចខិតខំប្រឹងប្រែងរបស់អ្នកសន្តិនិយមក្នុងរបៀបដែលលោក មហាត្មៈ គន្ធី បានធ្វើចលនារំដោះសេរីភាពអហិង្សាដែលល្បីល្បាញក្នុងប្រទេសឥណ្ឌា ។ ដំណោះស្រាយនេះ គួរតែធ្វើឡើងតាមរយៈការកែប្រែបុគ្គលចំពោះការរស់នៅដោយសន្តិភាព ។ ដំណោះស្រាយចុងក្រោយ ហើយថ្មីសន្ធាងគឺការអប់រំពីការអធ្យាស្រ័យ ។

### ក) សេណារីយ៉ូកម្មេច

ក្នុងសេណារីយ៉ូនេះ សង្គ្រាមដែលកើតឡើងគឺមិនគ្រប់គ្រាន់ធ្វើឲ្យមនុស្សស្រលាញ់សន្តិភាព និងរៀបចំមនុស្សរស់នៅដោយសន្តិភាពទេ ។ យើងប្រទះឃើញការបំផ្លាញមនុស្សស្រដៀងគ្នាកើតឡើងដដែលៗក្នុងប្រវត្តិសាស្ត្រ ។ មានសង្គ្រាមអូសបន្លាយរយៈពេលវែងទូទាំងពិភពលោកមុនសតវត្សរ៍ទី២០ ដែលនាំឲ្យលោកអេម៉ាណូអែល ខាន់ (Immanuel Kant) បោះពុម្ពផ្សាយសៀវភៅ *Perpetual Peace* ក្នុងឆ្នាំ១៧៩៥ សម្រាប់ការកើតឡើងស្របគ្នានូវសន្តិភាពរដ្ឋ ។ នៅក្នុងសតវត្សរ៍ទី២០ សង្គ្រាមកាន់តែកើតឡើងក្នុងទ្រង់ទ្រាយធំ ។ យើងមានសង្គ្រាមលោកលើកទី១ សង្គ្រាមលោកលើកទី២ សង្គ្រាមស៊ីវិល និងសង្គ្រាមក្នុងតំបន់ជាច្រើន ។ ស្របពេលជាមួយនឹងសង្គ្រាមដែលប្រកាសឲ្យដឹងមុន និងមិនប្រកាសឧក្រិដ្ឋកម្មធ្ងន់ធ្ងរថ្មីៗជាច្រើនបានកើតឡើងដូចជា ការប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ការប្រល័យពូជសាសន៍នៅប្រទេសអាមីនៀ បានកើតឡើងក្នុងឆ្នាំ១៩១៧ ប្រឆាំងនឹងជនជាតិអាមីនៀ ដោយក្រុមមួយដែលគេហៅថា យ៉ាំង ធើក (Young Turk) ។ ពិភពលោកបានឆ្លើយតបនឹងអំពើនោះវិញថា "កុំកើតឡើងជាថ្មីម្តងទៀតអី" ។ ប៉ុន្តែអំឡុងពេលសង្គ្រាមលោកលើកទី២ មានសង្គ្រាមប្រឆាំងពួកជ្វីហ្វ (Jewish Holocaust) ដោយពួកណាហ្ស៊ី (Nazi) អំពើរំលោភផ្លូវភេទរបស់ជនផ្តាច់ការជប៉ុននៅទីក្រុងណានជីង (The rape of Nanking by the Japanese) ប្រឆាំងជនជាតិចិន និងការបង្អត់អាហារប្រឆាំងជនជាតិអ៊ុយក្រែន ដោយស្តាលីន ។ ការប្រល័យពូជសាសន៍ទាំងអស់នេះ បានសម្លាប់មនុស្សរាប់មិនអស់ ។ នៅឆ្នាំ១៩៧៥ មានរបបពិឃាតរបស់ខ្មែរក្រហមប្រឆាំងប្រជាជនកម្ពុជា ប៉ុន្តែការប្រល័យពូជសាសន៍នេះនៅតែបន្តដោយគ្មានសញ្ញាស្រាកស្រាន្ត ។ នៅឆ្នាំ១៩៩៤ ការប្រល័យពូជសាសន៍នៅប្រទេសរ្វាន់ដា ដែលប្រព្រឹត្តដោយជនជាតិភាគតិចហ៊ូទូប្រឆាំងនឹងជនជាតិភាគតិចទុតស៊ីបានផ្ទុះឡើងយ៉ាងខ្លាំងរយៈពេលបីខែ ដោយសម្លាប់មនុស្ស៨សែននាក់ ដោយគ្មានការអន្តរាគមន៍ពីសហគមន៍អន្តរជាតិ ។ ចន្លោះឆ្នាំ១៩៩២ ដល់ ១៩៩៥ មានការបោសសម្អាតពូជសាសន៍ (Ethnic Cleansing) នៅបូស្នៀហេហ្សីហ្គូវីណា ហើយបច្ចុប្បន្ន ការប្រល័យពូជសាសន៍កំពុងតែប្រព្រឹត្តនៅដាហ្វ័រ ប្រទេសស៊ូដង់ ។

ប្រវត្តិសាស្ត្រច្រំដែលបង្កើតជាជំនឿមួយដែលថា មានតែសង្គ្រាម និងការរងទុក្ខទេនឹងនាំយកសន្តិភាព ហើយនឹងធ្វើឲ្យមនុស្សស្រលាញ់សន្តិភាព ដូច្នេះហើយ មានសង្គ្រាមធំ ដូចជាសង្គ្រាមនុយក្លេអ៊ែររវាងប្រទេសមហាអំណាចឬប្រទេសដែលគ្រប់គ្រងដោយពួកផ្តាច់ការអាចនឹងកើតឡើងដែលនាពេលអនាគតអាចបណ្តាលឲ្យមានការបំផ្លិចបំផ្លាញនិងការរងទុក្ខធ្ងន់ធ្ងរ ។ មានតែមនុស្សផ្លាស់ប្តូរផ្នត់គំនិត ហើយគិតស៊ីជម្រៅពីអំពើហិង្សាស៊ីជម្រៅ ។ មនុស្សនឹងប្រកាន់យកវប្បធម៌អហិង្សាដោយសារយល់កាន់តែច្បាស់នូវមេរៀនសង្គ្រាម ។ ឧទាហរណ៍ ប្រជាជនរ្វាន់ដា អាហ្វ្រិកខាងត្បូង ជប៉ុន កម្ពុជា និងប្រទេសដទៃ មានទំនោរប្រកាន់យកភាពអហិង្សា និងសន្តិភាព បន្ទាប់ពីខ្លួនជួបប្រទះការបំផ្លាញដោយអំពើហិង្សា និងសង្គ្រាម ។

### ខ) សេណារីយ៉ូផ្លាស់ប្តូរ

នៅក្នុងសេណារីយ៉ូនេះ ផ្ទុយទៅវិញ ពិភពលោកមានអំពើហិង្សា និងការរងទុក្ខរួចទៅហើយ ដូចជា អំពើហិង្សា និងការរងទុក្ខបង្កើតឡើងដោយសង្គ្រាមលោកទាំងពីរ សង្គ្រាមក្នុងតំបន់ សង្គ្រាមស៊ីវិល និងការបោសសម្អាតពូជសាសន៍ និងការប្រល័យពូជសាសន៍ ហើយសង្គ្រាមកាន់តែធ្វើឲ្យវិនាសនិងកាន់តែមិនអាចពន្យល់ហេតុផល ។ ចន្លោះឆ្នាំ១៥០០ និង១៩៨២ ជាមធ្យមមានការប្រកាសសង្គ្រាមមួយដងក្នុងមួយឆ្នាំ ។ ចាប់ពីឆ្នាំ១៩០០ ដល់ឆ្នាំ១៩៦៥ មានការធ្វើបដិវត្តន៍ប្រដាប់អាវុធប្រហែល៣៥០លើក ។ មានសង្គ្រាមច្រើនជាង១០០លើកនៅពាក់កណ្តាលសតវត្សរ៍ទី២០

ដែលភាគច្រើនកើតឡើងនៅភាគខាងត្បូង ។ ការបំផ្លិចបំផ្លាញទាំងនេះ បានបង្កើតនូវរបត់ដែលជំរុញពិភពលោកឆ្ពោះតាមទិសដៅនៃពិភពលោកមួយមានសន្តិភាពនៅទីបញ្ចប់ ។

និន្នាការនេះ បង្ហាញក្នុងរបៀបមួយដែលពិភពលោកវិវត្តទៅមុខ ។ បន្ទាប់ពីសង្គ្រាមលោកលើកទី១ ទស្សនៈនៃពិភពលោកមួយដែលគ្រប់គ្រងអង្គភាពក្នុងទម្រង់នៃប្រទេសសម្ព័ន្ធត្រូវបានបង្កើត ។ នៅឆ្នាំ១៩២៨ សន្និសញ្ញាទូទៅស្តីពីការបោះបង់សង្គ្រាម ដែលស្គាល់ថាជា *the Kellogg-Briand Pact* ត្រូវបានអនុម័តការបោះបង់ចោលការប្រើប្រាស់កម្លាំង ឬការគំរាមកំហែងដោយកម្លាំងដើម្បីដោះស្រាយវិវាទ ។ នៅឆ្នាំ១៩៣០ មាន៦១ប្រទេសបានចុះហត្ថលេខាលើសន្និសញ្ញានេះ ។ អង្គការសហប្រជាជាតិដែលជាក្តីសង្ឃឹមរបស់សន្តិភាពពិភពលោកសព្វថ្ងៃត្រូវបានបង្កើតដោយសារតែសង្គ្រាមលោកលើកទី២ដ៏មហន្តរាយ ។ ក្នុងឆ្នាំ១៩៦១ អ្នកតំណាងមកពីសហរដ្ឋអាមេរិក និងសហភាពសូវៀតបានសម្រេចកិច្ចព្រមព្រៀងស្តីពីគោលការណ៍រៀបចំការចរចា ការរំសាយអាវុធទូទៅ និងទាំងស្រុង ។ ក្នុងឆ្នាំ១៩៧៣ កិច្ចព្រមព្រៀងផ្សេងទៀតរវាងប្រទេសមហាអំណាចបានធ្វើឡើងស្តីពីការបង្ការសង្គ្រាមនុយក្លេអ៊ែរ ។

ទាក់ទិននឹងអធិបតេយ្យភាពនៅឆ្នាំ២០០១ គណៈកម្មាធិការរបស់ប្រទេសកាណាដា ដែលគាំទ្រដោយរដ្ឋាភិបាល និងស្ថាប័នជាច្រើនបានចេញនូវគោលការណ៍ការពារដើម្បីធ្វើអន្តរាគមន៍ខាងផ្លូវមនុស្សធម៌ក្នុងប្រទេសដែលការប្រល័យពូជសាសន៍ និងអំពើហិង្សាធ្ងន់ធ្ងរលើប្រជាជនបានកើតឡើង ។ លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានប្រកាសឲ្យប្រើប្រាស់នៅឆ្នាំ២០០១ ដើម្បីកាត់ទោសជនឧក្រិដ្ឋដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ អង្គការជាតិនិងអន្តរជាតិជាច្រើនត្រូវគេបង្កើតឡើងដោយសារតែបញ្ហាពីអតីត ។ ការរញ្ជួយផែនដីថ្មីៗ ដែលបង្កឡើងដោយរលកយក្សស៊ូណាមិ ដែលបានសម្លាប់មនុស្សច្រើនជាង ១៦០.០០០នាក់ ក្នុងប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍បានទទួលការគាំទ្រពីអន្តរជាតិដែលមិនធ្លាប់មានពីមុនពីផ្នែកឯកជន និងរដ្ឋាភិបាលជុំវិញពិភពលោកដោយមានអង្គការសហប្រជាជាតិជាអ្នកសម្របសម្រួលដ៏សំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ។ នេះបានបង្ហាញថា មនុស្សចាប់ផ្តើមគិតថា យើងទាំងអស់គ្នារស់នៅក្នុងពិភពមួយ ហើយយើងចាំបាច់ជួយគ្នាទៅវិញទៅមកក្នុងគ្រាមានវិបត្តិ ។

ការវិវត្តខាងផ្លូវមនុស្សធម៌តាមទិសដៅពិភពលោក គឺកើតឡើងដោយសារបញ្ហាពីអតីត ។ អវត្តមានសង្គ្រាម និងកើតឡើងទាំងស្រុងដោយសារតែបុគ្គលជាប់ពាក់ព័ន្ធ ។ ដំបូងសង្គ្រាមលោកនឹងមិនកើតឡើងទេរវាងប្រទេសមហាអំណាច បន្ទាប់មកមិនមានសង្គ្រាមក្នុងតំបន់រវាងប្រទេសមហាអំណាចតូចតាច ហើយក្រោយមក មិនមានសង្គ្រាមផ្ទៃក្នុងប្រទេស និងទីបញ្ចប់មិនមានសង្គ្រាមពូជសាសន៍រវាងសហគមន៍ ។ ម៉្យាងវិញទៀត ពិភពលោកនាពេលបច្ចុប្បន្នកំពុងរំកិលទៅរកសហគមន៍មួយដែលស្រលាញ់សន្តិភាព ។

### ក) បដិវត្តន៍អហិង្សា

ទស្សនៈនៃបដិវត្តន៍អហិង្សាបានលេចឡើងក្នុងឆ្នាំ១៩៦៨ ក្នុងទស្សនាវដ្តី *Peace News* ដែលប្រឆាំងនឹងសង្គ្រាម និងការរៀបចំសង្គ្រាម ហើយទស្សនៈនេះមានបំណងកសាងចលនាអហិង្សាសម្រាប់សង្គមថ្មីមួយដែលផ្អែកទៅលើអនាធិបតេយ្យនិយម និងសន្តិនិយម ។

នៅក្នុងពិភពលោកដែលមានអំពើហិង្សាដែលក្នុងនោះអំពើហិង្សាបានចាក់ឫសក្នុងផ្នត់គំនិតសង្គម គឺមានតែអំពើហិង្សាទេដែលដំណើរការបាន ។ នៅពេលតែអំពើហិង្សាកើតឡើងសកម្មភាពនោះគឺជាការប្រព្រឹត្តអំពើហិង្សា ។ យើងមិនអាចដកហូតអាវុធពីជនហិង្សា ដូចជា ហ៊ីត្លែរ និង សាដាម ហ៊ូសេន ដែលជាអ្នកបង្កើតហិង្សា ។ សុភាសិតចិនចែងថា “វិធីសាស្ត្រតែមួយដើម្បីកាត់ពេជ្រ គឺយកពេជ្រកាត់ពេជ្រ” ទោះបីជាយ៉ាងនេះ វាបានបង្ហាញថា អំពើហិង្សាមិនមែនជាសារជាតិរបស់មនុស្សទេ ដូចក្នុងករណីសហគមន៍កុលសម្ព័ន្ធ បាទិកណេហ្គេតូ ហើយថាយើងអាចរស់នៅដោយគ្មានអំពើហិង្សាបាន ។ យើងគ្មានផ្លូវបំបាត់សង្គ្រាម និងជម្លោះប្រដាប់អាវុធទេ លុះត្រាតែយើងខិតខំបំបាត់អំពើហិង្សា ។ ដូចគ្នានេះដែរ ដោយសារជនបដិវត្តន៍មិនរំដោះ មិនធ្វើការកែទម្រង់ និងមិនអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន វាមានសារសំខាន់ដែលមានប្រព័ន្ធអហិង្សាដែលយើងចាំបាច់ត្រូវធ្វើបដិវត្តន៍អហិង្សា ។ ហិង្សា និងអហិង្សា គឺជាទស្សនៈពីរដែលមិនស្របគ្នាដែលកើតឡើងដោយមិនជាប់ទាក់ទងគ្នា ហើយទស្សនៈទាំងពីរមិនអាចធ្វើការប្រៀបធៀបបានទេ ។ ភាព

អហិង្សានិងដំណើរការយ៉ាងរលូននៅពេលដែលរចនាសម្ព័ន្ធពិភពលោកមួយត្រូវបានបង្កើតឡើងសម្រាប់រឿងនេះ ។ លោក រ៉ូបឺត ហូម៉េស បានយល់ស្របថា យើងមិនអាចប្រៀបធៀបអំពើអហិង្សាទៅនឹងអំពើហិង្សាដែលបានកើតឡើងក្នុងប្រព័ន្ធសង្គម និងសេដ្ឋកិច្ចរបស់ពិភពលោកនោះទេ ។ លោក វិង បានបន្ថែមថា ការប្រៀបធៀបអំពើហិង្សា និងអំពើអហិង្សាគឺមិនត្រឹមត្រូវទេ ពីព្រោះជនគាំទ្រអំពើអហិង្សាមិនទទួលបានការគាំទ្រពីទាហានរាប់លាននាក់ដែលបណ្តុះបណ្តាលពីភាពអហិង្សា ។

## តើបដិវត្តន៍គួរតែត្រូវធ្វើឡើងដោយរបៀបណា?

លោក អេជេ ម៉ូស្ទេ ដែលជាអ្នកសន្តិនិយមបានសរសេរថា “គ្មានផ្លូវរកសន្តិភាពទេ ប៉ុន្តែសន្តិភាពគឺជាមធ្យោបាយ” ។ សណ្តាប់ធ្នាប់សង្គមអហិង្សា គឺកើតឡើងដោយសារការអនុវត្ត និងសកម្មភាពរបស់យើងប្រចាំថ្ងៃ ។ លោក មហាត្មៈ គន្ធី និងលោក ម៉ាទីន លីហ្វេធើ ឃីង ជឿថា ជាកម្លាំងដ៏ខ្លាំងមួយ “ដែលយើងទាំងអស់គ្នាអាចចាប់ផ្តើមធ្វើការកែប្រែរបៀបរស់នៅដោយធ្វើការមួយជំហានម្តងឆ្ពោះទៅរកការរស់នៅអហិង្សា” ។ អហិង្សានៅត្រូវការការគាំទ្រពីប្រជាជននីមួយៗលើពិភពលោកដូចជាស្ថាប័នដែលផ្តោតលើអំពើហិង្សាដែលកំពុងត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុ និងប្រាជ្ញាស្មារតី ។ លោក ឌិក ស៊ីបភត ស្ថាបនិក *Peace Pledge Union* បានព្យាយាមការពារសង្គ្រាមលោកលើកទី២ដោយជំរុញឲ្យមានការគាំទ្រពីមនុស្សដែលស្អប់សង្គ្រាម ។ គាត់បាននិយាយមុនសង្គ្រាមថា “ប្រសិនបើយើងទទួលបានអ្នកបោះឆ្នោតមួយលាននាក់ដែលទទូចថា អ្នកទាំងនោះនឹងមិនចូលរួមសង្គ្រាម រដ្ឋាភិបាលគួរតែត្រូវកត់សម្គាល់” ។ ទោះបីជាយ៉ាងនេះក៏ដោយ មិនមានមនុស្សគ្រប់គ្រាន់គាំទ្រគាត់ទេ ដូច្នេះហើយឥទ្ធិពលនោះមានកំណត់ ។ ការបរាជ័យរបស់គាត់មួយផ្នែកកើតឡើងដោយសារតែអ្នកសន្តិនិយមមិនមានជម្រើសផ្សេងចំពោះសង្គ្រាម និងមិនមានគោលដៅជាក់ច្បាស់ដែលបានឆ្លុះបញ្ចាំងក្នុងអត្ថបទមួយក្នុងទស្សនាវដ្តី *Peace News* ដែលក្នុងនោះអ្នកធ្វើយុទ្ធនាការផ្សេងបានបញ្ចេញទស្សនៈផ្សេងគ្នា ។ វាកើតឡើងដោយសារសាធារណជនលើកឡើងនូវសំណួរស្មានដោយទាមទារឲ្យមានការចាត់វិធានការអហិង្សាពេលដែលអំពើហិង្សាកើតឡើង ។ ទស្សនៈនេះមិនទទួលបានសេចក្តីទុកចិត្តនៃទស្សនៈខ្វែងគ្នារបស់អ្នកធ្វើយុទ្ធនាការ ។ គោលការណ៍ការពារជនស៊ីវិលរបស់លោក ជេន សាប មិនមែនជាចម្លើយចំពោះស្ថានភាពបែបហ្នឹងទេ ។ លោក ជេន សាប ស្នើដំណោះស្រាយការពារជនស៊ីវិលដោយអហិង្សាថាជាជម្រើសសម្រាប់ការការពារប្រដាប់អាវុធ ។ ក្នុងទ្រឹស្តីនេះ ប្រទេសនីមួយៗអាចការពារខ្លួនដោយមិនចាំបាច់ត្រូវការអាវុធ ។ ការងារនេះអាចធ្វើទៅរួចតាមរយៈការទាញការគាំទ្រជនវាយប្រហារ តាមរយៈការបន្សាក់ ឬបន្ទិតបន្ទំសត្រូវដោយបដិសេធការសហការដែលត្រូវការ ។ គោលការណ៍ការពារជនស៊ីវិល ទាមទារឲ្យបុគ្គលនីមួយៗក្នុងសង្គមជាបុគ្គលអហិង្សា ។ រឿងនេះមិនអាចធ្វើទៅរួចទេពេលបច្ចុប្បន្ន ពេលដែលផលប្រយោជន៍រដ្ឋត្រូវគាំពារដោយអំណាចយោធា ។ ក្នុងករណីមានការវាយប្រហារដោយនុយក្លេអ៊ែរ ជនស៊ីវិលមិនមានពេលវេលាដើម្បីបង្ហាញចំណាត់ការអហិង្សារបស់ខ្លួនទេ ដូច្នេះហើយឥរិយាបថអហិង្សា ត្រូវតែបង្ហាញមុនភាពតានតឹង និងមុនសង្គ្រាមកើតឡើង ។ ការរស់នៅដោយអហិង្សាគឺជាគន្លឹះ ។ គោលការណ៍ការពារជនស៊ីវិលអាចត្រូវបានប្រើនៅពេលដែលពិភពលោកកាន់តែមានអំពើហិង្សាតិចទៅៗ ដោយឆ្ពោះទៅរកភាពអហិង្សាទាំងស្រុង ។

បដិវត្តន៍អហិង្សាចាំបាច់ត្រូវធ្វើឡើងក្នុងរយៈពេលវែង ហើយត្រូវការជំនួយពីមនុស្សក្នុងសង្គមដែលចង់រស់នៅក្នុងសន្តិភាព ដែលសន្តិភាពគឺអាចសម្រេចបាន ។ ទាំងនេះនឹងបើកផ្លូវសម្រាប់ការវិវត្តនៃបដិវត្តន៍ ។

## ៤) ការអប់រំពីការអធ្យាស្រ័យ

សំណើជាច្រើនបានធ្វើឡើងដើម្បីបំបាត់សង្គ្រាម ប៉ុន្តែគ្មានសំណើណាមួយយកការអធ្យាស្រ័យជាលិខិតុបករណ៍ក្នុងការកែប្រែពិភពលោក ។ សង្គ្រាមកើតឡើងដោយសារការសង្ស័យការខ្វះការយល់ដឹងនិងជំនឿខុសលើសត្រូវ ។ ក្នុងសង្គ្រាមលោកលើកទី២ ដោយសារតែមានការទម្លាក់គ្រាប់បែករបស់អាល្លឺម៉ង់ដំបូងនៅទីក្រុងឡុង ការទម្លាក់គ្រាប់បែកនោះដែលសម្លាប់មនុស្សរាប់មិនអស់ មិនមែនចាប់ផ្តើមឡើងដោយការបំផ្លាញដោយផ្ទាល់លើបញ្ជីសារពើព័ន្ធយោធា ប៉ុន្តែជាការសងសឹក ។ លទ្ធិប្រើអាវុធក្នុងសង្គ្រាមត្រជាក់ដែលផ្អែកលើជំនឿដែលថា ប្រសិនបើភាគីមួយធ្វើសកម្មភាពភាគីដទៃនឹងមិនធ្វើសកម្មភាពតបទេ ប៉ុន្តែភាគីម្ខាងទៀតនឹងធ្វើការ

សង្គ្រាមដើម្បីប្រាកដថាភាគីទាំងពីរត្រូវបានបំផ្លាញស្មើគ្នា ។ បើតាមប្រវត្តិសង្គ្រាមពិភពលោកដែលក្រៅពីការប្រដៅខាងសាសនា ការអធ្យាស្រ័យមិនត្រូវបានសហគមន៍បណ្ឌិតសភាយកមកសិក្សាតាមផ្លូវវិទ្យាសាស្ត្រនោះទេ ។ ចាប់តាំងពីសតវត្សរ៍ទី៥ ដល់ឆ្នាំ ១៩៧០ លោក រ៉ូបឺត អេនរាយ បានរកឃើញសំណេរ១១០ច្បាប់ ស្តីពីការអធ្យាស្រ័យរបស់បុគ្គល ។ គាត់បានបញ្ជាក់ថា យ៉ាងច្រើនមានសំណេរមួយស្តីពីការអធ្យាស្រ័យរៀងរាល់១០ទៅ១៥ឆ្នាំម្តង ។ ការស្រាវជ្រាវពីការអធ្យាស្រ័យបានចាប់ផ្តើមក្នុងទសវត្សរ៍ ៨០ ។ ហេតុផលមួយចំនួនដែលការអធ្យាស្រ័យមិនត្រូវបានយកចិត្តទុកដាក់អស់ពេលយ៉ាងយូរនោះគឺដោយសារតែការអធ្យាស្រ័យទាក់ទិននឹងសាសនា ហើយវិទ្យាសាស្ត្រសង្គមចាត់ទុកការអធ្យាស្រ័យជាបញ្ហាសាសនា ។ ដោយសារតែសតវត្សរ៍ទី២០គឺជាសតវត្សរ៍បង្ហូរឈាម មនុស្សគិតថា ការអធ្យាស្រ័យគឺជាការមិនសមហេតុផល ។

លោក អ៊ីវើរីត វ៉ាស៊ីនតោន បានលើកឡើងថា «ការកើនឡើងភាពតានតឹងពូជសាសន៍ក្នុងសហគមន៍ និងជម្លោះអំពើហិង្សាក្នុងនិងរវាងប្រទេសបានគាំទ្រគំនិតពីរបៀបស្តារការបំផ្លិចបំផ្លាញដែលជានិន្នាការវិជ្ជមានមួយចំពោះការប្រើភាពអធ្យាស្រ័យជាការព្យាបាលសង្គ្រាម ។

ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ការអធ្យាស្រ័យអាចត្រូវបានបង្រៀន និងថាមនុស្សគ្រប់គ្នាអាចរៀនពីការអធ្យាស្រ័យ ។ មិនមានការកំណត់សារសំខាន់ណាមួយនៅឡើយចំពោះការអធ្យាស្រ័យដែលផ្តល់អត្ថប្រយោជន៍ដល់អ្នកដែលធ្វើការអធ្យាស្រ័យ និងសហគមន៍ទាំងមូលដែលប្រកាន់ការអធ្យាស្រ័យជានយោបាយសំខាន់ដើម្បីបញ្ចប់សង្គ្រាម និងដើម្បីផ្សះផ្សាសហគមន៍ ។ ការអធ្យាស្រ័យបង្កើនភាពយោគយល់គ្នា ការអត់ឱននិងការទប់អំពើហិង្សា ។ ការអប់រំពីការអធ្យាស្រ័យក្នុងសាលានឹងធ្វើឲ្យមនុស្សជិនាន់ក្រោយប្រកាន់ឥរិយាបថអហិង្សា និងដោះស្រាយជម្លោះដោយសន្តិវិធីនិងដើម្បីលើកស្ទួយការយល់ដឹង និងការគោរព ។ សង្គ្រាមកាន់តែគ្រោះថ្នាក់ ។ មានការកើនឡើងខ្ពង់ចំណាយលើបញ្ហាមនុស្ស សេដ្ឋកិច្ច បរិស្ថាន ដោយសារសង្គ្រាម និងមានការកើនឡើងចំនួនអ្នកស្លាប់ដូចដែលត្រូវបានប្រទះឃើញក្នុងសង្គ្រាមលោកទាំងពីរក្នុងទសវត្សរ៍ចុងក្រោយដែលមានការបំផ្លិចបំផ្លាញពិភពលោកដែលមិនធ្លាប់មានពីមុន ។ និន្នាការនេះ នឹងបន្តកើតឡើងដោយសារសព្វាវុធក្នុងពិភពលោកនាពេលបច្ចុប្បន្នអាចបណ្តាលឲ្យមានមនុស្សស្លាប់ ។ លោក មិកហៃល ហ្គោបាឆក បានប្រកាសថា ការកើនឡើងនុយក្លេអ៊ែរ ជាពិសេសការសាកល្បងថ្មីៗនៅប្រទេសឥណ្ឌា និងប៉ាគីស្ថាន បានធ្វើឲ្យពិភពលោកកាន់តែអស្ថិរភាព សន្ធិសញ្ញាស្តីពីការមិនបង្កើននុយក្លេអ៊ែរ និងការរំសាយសព្វាវុធលែងមានប្រសិទ្ធភាពទៀតហើយ ។ ជាមួយនឹងតថភាពបែបនេះ មនុស្សគ្រប់រូបត្រូវការបំពាក់អាវុធនុយក្លេអ៊ែរ ដូច្នេះហើយ វាហាក់បីដូចជានៅពេលអនាគតសង្គ្រាមណាក៏ដោយគឺជាការគ្រោះថ្នាក់ ។ ក្នុងករណីនេះ ការអប់រំពីការអធ្យាស្រ័យនឹងជាជម្រើសតែមួយដើម្បីធានាថា សង្គ្រាមនឹងមិនកើតឡើង ហើយពិភពលោកនឹងបន្តទៅមុខ ។ មេសាសនាកាតូលិក លោក ឌីសមិនទូទូ បានកត់សម្គាល់ថា ៈ

«ខ្ញុំសង្ឃឹមថា ថ្ងៃណាមួយ អ្នកនឹងមានឱកាសធ្វើដំណើរទៅហ៊ីរ៉ូស៊ីម៉ា និងមានឱកាសឃើញស្តូបគោរពវិញ្ញាណក្ខន្ធ ។ ពិភពលោកកំពុងស្ថិតក្នុងរណ្តៅគ្រោះថ្នាក់ ប្រសិនបើយើងមិនអធ្យាស្រ័យនិងមិនផ្សះផ្សា ។ ការអធ្យាស្រ័យ គឺមានសារសំខាន់សម្រាប់ការកកើតពូជមនុស្ស ។ គ្មានការអធ្យាស្រ័យ គ្មានពេលអនាគត» ។

## សេចក្តីសន្និដ្ឋាន

ទោះបីជាមនុស្សមួយចំនួនយល់ឃើញថា ពិភពលោកដែលគ្មានសង្គ្រាម ជាការស្រមើស្រមៃ និងជាទីសុខក្សេមក្សាន្ត ។ តាមនិយមន័យ ដែនដីសុខក្សេមក្សាន្ត (Utopia) និងពិភពលោកគ្មានសង្គ្រាម (World-without-war) គឺមានន័យផ្សេងគ្នា ។ ដែនដីសុខក្សេមក្សាន្ត (Utopia) គឺជាពិភពលោកមួយល្អឥតខ្ចោះតាមការស្រមើស្រមៃដែលយើងមិនអាចសម្រេចបានជាមួយវិធីសាស្ត្រដែលយើងមាន ។ នៅពេលដែលដែនដីសុខក្សេមក្សាន្តត្រូវជនបដិវត្តន៍និងជនរ៉ាឌីកាល់គ្រប់គ្រងលទ្ធផលនោះ គឺជាការបំផ្លាញជីវិតមនុស្សរាប់លាននាក់ ។ ពិភពលោកមួយដែលគ្មានសង្គ្រាមគឺជាពិភពលោកមួយស្ថិតក្នុងសន្តិភាពវិជ្ជមានដែលអវត្តមានសង្គ្រាម និងអំពើហិង្សា ។ ពិភពលោកមួយដែលគ្មានសង្គ្រាមគឺជាការប្រាកដនិយម ហើយលក្ខណៈរបស់ពិភពលោកមួយដែលគ្មានសង្គ្រាមត្រូវ

កំណត់ដោយចំណេះដឹងផ្នែកវិទ្យាសាស្ត្រដែលយើងមាន ។ សម្រាប់ប្រទេសកម្ពុជាដែលហែកហួរដោយសង្គ្រាម ពិភពលោកដែលគ្មានសង្គ្រាមគឺសុខសាន្ត និងមានលក្ខណៈសមស្របសម្រាប់មនុស្សគ្រប់គ្នា ដើម្បីយល់ពីសក្តានុពលរបស់ខ្លួន និងភាពរីករាយក្នុងជីវិត ។ ចំពោះអ្នកដែលមិនស្គាល់សង្គ្រាម ការប៉ងប្រាថ្នានេះ គឺជារឿងធម្មតា ប៉ុន្តែការពង្រីកសេចក្តីប៉ងប្រាថ្នា គឺមិនអាចធ្វើទៅរួចក្នុងការកសាងសន្តិភាពពិភពលោក និងពិភពលោកដ៏ប្រសើរសម្រាប់ទាំងអស់គ្នា ។

សេណារីយ៉ូពីរដែលអាចនាំឲ្យមានការបង្កើតពិភពលោកគ្មានសង្គ្រាមដោយមិនចាំបាច់មានការធ្វើអន្តរាគមន៍ពីអ្នកសន្តិនិយម រួមមានសេណារីយ៉ូកម្មេច និងសេណារីយ៉ូផ្លាស់ប្តូរ ។ ក្នុងសេណារីយ៉ូកម្មេចអ្វីដែលភាពទុរគតកើតចេញពីសង្គ្រាម និងអំពើហិង្សាក្នុងប្រវត្តិសាស្ត្រគឺមិនគ្រប់គ្រាន់ធ្វើឲ្យមនុស្សគិតសាជាថ្មីនូវសន្តិភាពនោះទេ ។ បទពិសោធថែមទៀតចាំបាច់ត្រូវការសម្រាប់ការយល់ដឹងពីបញ្ហានេះ ។ ផ្ទុយទៅវិញ ក្នុងសេណារីយ៉ូផ្លាស់ប្តូរពិភពលោកមានការរងទុក្ខរួចទៅហើយ ហើយពិភពលោករំកិលទៅរកសន្តិភាពបន្តិចម្តងៗ ។ ខ្ញុំស្នើដំណោះស្រាយពីរបន្ថែមទៀត ដូចជាបដិវត្តន៍អហិង្សា និងការអប់រំពីការអធ្យាស្រ័យ ពីព្រោះពិភពលោកមានហិង្សា និងមិនមានផ្លូវណាដែលយើងអាចកម្ចាត់បានទេ លុះត្រាតែយើងទាំងអស់គ្នាគាំទ្រការរស់នៅអហិង្សា ។ ការអធ្យាស្រ័យគឺផ្នែកសិក្សាក្នុងមុខវិជ្ជាចិត្តវិទ្យាដែលត្រូវបានគេប្រើសម្រាប់នាំយកសន្តិភាព និងការផ្សះផ្សាក្នុងប្រទេសដែលហែកហួរដោយសង្គ្រាម ។ ការអប់រំពីការអធ្យាស្រ័យធ្វើឲ្យមានការយោគយល់គ្នាកាន់តែខ្លាំង និងការទប់ឥរិយាបថចងគំនុំរវាងបុគ្គល និងក្រុម ។ **អេង កុកថាយ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: truthsocheat@dccam.org*
*Home page: www.dccam.org*



# ស៊ីវ ធួន ៖ ដំណើរឆ្លងកាត់របបខ្មែរក្រហម

**(តចប់)**

**បែកទាំងអាល័យ**

ពេលនោះ ក្រោយពីពួកសេដ្ឋកិច្ចខ្មែរក្រហមរត់ចោលអស់ នៅសល់អង្ករប្រហែលពីរគោ យើងក៏ វាល់អង្ករចែកគ្នាម្នាក់១៥ កំប៉ុង ឬច្រើនជាងនោះតាមប្រវែងផ្លូវឆ្ងាយ ឬជិត ។ យើងក៏លាគ្នាទាំងអាឡោះអាល័យ ធ្វើម្ដេចពេលវេលាបានមកដល់ ហើយតម្រូវឲ្យយើងបែកគ្នាដោយគ្មានការគ្រោងទុកដើម្បីវិលត្រឡប់ទៅជួបគ្រួសារដែលអ្នកខ្លះនៅរហូតដល់បន្ទាយឆ្មារ ។ យើងលើកបង្ហិចខោអាវ និងអង្ករស្ពាយ ហើយលាគ្នារៀងៗខ្លួនទាំងទឹកភ្នែករលីងរលោង ដោយនិយាយឃ្លាចុងក្រោយថា បើសិនជាយើងជួបគ្នាលើកទីពីរ នៅកន្លែងណាក៏ដោយ សូមកុំភ្លេចគ្នាឲ្យសោះ និយាយហើយក៏ធ្វើដំណើរទាំងព្រួយដងអរដង តាមទិសដៅរៀងៗខ្លួន ។ វេលាម៉ោងប្រហែល៩ព្រឹក ខ្ញុំធ្វើដំណើរចេញពីស្ពានធំ មកដល់ភ្នំស្រុក ស្រាប់តែជួបមនុស្សដែលមកពីភូមិព្រះនេត្រព្រះយ៉ាងច្រើន កំពុងស្នាក់នៅកុះករនៅក្នុងភូមិត្រពាំងថ្ម មានទាំងបង្ហិចចាន ឆ្នាំង កំពុងដាំបាយហូប ព្រោះពេលនោះជារដូវចម្រូត អ្នកជម្លៀសដើរកាត់វាលស្រែដែលស្រូវកំពុងទុំក្រាបដល់ដី គេនាំគ្នាបូតឬច្រូតនឹងកណ្ដៀវ ឬក៏បុកស្រូវធ្វើជាអង្ករ ម្នាក់ៗស្ពាយរាប់គោទុកសម្រាប់ធ្វើដំណើរតាមផ្លូវ ។

ពេលនោះ ស្រូវពង្រួស និងស្រូវសន្ទូងដែលនៅឆ្ងាយពីទំនប់បានផលល្អណាស់ ចំណែកស្រែមួយចំនួនដែលនៅជាប់នឹងទំនប់ក៏លិចរលួយមិនបានផល ។ ស្រូវដែលនៅតាមវាល ដូចជា វាលទៀនការំជាដើម បានផលច្រើន ហើយឆ្នាំនេះនៅរដូវច្រូតកាត់ គេលែងឃើញមានឡានយោធាចូលដឹកស្រូវទៀតហើយ ពេលនោះប្រជាជនម្នាក់ៗសប្បាយនឹងហូបបាយ សប្បាយនឹងសេរីភាព សប្បាយបានជួបបងប្អូន សប្បាយនឹងបានទៅស្រុកកំណើត ទន្ទឹម



ស៊ីវ ធួន ក្នុងឆ្នាំ១៩៨៤



ស៊ីវ ធួន ក្នុងឆ្នាំ២០១០

នឹងនេះ អ្នកខ្លះកើតទុក្ខព្រោះបាត់បង់បងប្អូន ឪពុកម្តាយ ឬមនុស្សជាទីស្រឡាញ់ ។

## សប្បាយទាំងមិនដឹងខ្លួន

ពេលខ្ញុំទៅដល់ភូមិត្រពាំងថ្មវេលាម៉ោងប្រហែល១០ព្រឹក ខ្ញុំឮភាសានិយាយគ្នារបស់ប្រជាជនបានប្តូរវាក្យស័ព្ទពីភាសាបដិវត្តន៍មកជាភាសាសាមញ្ញបែបសង្គមចាស់ ពុកម៉ែ មកឪពុកម្តាយ, ពីសមមិត្ត មកជាពាក្យបង ឬប្អូន ហើយអ្នកខ្លះទៀតចេញសម្លេងសើចក្អាកក្អាយ មុខមាត់ស្រស់បស់ ទាញយកសំពត់ ឬសារ៉ុងថ្មីដែលលាក់ជាយូរមកហើយ យកមកស្លៀកបង្កើតបានជាពិធីបុណ្យមួយដែលមានសម្លៀកបំពាក់ចម្រុះពណ៌ ។ រយៈពេលជិតបួនឆ្នាំនៃរបបខ្មែរក្រហម ទោះបីជាពួកគេមានភាពសាហាវឃោរឃៅ កាប់សម្លាប់ប្រជាជនរាប់លាននាក់ក៏ដោយ ក៏គេមិនអាចសម្លាប់មនោសញ្ចេតនាប្រជាជនខ្មែរទាំងស្រុងបានឡើយ ជាពិសេសទៀតគឺផ្នែកវប្បធម៌ និងអ្វីៗដែលជាផ្នត់គំនិតរបស់ខ្មែរនៅក្នុងរបបសង្គមចាស់ ។ ដោយរវល់តែសប្បាយភ្លេចខ្លួន ប្រជាជនអស់ទាំងនោះ ភ្លេចគិតថា ខ្លួនកំពុងត្រូវខ្មែរក្រហមកៀរឲ្យចូលព្រៃកូនខ្វែង ជាព្រៃក្រាស់ដែលមនុស្សកម្រទៅដល់អស់រយៈពេលជាងបីឆ្នាំមកហើយ ។

ប្រជាជនដែលឡើងមកពីតំបន់៥ ផ្នែកខាងក្រោម ចាប់ពីស្រមោច ដូនប្រែង ភូមិស្រែះ រហូតដល់ព្រះនេត្រព្រះ រោលជ្រូកប្រេប និងទៀនកាំ ត្រូវខ្មែរក្រហមកៀរសំដៅភ្នំដងរែក ប៉ុន្តែគេអនុញ្ញាតឲ្យឈប់មួយស្របក់ ដើម្បីទុកពេលឲ្យប្រជាជនដាំបាយហូប ព្រោះគេយល់ពួកគេធ្វើដំណើរកាន់តែឆ្ងាយពីកងទ័ពវៀតណាម ។ នៅពេលម៉ោងប្រហែល១២ថ្ងៃត្រង់ ខ្ញុំក៏លួចខ្សិបប្រាប់អ្នកដែលស្គាល់គ្នាថា សូមកុំទៅលើទៀតពួកវាកៀរឲ្យទៅស្លាប់ គ្មានអ្វីហូបក្រៅពីស្លឹករងៀងនោះទេ សូមបងប្អូនកុំជឿពួកវា ។ នៅពេលនោះកម្មាភិបាល ប៉ុល ពត ជិះសេះយាមប្រជាជន ដោយស្ពាយកាំភ្លើងនៅលើស្មា ព្រោះខ្លាចប្រជាជនបកទៅក្រោយវិញ ។ ពេលដែលកងយោធាខ្មែរក្រហមនាំគ្នាសម្រាកបាយថ្ងៃត្រង់ ជាឱកាសល្អខ្ញុំក៏បានបបួលអ្នកភូមិមួយចំនួនត្រឡប់ទៅកាន់ផ្លូវជាតិលេខ៦វិញ ដើម្បីត្រឡប់ទៅស្រុក ។

## នៅតែភ័យខ្លាច

ខ្ញុំភ័យណាស់ ប៉ុន្តែខ្ញុំមិននិយាយធ្វើឲ្យអ្នកផ្សេងទៀតបាក់ទឹកចិត្ត ចេះតែដើរទៅមុខទាំងព្រលឹងចុងសក់ រត់ចុះតាមផ្លូវកាត់តម្រង់ទៅរកបឹងឲ្យបានឆាប់ ដើម្បីលាក់ខ្លួនក្នុងព្រៃស្មៅដែលដុះយ៉ាងល្អ ទាំងគុម្ពៗមានកម្ពស់លិចក្បាលមនុស្ស ។ ប៉ុន្តែទោះបីខ្ញុំខំដើរយ៉ាងណាពេលងាកទៅក្រោយនៅតែឃើញ ភូមិត្រពាំងថ្មនៅជិតបង្កើយ ព្រោះវាវាលពេក មើលពីណាក៏ឃើញដែរ ។ យើងខំដើរឡើងបែកញើសរហាមព្រោះយល់ថា ទោះបីយើងចេញដំណើរប្រហែលជាងបីគីឡូម៉ែត្រពីភូមិក៏ដោយ ក៏យើងមិនអាចរត់រួចពីជើងសេះបានដែរ ប្រសិនបើពួកវាមើលឃើញយើង ។ យើងនៅតែតម្រង់ដើរទៅមុខទៀតដូចជាមិនអស់កម្លាំងប៉ុន្មាន ព្រោះយើងបានហូបបាយឆ្អែត តាំងពីជាងមួយសប្តាហ៍មកហើយ ។ ពេលនោះ យើងដើរឆ្លងកាត់បឹងជាច្រើនអន្លើ តាមជ្រលងដានជើងអ្នករកត្រី បត់បែនចុះឡើងកាត់ភក់ជុំងខ្លះ កាត់ដីស្ងួតខ្លះរហូតមកដល់ប៉ែកឦសានភូមិទៀនកាំដែលស្ថិតនៅចំពីមុខយើងប្រហែល២គីឡូម៉ែត្រ ។ យើងសាកល្បងមើលទៅក្រោយ លុះត្រាតែមើលឃើញភូមិត្រពាំងថ្ម ក្លាយជាពណ៌ប្រផេះ ដូចជាដុំផ្សែង ។ម្តងនេះពួកយើងមានទំនុកចិត្តលើខ្លួនឯងថា បើពួកវាតាមយើងទៅដល់ភូមិរហាលល្មម នៅទីនោះមានកងទ័ពវៀតណាម និងកងទ័ពរណសិរ្សកំពុងជិះលើរថយន្តតាមបណ្តោយផ្លូវ លាន់ឮស្នូរគគ្រឹកទាំងខ្សែៗ ។ លុះមានទំនុកចិត្តហើយពួកយើងក៏នាំគ្នាឈប់សម្រាកមួយសន្ទុះ អ្នកខ្លះអង្គុយមូរថ្នាំជក់ អ្នកខ្លះដើរចេញពីកន្លែងនេះដើម្បីទៅរកទឹកនៅម្តុំទីជិតនោះផ្សើមបំពង់ក យើងឈប់នៅកន្លែងមួយចម្ងាយពីជើងទំនប់ទៀនកាំប្រហែល៥០ម៉ែត្រ ។ យើងអង្គុយនៅក្នុងបាតប្រឡាយ ដែលបុកត្រង់ស្ពានមួយខាងកើតភូមិរហាល យើងមិនហ៊ានអង្គុយជិតជើងទំនប់ ព្រោះខ្លាចពួកខ្មែរក្រហមផ្សេងទៀត ដែលចេញពីភូមិទៀនកាំដើរតាមផ្លូវដោយចៃដន្យឃើញពួកយើងហើយសម្លាប់ចោល ។

យើងអង្គុយអស់រយៈពេល២០នាទី ជុំនុំគ្នាហើយគិតតែរៀងៗខ្លួនប្រកបដោយក្តីព្រួយបារម្ភខ្លាចតែវង្វេង រកបងប្អូនមិនឃើញ ។ យើងនាំគ្នាដើរតាមបាតប្រឡាយដែលគ្មានទឹក គឺមានតែស្មៅដើមរឹង ឈរច្រូង ហើយដុះក្រាស់នៅតាមភ្លឺប្រឡាយទាំងសងខាងបិតបាំងយើងដែលដើរជាខ្សែមុខក្រោយប្រហែលជាង១០នាក់ ។ ពេលនោះ គ្មាននរណាម្នាក់បានឃើញពួកយើងឡើយ រហូតដល់ឡើងផ្លូវជាតិរួចហើយ យើងក៏ចូលជាមួយហ្វូងមនុស្ស

ដែលកំពុងធ្វើដំណើរយ៉ាងសកម្មដើម្បីទៅស្រុកកំណើត ។

## សុភមង្គលមិនពិតប្រាកដ

ពេលនោះ យើងធ្វើដំណើរលើកំណាត់ផ្លូវប្រហែល២០គីឡូម៉ែត្រ ក្នុងរាត្រីយប់ងងឹតមកដល់ផ្លូវត្រឡែងកែងរវាងផ្លូវជាតិលេខ៦ និងផ្លូវលំទៅភូមិចក្រី និងរពេលជ្រូក ។ នៅទីនោះ យើងឃើញមនុស្សកកកុញបោះជំរំនៅទីនោះ សម្លេងឮទ្រហឹង ដូចបុណ្យកឋិន ពេលនោះខ្ញុំ និងអ្នករួមដំណើរជាមួយបានដើររកមើលហ្វូងមនុស្សដ៏ច្រើនណែនណាន់ ។ មានអ្នកខ្លះកំពុងដាំស្ល ខ្លះទៀតកំពុងហូបបាយវង់ៗ ។ ខ្ញុំក៏ខំឱនដាក់ភ្នែកសម្លឹងមើលក្រែងមានបងប្អូនស្គាល់ ។ លុះដល់ម៉ោង៩យប់ មានអ្នកខ្លះដេក ខ្លះទៀតនៅអង្គុយ ខ្លះទៀត ដោយរោយជើង ដេកទទឹងទទែងក្បាលកើយបង្គិចខោអាវ នៅលើផ្លូវដើរតែម្តង ។

នៅទីបំផុត ខ្ញុំក៏បានរកឃើញគ្រួសារខ្ញុំកំពុងអង្គុយហូបបាយនៅក្បែរគល់ដូងមួយ ប៉ុន្តែពុំឃើញមានម្ហូបទេ ដោយសេចក្តីត្រេកអរឥតឧបមា នៅរាត្រីនោះយើងកំពុងគិតថា សេចក្តីសប្បាយរបស់យើងមានលក្ខណៈជាការសប្បាយបណ្តោះអាសន្ន ព្រោះជាការជួបជុំគ្នានៅកណ្តាលវាលមួយរយៈពេលខ្លី ព្រោះយើងត្រូវឆ្លងកាត់ឧបសគ្គជាច្រើនទៅថ្ងៃមុខ ដូច្នេះនេះមិនមែនជាសុភមង្គលរបស់យើងទេ ។ តាមពិតក្រុមគ្រួសារខ្ញុំនៅទីនោះ និងនៅរហូតលុះគ្រាជួបជុំបងប្អូនដែលពុំដឹងថានៅរស់តាមសហករណ៍ផ្សេងៗត្រឡប់មកជួបជុំគ្នាវិញ ។ ក្រោយពីសំណេះសំណាលពីអ្វីដែលយើងអាចនៅមានជីវិតបានរហូតមកទល់ពេលនោះ យើងក៏ចាត់ចែងធ្វើម្ហូបដូចជា ពិធីជប់លៀងមួយ ដោយធ្វើទាដែលចាប់ពីសហករណ៍ដាក់ស្ងោរនឹងដ្តិលទឹកមួយ ប៉ុន្តែទានោះឆ្អិនតែពោះ ចំណែកខាងខ្នងនៅឆៅ ព្រោះពុំមានគម្របគ្រប ។ យើងនាំគ្នាបេះហូបតែសាច់កន្លែងណាដែលឆ្អិនប៉ុណ្ណោះ ។

## ផ្លូវបំបែក

នៅពេលដែលដឹងថា កងទ័ពវៀតណាមបើកការវាយលុកកាន់តែជ្រៅចូលមកក្នុងប្រទេស ខ្មែរក្រហមបានភៀសខ្លួនទៅកាន់ព្រំដែនប៉ែកខាងលិច ដោយកៀរប្រជាជនរាប់ម៉ឺននាក់នៅតំបន់ចុងកាត់ មាត់ញាក់ទៅជាមួយផងដែរ ។ នៅថ្ងៃ៧ មករា ប្រជាជនខ្មែរដែលបានរំដោះនឹកស្មានថា បានទទួលសេរីភាពឡើងវិញត្រូវវងទុក្ខវេទនា និងព្រាត់ប្រាសគ្នាម្តងទៀតដោយរត់ឡើងភ្នំ កាត់ព្រៃភ្នំក្រមថ្ម ត្រូវដាច់ពោះ ព្រោះនៅលើកំពូលភ្នំដោយគ្មានអាហារ ដោយគ្មានទឹកផឹក ព្រោះមិនស្គាល់ភូមិសាស្ត្រដែលក្នុងករណីខ្លះ ត្រូវវង្វេងនៅក្នុងព្រៃស្លាប់ដោយដាច់អាហារ ឬសត្វសាហាវយាយី ។

ប្រជាជនមួយចំនួនទៀត ត្រូវវងគ្រាប់កាំភ្លើងនៅកណ្តាលសមរភូមិប្រយុទ្ធរវាងកងទ័ពវៀតណាម និងខ្មែរក្រហម ។ ប្រជាជនជម្លៀសនេះមានពីរប្រភេទមានប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ។ ប្រជាជនថ្មីដែលស្អប់លទ្ធិកុម្មុយនីស្តមិនចូលចិត្តខ្មែរក្រហមបានរកផ្លូវវិលត្រឡប់ថយក្រោយមករកស្រុកកំណើតដើម្បីជួបជុំបងប្អូនត្រូវវងទុក្ខវេទនាមួយគ្រាទៀតដោយសារដាច់ស្បៀង រហូតដល់អារសាច់ខ្មោចធ្វើជាអាហារ ធ្វើយ៉ាងណាដើម្បីបានមកដល់ខេត្តមួយចំនួនដែលជាស្រុកកំណើត ដោយទុកចោលប្តី ឬប្រពន្ធនៅលើភ្នំដែលកំពុងមានជំងឺគ្រុនចាញ់ញាំញីមិនអាចបញ្ជិះកន្លារួច ដោយសារតែកូនតូចៗមកជាមួយ ។ ពេលមកដល់ស្រុកភូមិវិញ បានជួបជុំបងប្អូននិយាយថា ដូចជាកើតមកម្តងទៀត ។ ម្នាក់ៗបាននិទានសាច់រឿងរបស់គេដែលជារឿងកំសត់វេទនាខុសៗគ្នាជូនបងប្អូនស្តាប់ ហើយនាំគ្នាអង្គុយយំខ្សឹកខ្សួលដោយក្តីស្រណោះស្រណោក ។ ដូចជា មានអ្នកខ្លះដាច់ចិត្តទុកប្តី ឬប្រពន្ធនៅលើភ្នំនាំយកតែកូនត្រឡប់មកស្រុក រឿងសោកនាដកម្មនៃប្រជាជនខ្មែរនៅពេលនោះ មានការព្រាត់ប្រាសធ្ងន់ធ្ងរ ជាងសាច់រឿងនាងបដាចារទៅទៀត ។ ចំណែកឯប្រជាជនថ្មីមួយចំនួនដែលដឹងថាអង្គការសហប្រជាជាតិបានបើកជំរំដោយមានការផ្គត់ផ្គង់គ្រប់បែបយ៉ាង ក៏ភៀសខ្លួនចេញពីតំបន់ជម្លៀសដោយមិនវិលត្រឡប់ទៅស្រុកកំណើត ព្រោះផ្អែតចិត្តនឹងការវេទនាហួសនិស្ស័យដែលខ្មែរក្រហមស្រវឹងនឹងមនោគមវិជ្ជាសម្លាប់រង្គាលខ្មែរគ្នាឯងនៅលើទឹកដីមួយ ដែលព្រះពុទ្ធសាសនាបានចាក់ឫសគល់រាប់ពាន់ឆ្នាំមកហើយ ពិតជាគ្មាននរណាមួយជឿថារបបនេះនឹងកើតមានយ៉ាងដូច្នេះ ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនក៏ប្តេជ្ញាគេចចេញឲ្យឆ្ងាយទាន់មានឱកាស ដើម្បីទៅរស់នៅក្នុងប្រទេសទីបីដែលគេជឿថានឹងមានអនាគតភ្លឺស្វាងសម្រាប់គ្រួសារ ។ គ្រាន់តែរំដោះភ្លាមមិនបង្អង់យូរ ប្រជាជនក៏នាំគ្នាទាំងហ្វូងៗ តម្រង់ទៅកាន់ព្រំដែនតាមច្រកប៉ោយប៉ែត និងច្រកផ្សេងទៀត ដែលគេយល់ថា

នៅជិតដើម្បីចូលទៅរស់នៅជាបណ្តោះអាសន្ននៅតាមជំរំក្នុងទឹកដីថៃ ។ ចំណែកពួកខ្មែរក្រហមដែលបាត់បង់ អំណាចបានខិតខំប្រមូលបំណែកទ័ពដែលនៅសេសសល់ពីការបំផ្លាញរបស់កងទ័ពវៀតណាម ដើម្បីដុំកម្លាំងឡើងវិញ តស៊ូវាយបកប្រឆាំងនឹងកងទ័ពវៀតណាមដោយយកជួរភ្នំដងរែកធ្វើជាមូលដ្ឋានបង្អែកបន្ទាប់ពីត្រាច់ចរវិលវល់តាមផ្លូវបត់បែនដ៏វែងឆ្ងាយ នៅក្រោមកំដៅថ្ងៃប្រកបដោយការហេវហត់អស់រយៈពេលជាច្រើនខែឆ្លងកាត់ជួរភ្នំក្រវាញ និងជួរភ្នំដងរែកនេះគឺជាការតស៊ូបដិវត្តន៍លើកទីពីររបស់ខ្មែរក្រហមដែលប្រកបដោយគ្រោះថ្នាក់ ។

នៅក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ មានប្រជាជនជនខ្មែរភៀសខ្លួនប្រហែល៣សែននាក់ បានភៀសខ្លួនទៅកាន់ព្រំដែនខ្មែរ-ថៃ ដែលរស់នៅតាមជំរំចំនួន៧៨កន្លែងដែលបែងចែកជា៣ក្រុមគឺ ជំរុំលោកតា សឺន សាន រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ជំរំខ្មែរក្រហម និងជំរំរបស់រាជានិយមហ៊ុនស៊ីនប៉ិច ។ បើប្រៀបធៀបពីជីវភាពរស់នៅរបស់ប្រជាជន ការរស់នៅតាមជំរំមានជីវភាពល្អជាងការរស់នៅក្នុងប្រទេសក្នុងឆ្នាំ១៩៧៩ ។

## ការធ្វើដំណើរត្រឡប់ទៅស្រុក

នៅក្រោយថ្ងៃ៧ មករា ប្រជាជនជម្លៀសបានរួចផុតពីគុកឥតជញ្ជាំង ហើយជាពេលមួយដែលលេចឡើងនូវការព្រាត់ប្រាស និងការឈឺចាប់ ។ សមាជិកគ្រួសារខ្ញុំប្រហែល១០នាក់ បាត់បង់ជីវិតដោយដាច់អាហារ និងជំងឺនៅតាមសហករណ៍នៅភូមិភាគពាយ័ព្យ ។ ខ្ញុំបាត់ដំណឹងគាត់នៅពេលដែលមានស្ថានភាពជ្រួលច្របល់នៅភ្នំពេញ និងពេលដែល ប៉ុល ពត ជម្លៀសយ៉ាងតក់ក្រហល់ ។ នៅសម័យកម្ពុជាប្រជាធិបតេយ្យប្រជាជនបានស្លាប់ដោយប្រការផ្សេងៗ ប៉ុន្តែការស្លាប់ដោយដាច់ពោះជាការស្លាប់ដែលវេទនា ដោយមុននឹងស្លាប់អ្នកជំងឺស្រែកទារកបាយ រកបបរ នំចំណីតាមតែការនឹកឃ្លាន ។ បងប្អូនដែលនៅជុំវិញអ្នកជំងឺបានត្រឹមសម្រក់ទឹកភ្នែកអាណិតអាសូរប៉ុណ្ណោះ ព្រោះពុំមានវិធីដោះស្រាយ ឬពុំមានរបស់របរសម្រាប់ដោះដូរយកអាហារ ។ សម្លេងប្អូនស្រែកទារបាយនៅតែឮនៅក្នុងត្រចៀករបស់ខ្ញុំរហូត ។

បន្ទាប់ពីស្នាក់នៅទីប្រជុំជនជប់អស់មួយយប់ ដើម្បីស៊ើបសួរដំណឹងបងប្អូនផ្សេងទៀត ស្អែកឡើងបន្ទាប់ពីហូបបាយព្រឹកហើយ យើងក៏ចាប់ធ្វើដំណើរមកទិសខាងលិចសំដៅទៅស្វាយស៊ីសុផុន ។ យើងអូសរទេះជាមួយសមាជិកគ្រួសារដែលនៅរស់សរុប២០នាក់ក្នុងគោលបំណងវិលទៅស្រុកកំណើតខាងប្រពន្ធនៅខេត្តតាកែវ ។ ក្នុងចម្ងាយផ្លូវតែ៥គីឡូម៉ែត្រពីជប់ទៅគោកពង្រស្ថិតក្នុងស្រុកព្រះនេត្រព្រះ យើងត្រូវធ្វើដំណើរពេញមួយថ្ងៃដោយផ្លូវទៅជប់មានចំណោតខ្លាំង ព្រោះនៅទីនោះមានភ្នំមួយ “ភ្នំជញ្ជាំង” ។ ម្យ៉ាងទៀត រទេះយើងធ្ងន់ និងមានអីវ៉ាន់សំពីងសំពោង ដូចជាខ្ទើយ កន្ទេល មុង ចានឆ្នាំង អង្ករ អំបិល ប្រហុកដែលយកបានពីរោងសហករណ៍ប៉ោយក្បឿង ក្រោយពេលកម្មាភិបាលខ្មែរក្រហមរត់ភៀសខ្លួនទៅកាន់ភ្នំដងរែករយៈពេល២ថ្ងៃមុនពេលកងទ័ពវៀតណាមចូលទៅដល់ទីនោះ ។

## គោកលន់ ក្រោយរបបខ្មែរក្រហម

ក្រោយពីឈប់មួយស្របក់នៅលើចំណោតភ្នំ យើងបានចាប់ចេញដំណើរចុះចំណោតយ៉ាងស្រួលរហូតដល់សហករណ៍គោកលន់ ។ ពេលនោះ ខ្ញុំចង់ចូលជួបឪពុកមាម្នាក់ ប៉ុន្តែដោយសារភូមិនេះនៅជាប់នឹងផ្លូវជាតិ គាត់ក៏នាំគ្រួសារគាត់ចាកចេញទៅអស់ដោយបន្សល់ទុកតែផ្ទះខ្ទមប៉ុណ្ណោះ ។ គោកលន់ជាសហករណ៍ក្រខ្សត់ជាងគេនៅក្នុងចំណោមសហករណ៍នៅស្រុកព្រះនេត្រព្រះ ដីធ្លីនៅជុំវិញភូមិជាដីក្តាំង សូម្បីតែដំឡូងក៏គ្មានមើមដែរ គឺមានតែឫសប៉ុណ្ណោះ ។ ចំណែកស្រូវដែលដាំនៅតាមវាលស្រែខាងលិចភ្នំច្រប់ ក៏មិនបានផលល្អដែរ ។ នៅក្នុងភូមិនេះមានផ្ទះប្រហែលមួយរយខ្នងផ្ទះ នៅសល់អ្នករស់ជីវិតនៅលើផ្ទះមិនដល់២០ខ្នងផង គឺដោយសារអ្នកទាំងនោះសុទ្ធតែជាអ្នកពូកែខាងដោះដូររបស់របរដូចជា មាស ពេជ្រ ជាមួយអង្ករទើបអាចរស់បានដូច្នេះ ។

## ភូមិគោកពង្រ

ដោយយល់ឃើញថា ខ្វះស្បៀងតាមផ្លូវ យើងក៏សម្រេចចិត្តទៅសម្រាកនៅគោកពង្រចំនួនពីរថ្ងៃដើម្បីបុកស្រូវទុកធ្វើស្បៀង ។ នៅតាមផ្លូវ យើងក៏បានចែកការងារគ្នា ដោយខ្លះដើររកស្រូវ ខ្លះទៀតដើររកម្ហូប និងត្រូវចុះដើរពីផ្លូវជាតិប្រហែល៥ទៅ៦គីឡូម៉ែត្ររកទីតាំងទាំងនោះ ។ ពេលនោះ មនុស្សដើរបាចសាចពេញវាល ។ យើងមិនលើកលែងថាសត្វតូច ឬធំទេ សូម្បីតែ សត្វសេះ គោ ក្របី ក៏ចាប់មកធ្វើម្ហូបដែរ ។ នៅភូមិឈ្មួ បងថ្លៃខ្ញុំចាប់បាន

សេះ និងរកបានរទេះមួយ ប៉ុន្តែយើងមិនបានយកធ្វើម្ហូបទេ គឺទុកសម្រាប់ដឹកអីវ៉ាន់ ។ យើងបានធូរស្រាលកម្លាំងដោយសាររទេះសេះនេះ ។ នៅថ្ងៃបន្ទាប់ យើងត្រូវដាស់គ្នាឲ្យក្រោកតាំងពីម៉ោង៤ទៀប ភ្លឺ ដោយស្រីៗនាំគ្នារៀប បន្តាត់ភ្លើង លាងឆ្នាំង ដាំបាយ ធ្វើម្ហូបហូបបាយ មុនពេលចេញដំណើរ ។ ចំណែកប្រុសៗរៀបចំអីវ៉ាន់ដាក់លើរទេះមានកន្ទេលមុងនឹងអង្ករជាដើមឲ្យស្រេច ។

## ភូមិសាលាក្រៅ

នៅម៉ោង៧ព្រឹក យើងចាប់ចេញដំណើររហូតដល់ថ្ងៃត្រង់ទើបទៅដល់សាលាក្រៅ ជាកែងផ្លូវឆ្ពោះទៅកាន់សង្កាត់ភាស ក្នុងស្រុកបន្ទាយឆ្មារ ។ ពីមុនខ្ញុំមិនដែលស្គាល់សាលាក្រៅទេ ប៉ុន្តែនៅចុងឆ្នាំ១៩៧៥ ខ្ញុំបានស្នាក់នៅទីនោះមួយរយៈដើម្បីលើកប្រព័ន្ធភ្លឺ ។ ពេលនោះ សាលាក្រៅនៅរក្សារូបរាងជាទីផ្សារមួយ ដោយនៅសល់ផ្ទះល្អៗលាយឡំនឹងផ្សារ នៅអមសងខាងផ្លូវជាតិលេខ៦ ។ រំលងតែបីឆ្នាំប៉ុណ្ណោះ អ្វីៗប្រែប្រួលស្ទើរមើលមិនស្គាល់ ខ្មែរក្រហមបានរុះរើផ្ទះអស់រលីងនៅសល់តែដើមដូងខ្លះៗប៉ុណ្ណោះ ។ ខ្ញុំស្រឡាញ់ទឹកដីសាលាក្រៅ ព្រោះស្រូវសន្ទូងនៅទីនោះផ្តល់ទិន្នផលខ្ពស់ ថែមទាំងជាកន្លែងសម្បុកត្រីស្រែដ៏មានរសជាតិ ជាពិសេស គឺត្រីអណ្តែង ។ គ្រាន់តែយើងយកមងចាស់ៗទៅរាយតាមចន្លោះគុម្ពស្រូវ នៅខែកត្តិកក៏ជាប់ត្រីដោះមិនឈ្នះ ម្យ៉ាងទៀតយើងអាចធ្វើអន្ទង ។ អនុស្សាវរីយ៍លើកប្រព័ន្ធភ្លឺនៅសាលាក្រៅបានដក់ជាប់នៅក្នុងអារម្មណ៍ជានិច្ច ។

## ស្រុកកំណើត

នៅសម័យ ប៉ុល ពត ដោយសាធ្វើថ្នាំគ រាល់ពេល ការក្លែងប្រវត្តិរូប បានធ្វើឲ្យខ្ញុំបានរស់រានមានជីវិតមកដល់សព្វថ្ងៃ ។ សាច់ញាតិខ្ញុំបានជួបជុំគ្នាឡើងវិញ និងបានត្រឡប់មករស់នៅស្រុកកំណើតវិញ ។ ប៉ុន្តែរបបនេះបានធ្វើឲ្យខ្ញុំបាត់បង់បងប្អូន និងបាត់បង់នូវអ្វីៗដែលខ្ញុំធ្លាប់មានពីមុនមក ។ របបនេះបានបន្សល់នូវភាពភ័យខ្លាច តក់ស្លុត និងភាពទុរគតតោកយ៉ាក សម្រាប់ប្រជាជនកម្ពុជាដើម្បីរស់ឡើងវិញ ។

**ស៊ីវ ធួន**

*ក្រុមទស្សនាវដ្តីស្វែងរកការពិត សូមថ្លែងអំណរគុណអស់ពីដួងចិត្តដល់លោកគ្រូ ស៊ីវ ធួន ដែលបានចែករំលែក និងសរសេររឿងរ៉ាវជីវិតផ្ទាល់ខ្លួនសម្រាប់ការបោះពុម្ពផ្សាយនេះ ។*



ស៊ីវ ធួន កំពុងបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់លោកគ្រូ-អ្នកគ្រូប្រវត្តិសាស្ត្រនៅខេត្តស្ទឹងត្រែងកាលពីខែមេសា ឆ្នាំ២០១០

# ដំណឹងស្វែរកឪពុក និងបងប្អូន

នាងខ្ញុំឈ្មោះ ឃឹម ធារី អាយុ៥៦ឆ្នាំ សព្វថ្ងៃរស់នៅបុរីកីឡា សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។ សូមប្រកាសរកឪពុក និងបងប្អូនប្រុសស្រីដែលមានរាយនាមដូចខាងក្រោមៈ

១) ឈ្មោះ ឃឹម ខាន់ ត្រូវជាឪពុក ជាអតីតទាហាន លន់ នល់ និងជាកូនឈ្នួលរបស់ទ្រង់ ចាន់ រង្សី ។ នៅអំឡុងឆ្នាំ១៩៧៣ ឪពុកនាងខ្ញុំត្រូវខ្មែរក្រហមចាប់ខ្លួនពីបន្ទាយឈូកវ៉ា ហើយក៏បាត់ដំណឹងគាត់ចាប់តាំងពីពេលនោះមក ។

២) ឃឹម សុភាព ត្រូវជាប្អូនស្រី ជាអតីតសិស្សថ្នាក់ទី៤ទំនើប នៅសាលាទួលគោក ។ កាលពីរបបខ្មែរក្រហម សុភាព មានអាយុ១៦ឆ្នាំ ។ នៅឆ្នាំ១៩៧៧ សុភាព ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងចល័តតំបន់៥៤ ម្តុំភ្នំជីសូរ ហើយក៏បាត់ដំណឹងគាត់តាំងពីពេលនោះមក ។

៣) ឃឹម សាណារិន នៅក្នុងរបបខ្មែរក្រហមមានអាយុ២៦ឆ្នាំ ។ បង ណារិន បានបាត់ខ្លួនក្នុងអំឡុងឆ្នាំ១៩៧៧ ។

៤) មាស ចំរើន ត្រូវជាបងប្រុសជីដូនមួយ ជាអតីតទ័ពអាកាស ។ ចំរើន បានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៤ ពេលដែលគាត់ទៅរៀនបន្តនៅទីក្រុងបាងកក ។

**បញ្ជាក់** ៖ មុនខ្មែរក្រហមទទួលជ័យជម្នះ ក្រុមគ្រួសាររបស់នាងខ្ញុំរស់នៅផ្សារកីឡូលេខ៤ សង្កាត់លេខ៣ ភ្នំពេញ ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់នាងខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ អាស្រ័យហេតុនេះ បើបងប្អូនណាបានស្គាល់ ឬឮឈ្មោះអ្នកដែលនាងខ្ញុំបានរៀបរាប់ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈអាសយដ្ឋានខាងលើ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០១៥ ៨៨២ ២៨២ ឬ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# ដំណឹងស្វែរកបងស្រី

នាងខ្ញុំឈ្មោះ ហ៊ឹម ថន អាយុ៥៨ឆ្នាំ រស់នៅភូមិសណ្តោ ឃុំដាងទង ស្រុកត្រាំកក់ ខេត្តតាកែវ សូមប្រកាសស្វែរកប្អូនប្រុសឈ្មោះ ហ៊ឹម ញ៉ាយ ដែលបានបាត់ខ្លួន ក្រោយពីចាកចេញពីភូមិកំណើតទៅធ្វើជានិរសារនៅក្នុងរបបខ្មែរក្រហមតាំងពីអាយុ១១ឆ្នាំ ។ ឪពុកនាងខ្ញុំឈ្មោះ បូរ ម្តាយឈ្មោះ ថាន់ ។ នាងខ្ញុំមានបងប្អូន ៦នាក់គឺៈ ១) ហ៊ឹម មុំ (ស្រី) ២) ហ៊ឹម ឡី (ស្រី) ៣) នាងខ្ញុំ ៤) ហ៊ឹម ញីវ (ប្រុស) ៥) ហ៊ឹម ញ៉ាយ (បាត់ខ្លួន) និង ៦) ហ៊ឹម ទូច ភេទស្រី (ស្លាប់) ។ ហ៊ឹម ញ៉ាយ ត្រូវបានចាត់តាំងឲ្យធ្វើជានីរសារជាមួយមេកងចល័តឈ្មោះ ញ៉ី ហៀង នៅភូមិសណ្តោ ឃុំដាងទង នៅក្នុងរបបខ្មែរក្រហម ហើយបានធ្វើដំណើរទៅតាមកងចល័តរហូត ។ ក្រោយពីរបបខ្មែរក្រហមដួលរលំទៅនៅឆ្នាំ១៩៧៩ ប្អូនប្រុស ហ៊ឹម ញ៉ាយ ធ្លាប់ផ្តល់ដំណឹងមកគ្រួសារម្តងតាមរយៈឪពុកមាថា បានទៅធ្វើជាជាងតខ្សែភ្លើងនៅភ្នំពេញ ។ ក្រោយមក ខ្ញុំឮដំណឹងថា ប្អូនប្រុស ញ៉ាយ បានផ្លាស់មកធ្វើការនៅកំពតវិញ ប៉ុន្តែមិនបានត្រឡប់មកស្រុកកំណើតទេ ដោយសារស្រុកកំណើតមិនទាន់មានសន្តិភាព ។ ចាប់តាំងពីពេលនោះមក នាងខ្ញុំបាត់ដំណឹងប្អូនប្រុសរហូតមកទល់សព្វថ្ងៃនេះ ។

អាស្រ័យហេតុនេះ ប្រសិនបើបងប្អូនណាបានទទួលដំណឹងឬធ្លាប់បានស្គាល់ឈ្មោះ ហ៊ឹម ញ៉ាយ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១៦ ៨៧៦ ៦៩២ អាស័យដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ។

**សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ តរុតហក្សៀកតហាយ2ដចចាម ។ៀរង ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 156, December 2012 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.